សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ផលចំណេញនៃការវិនិយោគផ្ទាល់ពីបរទេស លើវិស័យវាយនភ័ណ្ឌនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែ មីនា ២០២២ ដល់ថ្ងៃទី ២៣ ខែ ឧសភា ២០២២


តាក់តែងឡើងដោយ
និស្សិតឈ្មោះ	ថេង ម៉ាលីន
គៀត ម៉ៃយ៉ា

សាស្ត្រាចារ្យណែនាំ
លោកស្រី ឡុង ម៉ាមីឌី


ថ្នាក់បរិញ្ញាបត្រ គ្រប់គ្រងធុរកិច្ច
ជំនាន់ទី ៦ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា	២០១៨
ឆ្នាំសរសេរសារណា	២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ផលចំណេញនៃការវិនិយោគផ្ទាល់ពីបរទេស លើវិស័យវាយនភ័ណ្ឌនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែ មីនា ២០២២ ដល់ថ្ងៃទី ២៣ ខែ ឧសភា ២០២២


តាក់តែងឡើងដោយ
និស្សិតឈ្មោះ ថេង ម៉ាលីន
គៀត ម៉ៃយ៉ា

សាស្ត្រាចារ្យណែនាំ
លោកស្រី ឡុង ម៉ាមីឌី


ថ្នាក់បរិញ្ញាបត្រ គ្រប់គ្រងធុរកិច្ច
ជំនាន់ទី ៦ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ ថេង ម៉ាលីន និង គៀត ម៉េយ៉ា ជានិស្សិតថ្នាក់បិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងធុរកិច្ច ជំនាន់ទី ៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ "**ផលចំណេញនៃការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌនៅកម្ពុជា**" យើងខ្ញុំសូមធ្វើការគោរពជូន និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដូចតទៅះ

ជាបឋមយើងខ្ញុំសូមសំដែងនូវការដឹងគុណ និងការគោរពដ៏ខ្ពង់ខ្ពស់ចំពោះអ្នកមានគុណទាំងពីរនូវគុណដ៏ធំធេងពីរគឺ ជាតិគុណ និងឧបការគុណ ដែលលោកទាំងពីរបានផ្តល់កំណើត និងចញ្ចឹមបីបាច់ថែរក្សា ព្រមទាំងអប់រំទូន្មានប្រៀនប្រដៅដែលជាពិសេសនោះគឺ លោកទាំងពីរបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ កម្លាំងចិត្ត និងធនធានទំនុកបម្រុងការសិក្សាតាំងពី ថ្នាក់បឋម រហូតដល់ថ្នាក់បរិញ្ញាបត្រ ដែលជាថ្នាក់ឧត្តមសិក្សានេះ។

អ្នកគ្រូ**សាស្ត្រាចារ្យ ឡុង ម៉ាមីឌី** ដែលបានជួយជ្រោមជ្រែង ដឹកនាំ និងផ្តល់ជាទស្សនៈល្អៗហើយ បានកែរតម្រូវរាល់កំហុសខុសឆ្គង ដែលមាននៅក្នុងសារណានេះ ចាប់តាំងពីចំណុចចាប់ផ្តើមរហូតទទួលបានជោគជ័យ ទោះបីជាមានពេលវេលាស្លួចស្តើងយ៉ាងណាក៏ដោយ។

លោក**សាស្ត្រាចារ្យបណ្ឌិត ង៉ាន់ ស៊ុនដេត** ដែលលោកបានខិតខំបង្រៀនវិធីសាស្ត្រស្រាវជ្រាវ និងជួយណែនាំអំពីរបៀបសរសេរសារណា។

ជាមួយគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់ការចូលរួមចំណែកជំរុញដល់ការសិក្សាអស់រយៈពេល ៤ឆ្នាំកន្លងមក ចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការ ព្រឹទ្ធបុរស លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកដែលកំពុងបម្រើការនៅសាកលវិទ្យាល័យទាំងអស់ ព្រមទាំងមិត្តរួមថ្នាក់ដែលបានសិក្សាជាមួយគ្នាកន្លងមក។

# អំណរគុណ

សារណា គឺជាការប្រមូលផ្តុំនូវចំណេះដឹង និងជាសមិទ្ធផលចុងក្រោយនៃការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែលជាការស្រាវជ្រាវកម្រិតបឋម ក្នុងរយៈពេលកំណត់មួយ។ ជាក់ស្តែងសារណាមួយនេះជាលទ្ធផលចុងក្រោយ និងជាចំណេះដឹងដែលបានសិក្សាអស់រយៈពេល ៤ឆ្នាំ នៃថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងធុរកិច្ច។

ការស្រាវជ្រាវលើប្រធានបទ "ការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌកាត់ដេរ គឺមានគោលបំណងក្នុងការពង្រីកចំពោះចំណេះដឹងលើ ស្ថានភាពនៃការវិនិយោគផ្ទាល់ពីបរទេសពិសេសលើវិស័យវាយនភ័ណ្ឌ។ ការស្រាវជ្រាវនេះ នឹងផ្តល់នូវចំណេះដឹងលើផ្នែកទ្រឹស្តីសេដ្ឋកិច្ច ដែលទាក់ទងទៅនឹងការវិនិយោគ ព្រមទាំងសិក្សាអំពីស្ថានភាពវិនិយោគផ្ទាល់ពីបរទេស ជាពិសេសការវិនិយោគលើវិស័យវាយនភ័ណ្ឌ និងគោលនយោបាយមួយចំនួនផងដែរក្នុងការទាក់ទាញវិនិយោគ ជាពិសេសវិនិយោគបរទេស។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះក៏ធ្វើការវិភាគលើសក្តានុពលរបស់កម្ពុជាដែលជាកត្តាទាក់ទាញអ្នកវិនិយោគផ្ទាល់ពីបរទេស។

ជាចុងក្រោយយើងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ ដែលមានចំណាប់អារម្មណ៍ និងបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការអានកិច្ចការស្រាវជ្រាវរបស់ពួកយើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចការស្រាវជ្រាវនេះពិតជាមានកង្វះខាត និងកំហុសឆ្គងណាមួយជៀសពុំផុត ដែលកើតឡើងដោយសារចំណេះដឹង និងបទពិសោធន៍មានកម្រិត ព្រមទាំងពេលវេលាមានកំណត់។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាឯកសារមួយនេះពិតជាផ្តល់ផលប្រយោជន៍ និងខ្លឹមសារៈសំខាន់ៗ ដែលជាចំណេះដឹងសម្រាប់ការសិក្សាស្រាវជ្រាវបន្តបន្ទាប់។

# មាតិកា

តារាងអក្សរកាត់....iv
បញ្ជីតារាង....v
បញ្ជីរូបភាព....vi

## សេចក្តីផ្តើម

១. លំនាំបញ្ហា....១
២. ចំណោទបញ្ហា....២
៣. គោលបំណងនៃការស្រាវជ្រាវ....២
៤. ទំហំ និងដែនកំណត់....២
៥. សារៈសំខាន់នៃការស្រាវជ្រាវ....៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ....៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ....៣

## ជំពូកទី ១
## រំលឹកទ្រឹស្តី

១.១. ទស្សនៈទាននៃការវិនិយោគ....៥
១.១.១. និយមន័យ....៥
១.១.២. កត្តាកំណត់ការវិនិយោគ....៦
១.២. ការវិនិយោគផ្ទាល់ពីបរទេស....៦
១.២.១. និយមន័យនៃការវិនិយោគផ្ទាល់ពីបរទេស....៦
១.៣. ទម្រង់នៃការវិនិយោគផ្ទាល់ពីបរទេស....៦
១.៤. គោលបំណងនៃការវិនិយោគផ្ទាល់ពីបរទេស....៧
១.៤.១. ការវិនិយោគស្វែងរកទីផ្សារ....៧
១.៤.២. ការវិនិយោគក្នុងការនាំចេញ....៨
១.៤.៣. ការវិយោគស្វែងរកមូលធន....៩
១.៥. កត្តាដែលធ្វើអោយមានឥទ្ធិពលដល់ការវិនិយោគផ្ទាល់ពីបរទេស....៩
១.៥.១. ទំហំទីផ្សារ....៩
១.៥.២. ថ្លៃដើមពលកម្ម....៩
១.៥.៣. អត្រាការប្រាក់....១០
១.៥.៤. អត្រាប្តូរប្រាក់....១០
១.៥.៥. ស្ថានភាពនយោបាយ....១០

## ជំពូកទី ២
## ស្ថានភាពទូទៅនៃការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជា


២.១. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា............................................................................................................១១
២.២. ស្ថានភាពវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជា.......................................................................១៤
២.២.១. បណ្តាប្រទេសដែលវិនិយោគនៅប្រទេសកម្ពុជា....................................................................១៦
២.២.១.១. ប្រទេសអាស៊ាន..................................................................................................១៧
២.២.១.២. ប្រទេសចិន........................................................................................................១៨
២.២.១.៣. សហរដ្ឋអាមេរិក...................................................................................................១៩
២.២.១.៣. សហភាពអឺរ៉ុប.....................................................................................................១៩
២.៣. កត្តាទាក់ទាញវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជា.......................................................................២០
២.៣.១. ស្ថេរភាពនយោបាយ.............................................................................................................២០
២.៣.២. ធនធាន និងសក្តានុពលធម្មជាតិ...........................................................................................២១
២.៣.៣. តំបន់សេដ្ឋកិច្ចពិសេស.........................................................................................................២៣
២.៣.៤. គោលនយោបាយលើកទឹកចិត្ត..............................................................................................២៤
២.៣.៥. ការធានា និងការការពារវិនិយោគ.........................................................................................២៥
២.៣.៦. ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន..................................................................................................២៦
២.៣.៧. សម្បូរភាពពលកម្ម និងកម្រិតប្រាក់ឈ្នួលទាប.......................................................................៣២


## ជំពូកទី ៣
## ស្ថានភាពទូទៅនៃវិស័យវាយនភ័ណ្ឌនៅប្រទេសកម្ពុជា


៣.១. ទិដ្ឋភាពទូទៅនៃវិស័យកាត់ដេរនៃវិស័យកាត់ដេរនៅប្រទេសកម្ពុជា............................................................៣៥
៣.១.១. ការវិវត្តនៃទំនាក់ទំនងទីផ្សារនាំចេញសម្លៀកបំពាក់របស់កម្ពុជា.................................................៣៨
៣.១.២. ចំណែកទីផ្សារ និងទំហំនាំចេញផលិតផលសម្លៀកបំពាក់របស់ប្រទេសកម្ពុជា............៣៩
៣.១.៣. វិនិយោគទុនក្នុងវិស័យវាយនភ័ណ្ឌ.......................................................................................៤២
៣.១.៤. អំពីរោងចក្រកាត់ដេរ.........................................................................................................៤៤
៣.១.៥. ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភ័ណ្ឌ..........................................................................៤៦


## ជំពូកទី ៤
## ផលចំណេញពីការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌនៅប្រទេសកម្ពុជា


៤.១. ឱកាសការងារ និងប្រាក់បៀវត្សន៍.........................................................................................................៥១
៤.២. ការកាត់បន្ថយភាពក្រីក្រ......................................................................................................................៥២

៤.៣. ការពង្រឹងធនធានមនុស្ស និងការអភិវឌ្ឍជំនាញ......................................................................៥២
៤.៤. ការបង្កើននូវបច្ចេកវិទ្យា.................................................................................................................៥២
៤.៥. លទ្ធផលនៃការស្រាវជ្រាវ.................................................................................................................៥៣

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន.............................................................................................................................៥៥
២. ការផ្តល់អនុសាសន៍.........................................................................................................................៥៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

ADB : Asia Development Bank ធនាគារអភិវឌ្ឍន៍អាស៊ី

AEC : ASEAN Economic Community សហគមន៍សេដ្ឋកិច្ចអាស៊ាន

AFT : ASEAN Free Trade Agreement កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន

AJCEP: ASEAN-Japan Comprehensive Economic Partnership (កិច្ចព្រមព្រៀង ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន)

CIB : Cambodia Investment Board គណៈកម្មាធិការវិនិយោគកម្ពុជា

CDC : Council Development of Cambodia ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

FDI : Foreign Direct Investment ការវិនិយោគផ្ទាល់ពីបរទេស

FTA : Free Trade Agreement កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

GDP : Gross Domestic Product ផលិតផលក្នុងស្រុកសរុប

GSP : Generalized System of Preferences ប្រពន្ធអនុគ្រោះពន្ធទូទៅ

JETRO: Japan External Trade Organization អង្គការពាណិជ្ជក្រៅប្រទេសជប៉ុន

MEF : Ministry of Economic and Finance ក្រសួងសេដ្ឋកិច្ចសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

MFN : Most Favored Nations បណ្តាប្រទេសដែលអំណោយផលបំផុត

MPWT : Ministry of Public Works and Transport ក្រសួងសាធារណៈការ និងដឹកជញ្ជូន

NIS : National Institute of Statistic វិទ្យាស្ថានជាតិស្ថិតិ

OCIC : Overseas Cambodian Investment Corporation អូវើស៊ី ខេមបូឌាន អ៊ីនវេសមេន ខបភើរេសិន

PAS : Port Autonomous of Shihanukville កំពង់ផែព្រះសីហនុ

PPAP : Phnom Penh Autonomous Port កំពង់ផែស្វយ័តក្រុងភ្នំពេញ

SEZ : Special Economic Zone តំបន់សេដ្ឋកិច្ចពិសេស

SSCA : State Secretariat of Civil Aviation អគ្គលេខាធិការដ្ឋានអាកាសចរណ៍ និងស៊ីវិល

WTO : World Trade Organization អង្គការពាណិជ្ជកម្មពិភពលោក

# បញ្ជីតារាង

តារាងទី១ ៖ ពាណិជ្ជកម្មរបស់កម្ពុជាជាមួយដៃគូសំខាន់ៗក្នុងឆ្នាំ ២០២០...............................១៦
តារាងទី២ ៖ ផលនេសាទត្រីទឹកសាបពីឆ្នាំ ២០០៩-២០១៣..............................................២២
តារាងទី៣ ៖ ចំនួនពលកម្មនៅកម្ពុជាក្នុងចន្លោះឆ្នាំ ២០០៩-២០១៤.....................................៣៣
តារាងទី៤ ៖ ការប្រើធៀបថ្លៃ FDI លើប្រាក់ឈ្នួលក្នុងប្រទេសកម្ពុជា ថៃ និងម៉ាឡេស៊ី ២០២២.....៣៤
តារាងទី៥ ៖ ការវិវត្តនៃប្រាក់ឈ្នួលអប្បបរមា និងប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅកម្ពុជាឆ្នាំ២០២២..៤៨

# បញ្ជីរូបភាព


រូបភាពទី១ ៖ អត្រាកំណើន GDP របស់កម្ពុជាជាប្រចាំឆ្នាំតាមវិស័យ......................................១២

រូបភាពទី២ ៖ មូលធនបរទេសនៃគម្រោងវិនិយោគដែលបានអនុម័តដោយ CDC........................១៥

រូបភាពទី៣ ៖ ការនាំចេញសំលៀកបំពាក់និង ស្បែកជើងនៅកម្ពុជាពីឆ្នាំ២០០០-២០១៨..............៣៦

រូបភាពទី៤ ៖ សកម្មភាពនៅរោងចក្ររបស់កម្មករ.................................................................៤១

រូបភាពទី៥ ៖ ចំណែកទីផ្សារនាំចេញផលិតផលសម្លៀកបំពាក់របស់កម្ពុជា ឆ្នាំ២០១២.................៤១

រូបភាពទី៦ ៖ ការនាំចេញផលិផលសម្លៀកបំពាក់ និងស្បែកជើងឆ្នាំ២០០០-២០១៦...................៤២

រូបភាពទី៧ ៖ ភាគរយនៃម្ចាស់រោងចក្រឧស្សាហកម្មកាត់ដេរនៅកម្ពុជា(២០១០).........................៤៣

រូបភាពទី៨ ៖ FDI លើវិស័យកាត់ដេរសំលៀកបំពាក់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤.................៤៤

រូបភាពទី៩ ៖ ប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជា និងប្រទេសផ្សេងៗសម្រាប់ឆ្នាំ២០២២......៥០

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា បើកអោយមានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិឡើងវិញនៅទសវត្សរ៍ឆ្នាំ១៩៨០ និង បើកអោយមានការវិនិយោគពីបរទេសនៅឆ្នាំ១៩៩៤។ ប្រទេសកម្ពុជា បានចូលជាសមាជិកអាស៊ាននៅឆ្នាំ ១៩៩៩ និងចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ ២០០៤។ ដៃគូនៃកិច្ចព្រមព្រៀងពានិជ្ជកម្ម ទ្វេភាគីរបស់ប្រទេសកម្ពុជា រួមមាន ចិន ឡាវ ស្វីស ហ្វីលីពីន បង់ក្លាដេស អាឡឺម៉ង់ ម៉ាឡេស៊ី អង់គ្លេស ថៃ ឥណ្ឌូនេស៊ី សិង្ហបូរីវៀតណាម ឥណ្ឌា យូហ្កាន់ដា ជប៉ុន កូរ៉េខាងជើង និងកូរ៉េខាងត្បូង។

ចាប់ពីឆ្នាំ ១៩៩៤ មកកម្ពុជាបានខិតខំជម្រុញលំហូរចូលនៃវិនិយោគផ្ទាល់ពីបរទេស និងបានខិតខំ បង្កើតគោលនយោបាយទាក់ទាញ អ្នកវិនិយោគពីបរទេសផងដែរ។ លើបរិស្ថាននៃការវិនិយោគនៅកម្ពុជា មានលក្ខណៈល្អប្រសើរ យើងសង្កេតឃើញថាលំហូរចូលវិនិយោគប្រទេសមួយចំនួនដូចជា ចិន ហុងកុង ម៉ាឡេស៊ី កូរ៉េខាងត្បូង អាមេរិក ថៃ និងប្រទេសផ្សេងៗទៀត បានធ្វើការវិនិយោគនៅកម្ពុជា ដែលការវិនិយោគ នៅកម្ពុជា ដែលការវិនិយោគនេះផ្តោតសំខាន់លើវិស័យ កាត់ដេរ ឧស្សាហកម្ម ទេសចរណ៍ និង វាយនភ័ណ្ឌ ជាដើម។ រួមជាមួយគ្នានេះដែរ តាមរយៈលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសមកក្នុងស្រុកកម្ពុជាបាន ទទួលផលប្រយោជន៍មួយចំនួន ដែលការទទួលនេះរួមមាន ការបង្កើតការងារ ដែលជាគោលបំណងចម្បង នៃ ការកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលកម្ពុជា។ ការវិនិយោគផ្ទាល់ពីបរទេសក៏ ផ្តល់មកនូវការពង្រឹង ធនធានមនុស្ស និងប្រសិទ្ធភាពកម្លាំងពលកម្ម ព្រមទាំងបង្កើនផលិតកម្ម និងការផ្ទេរនៃបច្ចេកវិទ្យាផងដែរ។ គោលដៅទាំងនេះជាអ្វីដែលកម្ពុជាកំពុងតែត្រូវការក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិនាពេលបច្ចុប្បន្ន និងពេលអនាគតផងដែរ។

វិស័យផលិតកម្មនៅកម្ពុជាត្រូវបានត្រួតត្រាដោយការផលិតសម្លៀកបំពាក់ និងស្បែកជើងដែលមាន ចំនួន ៧៤%[១] នៃការនាំចេញទំនិញប្រចាំឆ្នាំ។ យោងតាមអគ្គនាយកដ្ឋានគយ និងរដ្ឋាករក្រោមក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាន ឲ្យដឹង ថាព្រះរាជាណាចក្រកម្ពុជាបាននាំចេញ នូវផលិតផលសម្លៀកបំពាក់ និង ស្បែកជើងដែលមានតម្លៃជិត ៨ ពាន់លានដុល្លារក្នុងរយៈពេល ៩ ខែដំបូងនៃឆ្នាំ ២០១៩ ពោលគឺកើនឡើង ១៣ % បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៨ ។ ភាគច្រើននៃការនាំចេញ ទាំងនេះត្រូវបានដឹកនាំនៅ ទីផ្សារអឺរ៉ុបតែមួយសហរដ្ឋអាមេរិក និងជប៉ុន។ ការបន្តរីកចម្រើនគឺដោយសារគោលនយោបាយសេដ្ឋកិច្ច

[១] គេហទំព័រ អចលនទ្រព្យ , "*អំពីកម្ពុជា*" , www.realestate.com.kh

បើកទូលាយរបស់កម្ពុជា ទីតាំងភូមិសាស្ត្រអំណោយផល និងកម្លាំងពលកម្មដ៏សម្បូរបែប ដែលនៅតែបន្តទាក់ទាញការវិនិយោគនៅក្នុងវិស័យនេះ។

អាស្រ័យហេតុនេះហើយ បានជាកម្ពុជា នៅតែបន្តធ្វើសេរីភាវូបនីយកម្មគោលនយោបាយរបស់ខ្លួនជាបន្តបន្ទាប់ដើម្បីសម្របសម្រួល ជម្រុញ និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស ដើម្បីបង្កើតការងារដល់ប្រជាជន ជាពិសេសស្រទាប់យុវជន និងអភិវឌ្ឍន៍ប្រទេសដែលថាវិនិយោគជាក្បាលម៉ាស៊ីននៃកំនើនសេដ្ឋកិច្ចកម្ពុជា។

## ២. ចំណោទបញ្ហា

លំហូរនៃការវិនិយោគផ្ទាល់ពីបរទេស មកកម្ពុជាមានការកើនឡើង គួរឲ្យកត់សំគាល់នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសលើវិស័យវាយនភ័ណ្ឌកាត់ដេរ ដែលជាវិស័យឈានមុខក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា និងការជួយជាអត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាជនកម្ពុជា។ ជាមួយនឹងការកើនឡើងយ៉ាងឆាប់រហ័ស របស់ក្រុមហ៊ុនវិនិយោគទាំងនោះ យើងអាចមើលឃើញពីបញ្ហា និងការស្វែងយល់ដូចខាងក្រោម៖

ក. តើវិស័យវាយនភ័ណ្ឌនៅកម្ពុជាមានការវិវត្តយ៉ាងដូចម្តេចអំឡុងពេល ៥ ឆ្នាំចុងក្រោយ?

ខ. តើការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌ បានផ្តល់ផលចំណេញអ្វីខ្លះមកលើសេដ្ឋកិច្ចកម្ពុជា?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ ផលចំណេញនៃការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័-ណ្ឌនៅកម្ពុជានេះគឺក្នុងគោលបំណងសំខាន់មួយចំនួន ៣ ដូចខាងក្រោម ៖

ក. សិក្សាស្វែងយល់ពីស្ថានភាពនៃការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជា។

ខ. សិក្សាអំពី ផលចំណេញដែលការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌនៅប្រទេសកម្ពុជាផ្តល់មកលើលើប្រជាជនកម្ពុជា ក៏ដូចជាសេដ្ឋកិច្ចកម្ពុជា។

គ. សិក្សាស្វែងយល់អំពីដំណើរវិវត្តន៍នៃវិស័យវាយនភ័ណ្ឌនៅកម្ពុជា។

## ៤. ទំហំ និងដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ បានធ្វើការវិភាគ និងវាយតម្លៃទៅលើផលចំណេញការវិនិយោគផ្ទាល់ពីបរទេស លើវិស័យវាយនភ័ណ្ឌក្នុងប្រទេសកម្ពុជា ក្នុងអំឡុងជាង ៥ ឆ្នាំចុងក្រោយតែប៉ុណ្ណោះពោលគឺពីឆ្នាំ ២០១៧ ដល់បច្ចុប្បន្ន។ ពួកយើងធ្វើការស្រាវជ្រាវតែទៅលើ វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានអត្ថប្រយោជន៍ដូចខាងក្រោម៖

ក. អាចធ្វើជាឯកសារបំពេញបន្ថែមលើការសិក្សាលើទ្រឹស្តីលើការវិនិយោគផ្ទាល់ពីបរទេស (FDI)

ខ. អាចធ្វើជាឯកសារស្រាវជ្រាវសំរាប់ឱ្យនិស្សិតជំនាន់ក្រោយបានសិក្សាបន្ត

គ. អាចធ្វើជាឯកសារសម្រាប់ការដោះស្រាយបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងខ្លឹមសាររបស់ប្រធានបទ ចំពោះបញ្ហាដែលកើតមាន។

ឃ. អាចធ្វើជាព័ត៌មានសម្រាប់អ្នកវិនិយោគ ដែលធ្វើការសិក្សាទាក់ទងនឹងការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌនៅប្រទេសកម្ពុជា។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគម្រោង ផ្តោតសំខាន់លើទ្រឹស្តីដោយទាញភ្ជាប់ទៅជាមួយការវិវត្តនៃវិស័យវាយនភ័ណ្ឌ និងផលចំនេញដែលកម្ពុជាទទួលបានពីវិស័យមួយនេះ។ ការស្រាវជ្រាវនេះត្រូវបានចងក្រងឡើងតាមរយៈឯកសារទី២ (Secondary Data) ទិន្នន័យដែលយើងដកស្រង់ចេញពីឯកសារនានាដូចជាសៀវភៅដែលចេញពីអ្នកនិពន្ធផ្សេងៗ ទាំងភាសាខ្មែរ និងភាសាបរទេស គេហទំព័រតាមប្រព័ន្ធអ៊ីនធើណេត និងទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណៈការនិងដឹកជញ្ជូន អគ្គិសនីកម្ពុជា និងក្រសួងដែលពាក់ព័ន្ធមួយចំនួនទៀត។

ក្នុងការបកស្រាយបំភ្លឺការស្រាវជ្រាវត្រូវបានប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ (Qualitative Method) ដោយគ្រាន់តែធ្វើការពណ៌នា បកស្រាយ និងពន្យល់ពីទិន្នន័យដែលមានស្រាប់។ រាល់ទិន្នន័យដែលប្រមូលបានត្រូវបានរៀបជាស្ថិតិ ពណ៌នា ដើម្បីឱ្យមានភាពងាយស្រួលយល់។ បន្ទាប់ពីធ្វើការចងក្រង ជាខ្លឹមសារអត្ថបទ ពួកយើងបានធ្វើ ការវិភាគ និងវាយតម្លៃលើប្រាប់ចំនូលរបស់ប្រជាជនកម្ពុជា ក៏ដូចជា ទំហំការងាររបស់ប្រជាជនកម្ពុជា រួមទាំងប្រាក់ឈ្នួលអប្បបរមាដែលប្រជាជនកម្ពុជាទទួលបានពីវិស័យវាយនភ័ណ្ឌ ដើម្បីចេញជាលទ្ធផលស្រាវជ្រាវនៃផលចំណេញលើការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភណ្ឌនៅកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណានេះ ត្រូវបានចងក្រងឡើងជារចនាសម្ព័ន្ធ ដែលត្រូវបានបែងចែកជាបួនជំពូកធំៗ រួមមាន៖

ជំពូកទី ១៖ ក្នុងជំពូកនេះ យើងធ្វើការសិក្សាអំពីទស្សនៈទានផ្សេងៗ ទ្រឹស្តី និយមន័យ ប្រភេទទម្រង់ និងឥទ្ធិពលនៃការវិនិយោគផ្ទាល់ពីបរទេស។

ជំពូកទី ២៖ ក្នុងជំពូកនេះ យើងធ្វើការសិក្សាអំពីស្ថានភាពរបស់វិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជា និងកត្តាទាំងឡាយដែលទាក់ទាញវិនិយោគផ្ទាក់ពីបរទេស។

ជំពូកទី ៣៖ ក្នុងជំពូកនេះ យើងធ្វើការសិក្សាអំពីស្ថានភាពរបស់វិស័យវាយនភ័ណ្ឌនៅក្នុងប្រទេសកម្ពុជាជាមួយនិងការវិនិយោគផ្ទាល់ពីបរទេសមកលើវិស័យនេះ។

ជំពូកទី ៤៖ ក្នុងជំពូកនេះ យើងធ្វើការសិក្សាអំពីការវិភាគ និង បកស្រាយពីលទ្ធផលនៃការស្រាវជ្រាវ ពីផលចំណេញនៃការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌនៅកម្ពុជា និងការស្វែងរកដំណោះស្រាយ។

ចុងក្រោយ គឺសេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្សេងៗ ដើម្បីសរុបការសិក្សាស្រាវជ្រាវនៃសារណារមួយនេះ។

# ជំពូកទី ១

# រំលឹកទ្រឹស្តី

# ជំពូកទី ១
# រំលឹកទ្រឹស្តី

## ១.១. ទស្សនៈទាននៃការវិនិយោគ

មុននឹងស្វែងយល់ពីការវិនិយោគផ្ទាល់ពីបរទេស យើងនឹងធ្វើការសិក្សាស្វែងយល់ថាតើអ្វីទៅគឺជាការវិនិយោគជាមុនសិន? អ្វីទៅជាកត្តាកំណត់កវិនិយោគ?

### ១.១.១. និយមន័យ

មានសេដ្ឋកិច្ចវិទូ និងពាណិជ្ជករជាច្រើនបានយល់ឃើញផ្សេងៗគ្នាចំពោះនិយមន័យរបស់ការវិនិយោគ។ ទោះជាបែបនេះក្តី ទស្សនៈទាំងនោះត្រូវបានគេវាយតម្លៃថាត្រឹមត្រូវទាំងអស់។

**តាមន័យម៉ាក្រូសេដ្ឋកិច្ច៖** ការវិនិយោគ គឺជាការទិញទ្រព្យរបស់ សហគ្រាស ដើម្បីយកទៅផលិតទ្រព្យដទៃទៀតដូចជា ទ្រព្យឬទំនិញប្រើប្រាស់ជាដើម។ ការធ្វើវិនិយោគ គឺជាការធ្វើឱ្យមូលធនរបស់សហគ្រាសកាន់តែពង្រីកថែមទៀត[២]។ ជាទូទៅវិនិយោគមានពីរប្រភេទ៖

ក. វិនិយោគលើមូលធន ៖ ដូចជា ទិញអាគារ និងម៉ាស៊ីនជាដើម។

ខ. វិនិយោគលើស្តុក៖ ការទិញភាគហ៊ុន ជាការវិនិយោគលើម៉ាស៊ីន។

**តាមន័យអាជីវកម្ម៖** ការសម្រេចចិត្តក្នុងការផ្លាស់ប្តូរទ្រង់ទ្រាយនៃមូលនិធិទៅកាន់ ឬគ្រប់គ្រងនូវទ្រព្យសកម្មមួយ ឬច្រើនក្នុងអំឡុងពេលមួយ ដើម្បីផ្តល់ចំនេញក្នុងពេលអនាគតដែលទ្រព្យសកម្មនោះរួមមានសញ្ញាប័ណ្ណ (Bond) និងភាគហ៊ុន (Stock)។

ដូចនេះ នៅក្នុងការស្រាវជ្រាវនេះ យើងនឹងធ្វើការសិក្សាដោយផ្តោតសំខាន់លើវិនិយោគតាមទ្រឹស្តីរបស់ម៉ាក្រូសេដ្ឋកិច្ច។

### ១.១.២ កត្តាកំណត់វិនិយោគ

វាជាការពិតណាស់ដែលថា អ្នកវិនិយោគចាយវាយទៅលើទំនិញមូលធន (Capital Goods) ដោយសារតែគេសង្ឃឹមថានឹងទទួលបានប្រាក់ចំណេញ។ ជារួមកត្តាដែលកំណត់វិនិយោគអាចនិយាយបានថា គឺទៅលើប្រាក់ចំណេញ ប៉ុន្តែកត្តាដែលកំណត់នូវប្រាក់ចំណេញ មានបីសំខាន់ៗគឺ ចំណូល ចំណាយ និងការរំពឹងទុករបស់អ្នកវិនិយោគ[៣]។

---

[២] សាស្ត្រាចារ្យ ម៉ម ចរិយារុធ, "*ម៉ាក្រូសេដ្ឋកិច្ច*" (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៣), ១៩។

[៣] Samuelson និង Nordhaus, "*Fundamental of Investment [មូលដ្ឋានគ្រឹះនៃការវិនិយោគ]*", (២០០១), ៧១។

**ចំណូល៖** ក្រុមហ៊ុន ឬសហគ្រាសមួយអាចទទួលបានចំណូលច្រើន នៅពេលដែលការផលិតនិងតម្រូវការច្រើន នោះលុះត្រាតែចំនួនអ្នកមានតម្រូវការមានចំណូលច្រើនផងដែរ ដែលមានន័យថា ផលិតផលក្នុងស្រុកសរុប (GDP) គឺជាកត្តាមួយដែលកំណត់វិនិយោគ។ ប្រសិនបើក្នុងស្ថានភាពសេដ្ឋកិច្ចមានការធ្លាក់ចុះ នោះនាំឱ្យវិនិយោគធ្លាក់ចុះផងដែរ និងច្រាសមកវិញ។ នោះយើងអាចនិយាយថាវិនិយោគមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងវដ្តសេដ្ឋកិច្ច។

**ចំណាយ៖** ការចំណាយទៅលើវិនិយោគ ត្រូវបានគេចាត់ទុកថាមានលក្ខណៈស្មុគស្មាញក្នុងការប៉ាន់ស្មាន ពីព្រោះវាត្រូវបានប្រើប្រាស់ក្នុងរយៈពេលយូរអង្វែង។ ដូចនេះក្នុងរយៈពេលយូរនោះថ្លៃដើមសម្រាប់ទំនិញប្រើប្រាស់ វាមិនត្រឹមតែថ្លៃដើមមូលធនប៉ុណ្ណោះទេ តែវាក៏ត្រូវគិតផងដែរចំពោះពន្ធ និងអត្រាការប្រាក់ ជាដើម។ នោះការប្រែប្រួលការប្រាក់ វាពិតមានឥទ្ធិពលទៅលើថ្លដើម និងចំណូលផងដែរ។ ការប្រែប្រួលពន្ធលើប្រាក់ចំណូល និងចំណាយរបស់អ្នកវិនិយោគ ក៏ធ្វើឱ្យមានឥទ្ធពលដល់ការវិនិយោគផងដែរ។

## ១.២. ការវិនិយោគពីបរទេស

ដើម្បីងាយស្រួលក្នុងការស្វែងយល់ និងជាមូលដ្ឋានក្នុងដំណើរការសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងអាចវែកញែកបានត្រឹមត្រូវនោះ យើងគួរស្វែងយល់និយមន័យនៃពាក្យគន្លឹះនិង ទ្រឹស្ដីមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទជាមុនសិន។

### ១.២.១. និយមន័យនៃការវិនិយោគផ្ទាល់ពីបរទេស

ការវិនិយោគពីបរទេស ជាការវិនិយោគធ្វើពាណិជ្ជកម្ម របស់ប្រទេសមួយទៅកាន់ប្រទេសក្រៅមួយផ្សេងទៀត។ ការវិនិយោគបរទេសពាក់ព័ន្ធនឹងការផ្ទេរទ្រព្យសម្បត្តិអរូបិយ ទៅកាន់ប្រទេសមួយផ្សេងទៀត សម្រាប់គោលបំណងប្រើប្រាស់ក្នុងប្រទេសនោះ ដើម្បីបង្កើនទ្រព្យសម្បត្តិ ក្រោមការគ្រប់គ្រង់ទាំងស្រុងឬដោយផ្នែកនៃម្ចាស់ទ្រព្យសម្បត្តិ។ វាខុសគ្នាពីការវិនិយោគផលប័ត្រ ដែលជាចលនានៃលំហូរសាច់ប្រាក់សម្រាប់គោលបំណងនៃការទិញភាគហ៊ុននៅក្នុងក្រុមហ៊ុនមួយដែលបានបង្កើត ឬដំណើរការនៅក្នុងប្រទេសផ្សេងទៀត។ កត្តាមួយទៀតដែលកំណត់ដោយផ្ទាល់ពីបរទេស ការវិនិយោគក្រៅពីការវិនិយោគផលប័ត្រ គឺជាការវិនិយោគផ្ទាល់ពីបរទេស ដែលភាគច្រើនធ្វើឡើងដោយសាជីវកម្មពហុជាតិ (MNC)។

## ១.៣. ទម្រង់នៃការវិនិយោគផ្ទាល់ពីបរទេស

ការវិនិយោគផ្ទាល់ពីបរទេសកើតឡើង នៅពេលដែលសហគ្រាសមួយធ្វើការវិនិយោគផ្ទាល់ ដើម្បីផលិតផលិតផល ឬចែកចាយផលិតផលរបស់ខ្លួន នៅក្នុងប្រទេសមួយ ឬច្រើនដទៃទៀតក្រៅពីប្រទេសដើមកំណើតរបស់ខ្លួន ឬក៏និយាយបានម្យ៉ាងទៀតថា គឺជាការវិនិយោគក្នុងប្រទេសមួយដោយជនជាតិនៃប្រទេស

ដទៃទៀត[៤]។ ការវិនិយោគផ្ទាល់ពីបរទេស មានសារៈសំខាន់ណាស់ក្នុងការបែងចែករវាងលំហូរ និងស្តុកនៃការវិនិយោគផ្ទាល់ពីបរទេស។

ជាទូទៅ ការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានកើតឡើងពីការបញ្ជ្រាតចូលទៅក្នុងទីផ្សាររបស់ប្រទេសមួយក្នុងរូបភាព២យ៉ាង៖

**ក្រុមហ៊ុនសាខា** (**Greenfield Investment**)៖ ជាការបង្កើតប្រតិបត្តិការថ្មីទាំងស្រុងរបស់ប្រទេសមួយ។ ភាគច្រើនវាកើតឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

**ក្រុមហ៊ុនរួមទុន** (**Merger Investment**)៖ ក្រុមហ៊ុនសាជីវកម្មធ្វើការរួមចំណែក បើកការវិនិយោគនៅក្នុងប្រទេសមួយ ជាមួយដៃគូក្នុងស្រុកទោះបីជារដ្ឋ ឬឯកជន ឬទិញយកក្រុមហ៊ុនក្នុងស្រុកធ្វើជារបស់ខ្លួនតែម្តង។ ភាគច្រើនយើងប្រទះឃើញនៅក្នុងប្រទេសអភិវឌ្ឍន៍។

វិនិយោគផ្ទាល់បរទេសនៅតែធ្វើការចូលទុនដោយសារមូលហេតុ (១) ក្រុមហ៊ុនរួមទុនមានភាពងាយស្រួល និងរហ័សនៅក្នុងការប្រតិបត្តិការសាកល្បងជាមួយនឹងតម្រូវការមូលធន និងធ្វើអោយក្រុមហ៊ុនអាចរីករាលដាលរហ័សក្នុងពិភពលោក។ (២) ការរួមទុនអាចត្រូវបានបង្កើនប្រសិទ្ធិភាពដោយការផ្ទេរនូវបច្ចេកវិទ្យា និងជំនាញផ្សេងៗ។ (៣) ប្រទេសដែលទទួលការវិនិយោគអាចតម្រូវអោយការវិនិយោគផ្ទាល់ពីបរទេសចូលរួមជាដៃគូជាមួយវិនិយោគក្នុងស្រុក។

## ១.៤. គោលបំណងនៃការវិនិយោគផ្ទាល់ពីបរទេស

ការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានមើលឃើញថាធ្វើឡើងក្នុងគោលបំណងផ្សេងៗគ្នាដែលក្នុងនោះរួមមាន ការវិនោយោគស្វែងរកទីផ្សារ ការវិនិយោគដើម្បីនាំចេញ និងការវិនិយោគស្វែងរកធនធាន។[៥]

### ១.៤.១.ការវិនិយោគស្វែងរកទីផ្សារ

ការវិនិយោគស្វែងរកទីផ្សារ គឺជាការិនិយោគពីបរទេសមួយបែបRajnessh Narular និងលោក Jonh Dunning បានពន្យល់ថាការវិនិយោគបែបនេះកើតឡើង នៅពេលដែលក្រុមហ៊ុនធ្វើអន្តរតូបនីយកម្មនៅក្នុងប្រទេសមួយ ដើម្បីផ្គត់ផ្គង់ទំនិញ និងសេវាកម្មនៅលើទីផ្សារប្រទេសនោះ ក្នុងគោលបំណងដើម្បីចាក់ឬសក្នុងទីផ្សារ និងប្រកួតប្រជែងក្នុងទីផ្សារ និងដើម្បីឆក់យកឱកាស Production Economies_of Scale។ ដើម្បីទាញយកប្រយោជន៍ទាំងពីរនេះ គឺត្រូវទាមទារនូវទីផ្សារដែលមានទំហំប្រជាជនធំ ឬទីផ្សារដែលមានទំហំសេដ្ឋកិច្ចធំ ដើម្បីទ្រទ្រង់ទំហំវិនិយោគដែលបានបោះទន់។ ដូច្នេះការវិនិយោគផ្ទាល់ពីបរទេសដើម្បីស្វែង

[៤] Charles W. L. Hill, "*International business Competing in the Global Marketplace*", Fifth Edition, (២០០៥), ២២១។

[៥] John Dunning និង Rajneesh Narula, "*Foreign Direct Investment and Governments*" , ១៩៩៦

រកទីផ្សារ គឺជាការស្វែងរកទីតាំងភូមិសាស្ត្រ នៅកណ្តាលដែលងាយស្រួលក្នុងការចូលទីផ្សារ។

យ៉ាងណាមិញលោក Narula និងលោក Dunning បានកំណត់ថា ការវិនិយោគស្វករកទីផ្សារត្រូវបានលើកទឹកចិត្ត ប្រសិនបើប្រទេសដើមកំណើតរបស់ក្រុមហ៊ុនជាប់មានរបាំងពាណិជ្ជកម្មណាមួយនោះ ឬប្រទេសទទួលការវិនិយោគបានបើកទូលាយផ្តល់នូវការស្វាគមន៍ និងបានផ្តល់ឱកាស ក្នុងការវិនិយោគជាមួយ និងការលើកទឹកចិត្តផ្សេងៗ ដើម្បីធានានូវភាពរីកចម្រើនលូតលាស់។

នៅពេលដែលគេនិយាយពីការវិនិយោគស្វែងរកទីផ្សាររបស់ សាជីវកម្មពហុជាតិនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការជ្រើសរើសទីតាំងវិនិយោគ គឺជាទូទៅត្រូវបានពន្យល់ដោយឱកាសផលិតកម្មនៅក្នុងប្រទេសដែលទទួលការវិនិយោគដោយមើលឃើញពីតម្រូវការក្នុងស្រុក និងក្រៅស្រុករបស់ប្រទេសនោះ។

### ១.៤.២.ការវិនិយោគក្នុងការនាំចេញ

ការវិនិយោគដើម្បីនាំចេញ ជាទូទៅត្រូវបានពន្យល់ដោយលោក Reuder ដែលលើកឡើងថាការវិនិយោគជាប្រភេទវិនិយោគដែលស្វែងរកទីផ្សារដែលមានកត្តាពលកម្មថោក និងសំបូរបែបដើម្បីងាយស្រួលក្នុងការផលិត ទំនិញសម្រេចដែលមានតម្លៃទាប ហើយផ្តល់ភាពងាយស្រួលក្នុងការប្រកួតប្រជែងនាំចេញទំនិញក្នុងទីផ្សារអន្តរជាតិ។ ម្យ៉ាងវិញទៀត ការវិនិយោគសម្រាប់ការនាំចេញ ជារឿយៗ គេមិនសំដៅលើទីផ្សារក្នុងប្រទេស ដែលគេធ្វើការវិនិយោគនោះទេ ប៉ុន្តែគេសង្កត់ធ្ងន់ទៅលើទីផ្សារខាងក្រៅ និងជុំវិញ ព្រមទាំងទំនាក់ទំនងជាមួយប្រទេសដែលទទួលវិនិយោគនោះ។ ជាទូទៅតម្រូវការក្នុងស្រុក របស់ប្រទេសកំពុងអភិវឌ្ឍន៍មានទំហំតូច តែវាមិនមែនជាបញ្ហាដល់ការវិនិយោគផ្ទាល់ពីបរទេសនោះទេ។ ពេលប្រទេសទទួលវិនិយោគមានការបើកចំហរ ទីផ្សារលំហូរ FDI ក្នុងប្រទេសនោះផ្តោតទៅលើ ការធ្វើពាណិជ្ជកម្មជាមួយដៃគូរ។ ដូច្នេះប្រទេសដែលទទួលការវិនិយោគ គឺតម្រូវអោយមានទំនាក់ទំនងអន្តរជាតិ។

### ១.៤.៣.ការវិនិយោគស្វែងរកមូលធន

ការវិនិយោគស្វែងរកមូលធន គឺជាការវិនិយោគដែលផ្តោតសំខាន់លើភាពសំបូរបែប វត្ថុធាតុដើម កម្លាំងពលកម្ម និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅក្នុងប្រទេសម្ចាស់ផ្ទះ បើយោងតាមលោក John Dunning បានបែងចែកក្រុមហ៊ុនសាជីវកម្មជា ៣ ប្រភេទ ៖

ក.ជាក្រុមស្វែងរកធនធានរូបវ័ន្តមានដូចជា៖ ប្រេង រ៉ែ វត្ថុធាតុដើម និងផលិតផលកសិកម្ម

ខ.ជាក្រុមស្វែងរកកម្លាំងពលកម្មតម្លៃថោកជាងទៅគឺជា កម្លាំងពលកម្មគ្មានជំនាញ

គ.ជាក្រុមស្វែងរកនូវបច្ចេកទេសនៃការគ្រប់គ្រងឬជំនាញផ្សព្វផ្សាយទីផ្សារផ្សេងៗ។

ការវិនិយោគស្វែងរកមូលធ ក៏មានជាការផ្តល់ជាវគ្គបង្រៀនខ្លីៗ បង្កើតនូវឱកាសសម្រាប់បុគ្គលិក ព្រមទាំងជួយកាត់បន្ថយការប្រើប្រាស់កម្លាំងពលកម្ម និងមូលធនមិនចំគោលដៅ។

ទោះជាយ៉ាងណាក៏ដោយ ការវិនិយោគផ្ទាល់ពីបរទេសបែបនេះ អាចនឹងធ្វើអោយមានភាពសឹករិចរិលមូលធន។ បើតាមលោក Rajneeh Narula និងលោក Dunning លើកឡើងថាក្នុងតំបន់ដែលមានលទ្ធភាព ផ្គត់ផ្គង់នូវមូលធនកម្រ រដ្ឋាភិបាលតំបន់នោះ មានលទ្ធភាពខ្ពស់ក្នុងការចចារ ហើយនៅពេលដែលមានការចំណាយក្នុងការទាក់ទាញ យកធនធានកម្រនោះ មានតែលើកិច្ចសន្យាជាមួយរដ្ឋាភិបាលនិងចំណាយលើការរុករកនោះ ក្រុមហ៊ុនវិនិយោគពីបរទេសនឹងទទួលបាននូវផលចំណេញក្នុងកំរិតខ្ពស់។ រីឯចំពោះប្រទេសម្ចាស់ផ្ទះក៏បានទទួលនូវផលចំណេញពីការវិនិយោគនេះដែរ ពោលគឺចំណេញផ្នែកបច្ចេកទេសភាពមានការងារ បូករួមនិងការទាក់ទាញធនធានទាំងនោះ មកប្រើប្រាស់ ព្រោះបើគ្មានការវិនិយោគពីបរទេសធនធាននោះនឹងមិនសូវបានប្រើប្រាស់នោះទេ។ ក្នុងករណីការវិនិយោគស្វែងរកធនធាន ឬពលកម្មក្នុងតម្លៃថោក ភាគច្រើនការវិនិយោគចេញពីប្រទេសមានកម្លាំងពលកម្មថ្លៃ។ ដូចនេះ ការវិនិយោគនៅក្រៅប្រទេសគឺក្នុងគោលបំណងកាត់បន្ថយថ្លៃដើមក្នុងកត្តាផលិតកម្ម។

## ១.៥. កត្តាដលជះឥទ្ធិពលដល់ការវិនិយោគផ្ទាល់ពីបរទេស

ជាទូទៅស្ថានភាពសេដ្ឋកិច្ចរួមមាន ទំហំទីផ្សារ ថ្លៃដើមពលកម្ម អត្រាការប្រាក់ និងអត្រាប្តូរប្រាក់ដែលមានឥទ្ធិពលទៅលើ FDI ។

### ១.៥.១. ទំហំទីផ្សារ

ជាទូទៅទំហំទីផ្សារត្រូវបានកំនត់ទៅលើចំនួនប្រជាជន និងចំណូលសរុបរបស់ប្រទេសមួយ។ នៅពេលដែលទំហំទីផ្សារកាន់តែធំ នោះសកម្មភាពផលិត បែងចែក និង ប្រើប្រាស់កាន់តែច្រើនផងដែរ នៅពេលដែលប្រជាជនមានតម្រូវការកាន់តែច្រើន នោះមានន័យថាចំណូលក្នុងម្នាក់ៗកាន់តែច្រើន និង មានន័យថាទីផ្សារមានសកម្មភាពល្អផងដែរ។ ដូច្នេះវានឹងធ្វើអោយមានការវិនិយោគ របស់សហគ្រាសបោះជំហានចូលទៅក្នុង ទីផ្សារដែលពួកគេសម្លឹងមើលទៅលើសក្តានុពលៈ

ក. ការវិនិយោគលើទីផ្សារ ដែលមានតម្រូវការខ្ពស់ ដែលនាំអោយទទួលបានប្រាក់ចំនេញពីការវិនិយោគរបស់ខ្លួន។

ខ. ការវិនិយោគផ្ទាល់ពីបរទេស មាននិន្នាការវិនិយោគលើប្រទេសដែលមានឧស្សាហកម្មលូតលាស់ ព្រោះវិស័យឧស្សាហកម្មជាប្រភពនៃការងារ និងប្រាក់ចំនូលរបស់ពលកម្ម។ ហេតុដូចនេះបានជាកម្ពុជាអនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ ដើម្បីការបង្កើតការងារ និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស។

### ១.៥.២. ថ្លៃដើមពលកម្ម

តម្លៃពលកម្ម ពិតជាមានទំនាក់ទំនងជាមួយនឹងការវិនិយោគផ្ទាល់ពីបរទេស។ ថ្លៃដើមពលកម្មជាកត្តាមួយដ៏សំខាន់ក្នុងដំណើរការផលិតកម្ម ពោលគឺ នៅពេលដែលប្រទេសមួយមានថ្លៃពលកម្មថោកជាងប្រទេសដ៏ទៃទៀតនោះ អាចទាក់ទាញវិនិយោគផ្ទាល់ពីបទេសមកវិនិយោគក្នុងប្រទេសរបស់ខ្លួន។ កាលណាតម្លៃពលកម្មថោក នោះវាធ្វើអោយថ្លៃដើមនៃផលិតកម្មមានតម្លៃថោកដែលធ្វើអោយមានឱកាសក្នុងការប្រកួតប្រជែងជាមួយនឹងដៃគូក្នុងទីផ្សារយ៉ាងងាយស្រួល។

### ១.៥.៣. អត្រាការប្រាក់

អត្រាការប្រាក់ជាទូទៅមានទំនាក់ទនងជាមួយនឹងការវិនិយោគយ៉ាងស្និទ្ធ។ ប្រសិនបើអត្រាការប្រាក់កើនឡើង នោះវាធ្វើអោយការវិនិយោគធ្លាក់ចុះ ។ ប្រសិនបើអត្រាការប្រាក់ធ្លាក់ចុះ នោះនាំអោយការវិនិយោគកើនឡើង ។

### ១.៥.៤. អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់ គឺជាកត្តាមួយដ៏សំខាន់ផងដែរ ដែលវិនិយោគផ្ទាល់ពីបរទេសសម្លឹងមើល។ អត្រាប្តូរប្រាក់មានតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ នោះវាក៏មានឥទ្ធិពលទៅលើការវិនិយោគផ្ទាល់ពីបរទេស ដែលវាអាចពន្យល់បានក្នុងពីរករណីៈ

ក. នៅពេលដែលរូបិយវត្ថុរបស់ប្រទេសមួយមានការកើនឡើងធៀបជាមួយនឹងប្រទេសដែលមកវិនិយោគក្នុងប្រទេសរបស់ខ្លួន នោះវាធ្វើអោយមានការកើនឡើងនូវថ្លៃដើមក្នុងការវិនិយោគ។ ដូច្នេះ ការវិនិយោគផ្ទាល់ពីបរទេសនោះ ត្រូវបានហូរទៅប្រទេស ដែលមានរូបិយវត្ថុដែលមានតម្លៃថោកជាង។

ខ. ការកើនឡើងតម្លៃរូបិយវត្ថុ ប្រទេសក្នុងស្រុករបស់ខ្លួនធ្វើអោយទំនិញក្នុងស្រុកមានតម្លៃថ្លៃជាងបើប្រៀបធៀបជាមួយរូបិយវត្ថុបរទេស។ ហេតុដូចនេះ វាធ្វើអោយមានការនាំចេញទំនិញពីបរទេសទៅកាន់ប្រទេសខ្លួន ដែលមានការប្រកួតប្រជែងតិចតួច ។ ដូច្នេះ វាធ្វើអោយអ្នកវិនិយោគក្នុងស្រុកទៅវិនិយោគក្រៅប្រទេសមានការកើនឡើង។

### ១.៥.៥. ស្ថានភាពនយោបាយ

រដ្ឋមានតួនាទីសំខាន់ ក្នុងការធានាស្ថេរភាពនយោបាយ សុខសន្តិភាព និងសណ្តាប់ធ្នាប់សង្គម។ បើប្រទេសមួយគ្មានស្ថេរភាពនយោបាយទេនោះ ទោះបីជាប្រទេសនោះមានលក្ខណៈអំណោយផលដល់វិនិយោគយ៉ាងណាក៏ដោយ ក៏ពុំមានអ្នកវិនិយោគណាសម្រេចចិត្តវិនិយោគក្នុងប្រទេសដែលមានហានិភ័យខ្ពស់ក្នុងការធ្វើអោយខាតបង់មូលធនទាំងស្រុងរបស់ពួកគេនោះដែរ។ ដូច្នេះ រដ្ឋមានតួនាទីសំខាន់ណាស់ក្នុងការធានានូវស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងធានាលើច្បាប់ការពារវិនិយោគដ៏ត្រឹមត្រូវដល់វិនិយោគិនទាំងអស់។

# ជំពូកទី ២
# ស្ថានភាពទូទៅនៃ
# ការវិនិយោគផ្ទាល់ពីបរទេស
# នៅប្រទេសកម្ពុជា

# ជំពូកទី ២
# ស្ថានភាពទូទៅនៃការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជា

## ២.១. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

រំលឹកទៅអតីតកាលនៅទសវត្សរ៍ទី ៦០ ប្រទេសកម្ពុជាធ្លាប់ត្រូវបានគេចាត់ទុកថាជាប្រទេសដែលមានខឿនសេដ្ឋកិច្ចល្អ និងការអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស បើប្រៀបធៀបនឹងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍។ ប៉ុន្តែដោយសារសង្គ្រាមរាំរ៉ៃរាប់ទសវត្សរ៍ បានធ្វើអោយកម្ពុជានាពេលបច្ចុប្បន្នត្រូវបានចាត់ទុកជាប្រទេសកំពុងអភិវឌ្ឍមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍដទៃទៀតក្នុងពិភពលោក។

ពីរបបមួយទៅរបបមួយ រចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជា បានផ្លាស់ប្ដូរជាបន្តបន្ទាប់។ ការធ្វើនូវសេរីភាវូបនីយកម្ម ដើម្បីឈានឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសេរីបានចាប់ផ្ដើមពីឆ្នាំ១៩៨៥ ហើយបានជំរុញនូវដំណើរនេះអោយកាន់តែមានសភាពខ្លាំងនៅក្នុងកំឡុងឆ្នាំ ១៩៨៩ មក។

បន្ទាប់ពីមានសេដ្ឋកិច្ចដ៏រឹងមាំជាងពីរទសវត្ស ប្រទេសកម្ពុជាស្ថិតក្នុងប្រទេសដែលមានប្រាក់ចំណូលមធ្យមកំរិតទាប[៦] ក្នុងឆ្នាំ២០១៥ ជាមួយនឹងប្រាក់ចំណូលជាតិសរុប (GNI) សំរាប់មនុស្សម្នាក់កើតដល់ ១,០៧០ ដុល្លារអាមេរិក ការនាំចេញសម្លៀកបំពាក់ និងវិស័យទេសចរណ៍បានរក្សាកំណើនជាមធ្យម ៧,៦% ក្នុងឆ្នាំ ១៩៩៤ ដល់ ឆ្នាំ ២០១៥ ដែលឈរនៅលំដាប់ទី ៦ នៅលើពិភពលោក។ កំណើនសេដ្ឋកិច្ចបានកើនឡើង ៧% នៅឆ្នាំ ២០១៧ ។ គេរំពឹងក្នុងឆ្នាំ២០១៨ កម្ពុជាអាចនិងរក្សាកំណើន ៧% ឬលើសពីនេះទៀតព្រោះការងើបឡើង វិញនៃវិស័យទេសចរណ៍ រួមមួយនឹងការពង្រឹងសារពើពន្ធ និងជួយបំពេញលើការថយចុះលើផ្នែកនាំចេញសម្លៀកបំពាក់និងកំណើនផ្នែកសំណង់។

ភាពក្រីក្របន្តធ្លាក់ចុះក្នុងប្រទេសកម្ពុជា ទោះបីជាការធ្លាក់ចុះនេះមានសភាពយឺតជាងក្នុងឆ្នាំកន្លងទៅក្តី។ នៅក្នុងឆ្នាំ ២០១៤ អត្រាភាពក្រីក្រមាន ១៣,៥% បើធៀបនឹងឆ្នាំ ២០០៧ មាន ៤៧.៨% ។ ប្រហែល ៩០%នៃប្រជាពលរដ្ឋក្រីក្រ រស់នៅក្នុងតំបន់ជនបទ ។ ខណៈដែលកម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍន៍សហវត្សរ៍ ដោយបានកាត់បន្ថយអត្រាភាពក្រីក្របាន ៥០% ក្នុងឆ្នាំ២០១៩។

ទោះបីជាសម្រេចបាន សមិទ្ធិផលទាំងនេះក្តី ក៏កម្ពុជានៅតែមានបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍន៍លើគ្រប់វិស័យ រដ្ឋបាលដីធ្លី និងការគ្រប់គ្រង់ធនធានធម្មជាតិ បរិស្ថាន និងអភិបាលកិច្ចល្អ ប្រកបដោយចីរភាព។ ការបោះជំហ៊ានទៅមុខ និងជោគជ័យនៃការដោះស្រាយបញ្ហាប្រឈមទាំងនេះ មិនមែនពឹងផ្អែកតែទៅលើការថែរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង សម្រាប់ការនាំចេញប៉ុណ្ណោះទេ ប៉ុន្តែ

[៦]អង្គការទិន្នន័យអំពីការអភិវឌ្ឍ, "*ចំណូលជាតិសរុប (GNI)*" , www. opendevelopmentcambodia.com

ថែមទាំងផ្អែកលើការកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការចំណាយសាធារណៈដែលមានប្រសិទ្ធភាពជាងមុនដែលឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ។

ប្រទេសកម្ពុជា គឺជាសមាជិករបស់ អាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ហើយអនុវត្តការពេញចិត្តរបស់ MFN និង GSP ជាមួយនឹងប្រទេសផ្សេងទៀត ជាពិសេស សហរដ្ឋអាមេរិក (US) និងសហភាពអឺរ៉ុប (EU) ជាដើម។ ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា (GDP)

ប្រទេសកម្ពុជាជាប្រទេសមានចំណូលមធ្យមទាប ជាមួយនឹងការលូតលាស់សេដ្ឋកិច្ចយ៉ាងលឿនដែលបានរក្សាអត្រាកំណើនប្រមាណ ៧ ភាគរយចាប់តាំងពីឆ្នាំ ២០១១។ យោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី សេដ្ឋកិច្ចបានធ្លាក់ចុះ ៣,១ ភាគរយនៅឆ្នាំ ២០២០ ដោយសារជំងឺឆ្លងកូវីដ-១៩។ សេដ្ឋកិច្ចត្រូវបានព្យាករណ៍ថានឹងកើនឡើង ៤ ភាគរយនៅឆ្នាំ ២០២១ និង ៥,៥ ភាគរយនៅឆ្នាំ ២០២២ ដោយសារការឆ្លើយតបរហ័សរបស់រដ្ឋាភិបាលចំពោះវិបត្តិ និងការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាដោយជំរុញតម្រូវការនាំចេញ។ ទោះបីជាគ្រប់វិស័យទាំងអស់នឹងមិនទទួលបានអត្ថប្រយោជន៍ស្មើភាពគ្នា ក៏ប៉ុន្តែវានឹងជួយបង្កើនប្រាក់ចំណូលគ្រួសារទាំងមូលអោយមានកំណើន។

រូបភាពទី១៖ អត្រាកំណើន GDP របស់កម្ពុជាជាប្រចាំឆ្នាំតាមវិស័យ




ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២០

ប្រភព៖ ទាញពីទិន្នន័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២០

យោងតាមទិន្នន័យតាមក្រាបខាងលើបានបង្ហាញថា បើទោះជាប្រឈមនូវបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាមួយចំនួនដូចជា ភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិន, ភាពមិន

ប្រាកដប្រជានៃការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប, ការឡើងកំដៅនៃភូមិសាស្ត្រនយោបាយ និងការបន្តនិន្នាការគោលនយោបាយគាំពារនិយមជាដើម, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០១៩ នៅតែបន្តសម្រេចបានកំណើនល្អក្នុងអត្រា ៧,១% ។ កំណើនល្អនេះត្រូវបានគាំទ្រដោយសារការបន្តរីកចម្រើននៃវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ជាពិសេសអនុវិស័យសំណង់, អនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ និងអនុវិស័យលក់ដុំ-រាយ ។ ទោះជាយ៉ាងនេះក្តី កម្ពុជានៅបន្តជួបប្រទះបញ្ហាប្រឈមជារចនាសម្ព័ន្ធសំខាន់ៗចំនួន ២ គឺ ភាពប្រកួតប្រជែងនៅមានកម្រិត និងភាពយឺតយ៉ាវនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ។ ជាការឆ្លើយតបរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគោលនយោបាយផ្សេងៗ មានដូចជា៖ ការជួយសម្រួលក្នុងការកាត់បន្ថយថ្លៃដើម, ពេលវេលា និងបង្កើនភាពងាយស្រួលដល់ការធ្វើអាជីវកម្ម ដោយបន្តពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម, ការកាត់បន្ថយថ្លៃ និងធានាស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី, ការកាត់បន្ថយថ្លៃដឹកជញ្ជូន និងឡូជីស្ទីក, ការបង្កើនការតភ្ជាប់ឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបង្កើនការបណ្តុះបណ្តាលជំនាញ, ការកាត់បន្ថយកម្រៃក្រៅផ្លូវការ, ការលើកកម្ពស់សេវាបង់ពន្ធ, ការកាត់បន្ថយការធ្វើសវនកម្មពន្ធដារត្រួតគ្នា និងការជំរុញការប្រកួតប្រជែង ដោយស្មើភាព, ការអនុម័តច្បាប់វិនិយោគថ្មី, ច្បាប់ស្តីពីការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស និងច្បាប់ស្តីពីការប្រកួតប្រជែង, ការរៀបចំផែនការមេដើម្បីអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង, ការបន្តលើកទឹកចិត្តផ្នែកសារពើពន្ធ ដើម្បីលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ការស្វែងរកទីផ្សារក្រៅស្រុកបន្ថែម ទាំងទ្វេភាគី និងពហុភាគី តាមរយៈការពង្រីកទីផ្សារក្រៅប្រទេសទៅក្នុងប្លុកពាណិជ្ជកម្មថ្មីៗ, ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការដឹកនាំ និងការអនុវត្តគោលនយោបាយ និងវិធានការនានា, ការបង្កើនប្រសិទ្ធភាពនៃការសម្របសម្រួលស្ថាប័ន ឬមុខងារ តាមរយៈការធ្វើវិចារណកម្មមុខងារ និងភារកិច្ច ព្រមទាំងការលើកកម្ពស់ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន ការបង្កើនការអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតសំខាន់ទាំងបរិមាណ និងគុណភាព។

ក្នុងឆ្នាំ ២០២០ ពិភពលោកទាំងមូលបានជួបប្រទះនឹងវិបត្តិសុខភាពសាធារណៈជាសកល ដែលបណ្តាលមកពីការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ រហូតឈានទៅដល់ការបិទប្រទេស, ការបិទទីក្រុង, ការរឹតត្បិតការធ្វើដំណើរ និងការដាក់ចេញនូវវិធានការម៉ឺងម៉ាត់មួយចំនួនទៀត សំដៅទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ ជាលទ្ធផល វិធានការទាំងនោះបានបន្ថែមសម្ពាធ និងបង្អាក់សកម្មភាពផលិតកម្ម, ការផ្គត់ផ្គង់, ការប្រើប្រាស់ និងការវិនិយោគ ដែលបានរុញច្រានកំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០២០ ឱ្យធ្លាក់ចុះគួរឱ្យកត់សម្គាល់ ។ មិនខុសពីបណ្តាប្រទេសនានាលើសកលលោកឡើយ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២០ ក៏បានទទួលរងផលប៉ះពាល់ពីវិបត្តិសកលនេះផងដែរ និងជារួមត្រូវបានវាយតម្លៃថា

សម្រេចបានកំណើនអវិជ្ជមាន ក្នុងអត្រា -៣,១% ដោយសារការធ្លាក់ចុះនៃវិស័យសេវាកម្ម និងវិស័យឧស្សាហកម្ម ខណៈវិស័យកសិកម្មនៅរក្សាបានកំណើនវិជ្ជមាន ។ ក្នុងនោះ វិស័យសេវាកម្មមានកំណើនអវិជ្ជមាន ក្នុងអត្រា ៦,៧% ដោយសារការធ្លាក់ចុះយ៉ាងគំហុកនៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន និងកំណើនអវិជ្ជមាននៃអនុវិស័យអចលនទ្រព្យ និងអនុវិស័យផ្សេងទៀតដែលគាំទ្រដល់វិស័យទេសចរណ៍។ ជាមួយគ្នានេះ វិស័យឧស្សាហកម្មត្រូវបានវាយតម្លៃថាមានកំណើនអវិជ្ជមាន ក្នុងអត្រា ១,២% ដែលបណ្ដាលមកពីការធ្លាក់ចុះនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់ ខណៈអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅរក្សាបានកំណើនខ្ពស់ ។ ទោះជាយ៉ាងនេះក្តី, វិស័យកសិកម្មត្រូវបានវាយតម្លៃថាមានកំណើនវិជ្ជមានក្នុងអត្រា ០,៥% ដែលគាំទ្រដោយកំណើនទាបនៃអនុវិស័យដំណាំ និងការងើបឡើងវិញនៃអនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទ បន្ទាប់ពីកំណើនអវិជ្ជមានក្នុងឆ្នាំ ២០១៩។

ជាមួយនឹងកំណើនអវិជ្ជមាននេះ ផសស ថ្លៃបច្ចុប្បន្នបានធ្លាក់ចុះមក ១០៩ ០៦២ ប៊ីលានរៀល និងធ្វើឱ្យ ផសស សម្រាប់មនុស្សម្នាក់ថមថយមកប្រមាណ ១ ៦៥៣ ដុល្លារអាមេរិក។ អតិផរណាមានការកើនឡើងបន្តិច ប៉ុន្តែស្ថិតក្នុងកម្រិតគ្រប់គ្រងបានក្នុងអត្រា ២,៩% ក្នុងឆ្នាំ ២០២០ ធៀបនឹង ១,៨% ក្នុងឆ្នាំ ២០១៩ ដោយសារការកើនឡើងនៃតម្រូវការ (Demand Shock) ម្ហូបអាហារ និងផលិតផលផ្សេងទៀតនៅលើទីផ្សារ ស្របពេលដែលសមត្ថភាពផ្គត់ផ្គង់មានការថមថយ, ដោយឡែកថ្លៃដឹកជញ្ជូនមានការធ្លាក់ចុះដោយសារការធ្លាក់ថ្លៃប្រេងលើទីផ្សារអន្តរជាតិ។ យ៉ាងណាមិញ អត្រាប្តូរប្រាក់នៅតែបន្តមានស្ថិរភាពក្នុងអំឡុងពេលវិបត្តិនេះ ក្នុងតម្លៃប្រមាណ ៤ ០៨០ រៀលក្នុងមួយដុល្លារអាមេរិក។

ដើម្បីឆ្លើយតបនឹងនិន្នាការខាងលើ ក៏ដូចជាគ្រប់គ្រងហានិភ័យផ្សេងៗ ដែលអាចកើតមាន រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលវេលា តាមរយៈការដាក់ចេញដោយប្រទាក់ក្រឡានូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយរចនាសម្ព័ន្ធ (structural policy) ដើម្បីសម្រេចឱ្យបានគោលបំណងរក្សាលំនឹងសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ច។

## ២.២. ស្ថានភាពវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជា

ការវិនិយោគផ្ទាល់ពីបរទេស បានចាប់ផ្តើមហូរចូលមកប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៨៩ ស្របពេលដែលរដ្ឋាភិបាលកម្ពុជា បានធ្វើការផ្លាស់ប្តូរបែបផែនសេដ្ឋកិច្ចពីសេដ្ឋកិច្ចបែបផែនការទៅជាសេដ្ឋកិច្ចទីផ្សារសេរីវិញ។ បន្ទាប់ពីមានការបោះឆ្នោតជាលើកដំបូងក្នុងឆ្នាំ ១៩៩៣ ការវិនិយោគផ្ទាល់ពីបរទេសចាប់ផ្តើមមានសន្ទុះកើនឡើងគួរអោយកត់សម្គាល់។ គួរបញ្ជាក់ផងដែរថាក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេសដែលមកធ្វើការវិនិយោគនៅកម្ពុជា រួមមានលើវិស័យឧស្សាហកម្មធនាគារ កសិកម្ម និងទេសចរណ៍។ ដែលក្រុមហ៊ុនទាំងនោះជាក្រុមហ៊ុនដែលមកពីបណ្តាប្រទេសដូចជា ហុងកុង ថៃ សិង្ហបុរី ម៉ាឡេស៊ី និងអាមេរិកជា

ដើម។ នៅក្នុងឆ្នាំ ២០០០ CDC បានអនុម័តលើគម្រោងវិនិយោគចំនួន ៦២ ដែលមានមូលធនវិនិយោគសរុប ២២០លានដុល្លាអាមេរិក។និន្នាការនេះមានការកើនឡើងគួរឲ្យកត់សម្គាល់ជាបន្តបន្ទាប់ ហើយវាមានការឡើងខ្លាំងនៅក្នុងឆ្នាំ២០០៨ គឺមូលធនសរុបនៃវិនិយោគបានកើនឡើងដល់ ៦.៩៥៦ លានដុល្លា។ ប៉ុន្តែការកើនឡើងនេះ ត្រូវបានធ្លាក់ចុះមកវិញនៅក្នុងឆ្នាំ ២០០៩ មកនៅត្រឹម ២,១០៦ លានដុល្លា ដោយសារតេឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុពិភពលោក។ តែទោះជាយ៉ាងណាក៏ដោយ ក៏វិបត្តិនេះពុំមានផលអាក្រក់ខ្លាំងចំពោះការទាក់ទាញ FDI នោះទេ ដោយគេសង្កេតឃើញថាវាមានការកើនឡើងបន្តិចវិញក្នុងឆ្នាំ ២០១០ ដែលមូលធនវិនិយោគបានកើនដល់ ២.៣០០ លានដុល្លា លុះដល់ឆ្នាំ ២០១១ ការវិនិយោគផ្ទាល់ពីបរទេសមានសន្ទុះកើនឡើងដល់ ៥.៧៦៣លានដុល្លារអាមេរិក។ តែបន្តមកដល់ឆ្នាំ ២០១២ FDIបានធ្លាក់ចុះមកវិញត្រឹម ១.៧១៧ លានដុល្លារអាមេរិក និងបានបន្តការកើនឡើងមកដល់ឆ្នាំ ២០១៥ ត្រឹម ១.៤២៦លានដុល្លារអាមេរិក។

រូបភាពទី២៖ មូលធនបរទេសនៃគម្រោងវិនិយោគដែលបានអនុម័តដោយ CDC




ប្រភព៖ ទាញយកពី CDC ២០១៥

ជាទូទៅការវិនិយោគផ្ទាល់ពីបរទេស (FDI) ត្រូវបានគេមើលឃើញថាជាកម្លាំងជំរុញនូវកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ការអភិវឌ្ឍសង្គមទាំងសម្រាប់ប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ដូចគ្នា។

ជាក់ស្តែង សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានទទួលអត្ថប្រយោជន៍ជាច្រើនពី FDI។ លំហូរវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជាបានកើនឡើងយ៉ាងខ្លាំង ចាប់ពីដើមទសវត្សន៍ឆ្នាំ ២០០០ មកដោយសារគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ ស្ថេរភាពនយោបាយ និងការបើកចំហទីផ្សារក៏ដូចជាឥទ្ធិពលនៃកំណើនសេដ្ឋកិច្ចក្នុងតំបន់។ បរិយាកាសអំណោយផលទាំងនេះបានផ្តល់មកនូវឱកាសវិនិយោគដ៏ទាក់ទាញសម្រាប់វិនិយោគិនមកលើប្រទេសកម្ពុជា។

ជាការពិតណាស់ FDI គឺជាផ្នែកមួយដ៏ធំនៃលំហូរចូលយ៉ាងច្រើននៃមូលធនហិរញ្ញវត្ថុមកក្នុងប្រទេសកម្ពុជា។ យោងតាមរបាយការណ៍ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជាបានឱ្យដឹងថា លំហូរចូលនៃ ការវិនិយោគផ្ទាល់ពីបរទេសនៅឆ្នាំ ២០១៩ បានកើនឡើង ១២% ដែលស្មើនឹង ៣,៥ ពាន់លានដុល្លារអាមេរិក។ ខណៈលំហូរចូលវិនិយោគផ្ទាល់ពីបរទេសចំនួន ២,៣ ពាន់លានដុល្លារបានចូលទៅក្នុងវិស័យហិរញ្ញវត្ថុ។ ក្នុងនោះប្រទេសចិននៅតែមានចំណែកធំបំផុតនៃទុនវិនិយោគផ្ទាល់ពីបរទេសដោយមានចំនួន ៤៣% បន្ទាប់មកគឺកូរ៉េខាងត្បូងចំនួន ១១%, វៀតណាមចំនួន ៧%, ជប៉ុន និងសិង្ហបុរីចំនួន ៦% ដូចគ្នា។ លំហូរមូលធនដ៏ច្រើនបសន្ទឹកសន្ធាប់នេះភាគច្រើនបណ្តាលមកពីការវិនិយោគដ៏រឹងមាំនៅក្នុងវិស័យផលិតកម្ម និងសេវាកម្ម។

### ២.២.១. បណ្តាប្រទេសដែលវិនិយោគនៅប្រទេសកម្ពុជា

ដៃគូពាណិជ្ជកម្មធំបំផុតរបស់កម្ពុជានៅឆ្នាំ ២០២០ គឺអាស៊ាន ចិន អាមេរិក និងសហភាពអឺរ៉ុប។ តម្លៃពាណិជ្ជកម្មសរុបបានឈានដល់ ៣៥,៨០៥,៨៥ លានដុល្លារក្នុងឆ្នាំ ២០២០ ដែលជាការកើនឡើង ២,៥៤% ពីឆ្នាំ ២០១៩។

តារាងទី១៖ ពាណិជ្ជកម្មរបស់កម្ពុជាជាមួយដៃគូសំខាន់ៗក្នុងឆ្នាំ ២០២០ (លានដុល្លារអាមេរិក)

| ទិសដៅនាំចេញ | នាំចេញ | ឆ្នាំ២០១៩ នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | ឆ្នាំ២០២០ នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | បម្រែបម្រួល (%) នាំចូល | ទំហំពាណិជ្ជកម្ម |
|---|---|---|---|---|---|---|---|---|---|
| កាណាដា | ៨៣៦.៦៨ | ១២១.១៦ | ៩៥៧.៨៥ | ៧៤៥.០៤ | ៥៥.៣៦ | ៨០០.៤០ | (0.១១) | (0.៥៤) | (0.១៦) |
| កូរ៉េ | ២១១.៧២ | ៦៧០.0៤ | ៨៨១.៧៦ | ១៨៥.0២ | ៥៤៤.១១ | ៧២៩.១៣ | (0.១៣) | (0.១៩) | (0.១៧) |
| ចក្រភពអង់គ្លេស | ៩៧៧.៥ | ៧៩.៧៧ | ១,0៥៧.២៨ | ៨២៦.១៦ | ៥១.៣៨ | ៨៧៧.៥៤ | (0.១៥) | (0.៣៦) | (0.១៧) |
| សហភាពអឺរ៉ុប (EU) | ៣៨៩៤.១៩ | ៧0១.0៩ | ៤,៥៩៥.២៨ | ៣,២0៣.៨៧ | ៦៥៩.១៣ | ៣,៨៦៣.00 | (0.១៨) | (0.0៦) | (0.១៦) |
| ឥណ្ឌា | ៦៤.៦៧ | ១៩១.៥៩ | ២៥៦.២៦ | ៦១.៣៦ | ១២៨.៧៧ | ១៩0.១៣ | (0.0៥) | (0.៣៣) | (0.២៦) |
| ជប៉ុន | ១១៣៦.៥៨ | ៨៨២.៣៤ | ២,0១៨.៩២ | ១,0៥៥.៥៥ | ៦៣៧.0៩ | ១,៦៩២.៦៤ | (0.0៧) | (0.២៨) | (0.១៦) |
| អូស្ត្រាលី | ១៣៣.៥៨ | ៧២.២១ | ២0៥.៧៩ | ១៣៣.៩២ | ៧៩.៧២ | ២១៣.៦៤ | 0.00 | 0.១0 | 0.0៤ |
| សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) | ៥១.៨១ | ៥.១៧ | ៥៦.៩៨ | ៥២.១៩ | ១៥.១៨ | ៦៧.៣៧ | 0.0១ | ១.៩៤ | 0.១៨ |
| វៀតណាម | ៣៣៥.៨២ | ២,៧១៨.១៩ | ៣,0៥៤.0១ | ៣៨៥.៧៩ | ២,៦៣៣.៨១ | ៣,0១៩.៦0 | 0.១៥ | (0.0៣) | (0.0១) |
| ពិភពលោក | ១៤៧៤៨.៧៤ | ២0,១៧១.៨១ | ៣៤,៩២0.៥៥ | ១៧,២១៥.៣៧ | ១៨,៥៩0.៤៨ | ៣៥,៨0៥.៨៥ | 0.១៧ | (0.0៨) | 0.0៣ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| អាស៊ាន | ១៣០៣.៤១ | ៧,៩៥១.៥០ | ៩,២៥៤.៩០ | ៣,៧២២.៧៦ | ៧,៦០៧.២៦ | ១១,៣៣០.០២ | ១.៨៦ | (0.0៤) | 0.២២ |
| អាមេរិក | ៤៤០២.៣៦ | ៣១១.២០ | ៤,៧១៣.៥៧ | ៥,២៥៨.៨៨ | ២៥០.៧៣ | ៥,៥០៩.៦០ | 0.១៩ | (0.១៩) | 0.១៧ |
| ប្រទេសផ្សេងៗ | ៧១៩.២៥ | ១,៦១៧.៩១ | ២,៣៣៧.១៧ | ៨៧១.0៦ | ១,៥១៤.៧៦ | ២,៣៨៥.៨១ | 0.២១ | (0.0៦) | 0.0២ |
| ថៃ | ៥០២.១ | ៣,២២២.៤៤ | ៣,៧២៤.៥៤ | ៦៥០.៦៧ | ២,៨៣៥.៥៦ | ៣,៤៨៦.២៣ | 0.៣0 | (0.១២) | (0.0៦) |
| ចិន | ១០០៤.៧៩ | ៧,៥៥៨.៥២ | ៨,៥៦៣.៣១ | ១,0៨៦.២៦ | ៧,0៣១.៨១ | ៨,១១៨.0៧ | 0.0៨ | (0.0៧) | (0.0៥) |
| នូវែលសេឡង់ | ១២.១៨ | ៩.៣១ | ២១.៥០ | ១៣.៣១ | ១៥.១៧ | ២៨.៤៨ | 0.0៩ | 0.៦៣ | 0.៣២ |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច, *"របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០២០ និង ទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២១"*

### ២.២.១.១. ប្រទេសអាស៊ាន

របាយការណ៍របស់ក្រសួងពាណិជ្ជកម្មប្រចាំឆ្នាំ ២០២០ បង្ហាញថាពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសជាសមាជិកអាស៊ានមានទំហំពាណិជ្ជកម្មខ្ពស់បំផុតដែលមានចំនួន ១១,៣ ពាន់លានដុល្លារក្នុងឆ្នាំ ២០២០។ នេះគឺជាការកើនឡើង ២២,៤ ភាគរយបើប្រៀបធៀបនឹងតួលេខដែលបានកត់ត្រាក្នុងឆ្នាំ ២០១៩ ដោយមានប្រទេសថៃ និងវៀតណាមជាដៃគូពាណិជ្ជកម្មធំបំផុត។ ការធ្វើពាណិជ្ជកម្មនៅក្នុងឆ្នាំ ២០២០ ជាមួយប្រទេសថៃមានតម្លៃ ៣,៤ ពាន់លានដុល្លារខណៈពេលដែលការធ្វើពាណិជ្ជកម្មជាមួយប្រទេសវៀតណាមគឺ ៣ ពាន់លានដុល្លារដែលធ្លាក់ចុះ ៦,៤ និង ១,១៣ ភាគរយបើធៀបទៅនឹងឆ្នាំ ២០១៩។[៧]

បណ្តាប្រទេសអាស៊ានបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួនដើម្បីអនុញ្ញាតឱ្យប្រទេសជាសមាជិកទទួលបាននូវលំហូរទំនិញ សេវាកម្ម ការវិនិយោគ ដើមទុន និងកម្លាំងពលកម្មដោយសេរីតាមរយៈការបង្កើតទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ។ កិច្ចព្រមព្រៀងនេះរួមមានកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយអាស៊ានស្តីពីវិនិយោគ កិច្ចព្រមព្រៀងអាស៊ានស្តីពីចលនាមនុស្សធម្មជាតិ និងកិច្ចព្រមព្រៀងអាស៊ានស្តីពីការទទួលស្គាល់ទៅវិញទៅមកលើសេវាកម្ម។ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម លោកប៉ាន សូរ៉ាស័ក្តិបានធ្វើសន្និសីទវីដេអូជាមួយ-

[៧] ក្រសួងពាណិជ្ជកម្ម, *"របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២០ និង ទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២១"*

លោក Gan Kim Yong រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មសិង្ហបុរីអំពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការសហការយ៉ាងជិតស្និទ្ធលើវិស័យពាណិជ្ជកម្ម និងការវិនិយោគ និងដំណើរការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់។ដែលជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) រវាងសមាជិកអាស៊ាន និងដៃគូពាណិជ្ជកម្មនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំង ៦ របស់ខ្លួនរួមមានចិន កូរ៉េខាងត្បូង ជប៉ុន ឥណ្ឌា អូស្ត្រាលី និងនូវែលហ្សេឡង់។

អនុប្រធានសភាពាណិជ្ជកម្មកម្ពុជាលោក លឹម ហេងបានមានប្រសាសន៍ថាពាណិជ្ជកម្មជាមួយវៀតណាម និងថៃមានភាពស្រដៀងគ្នាច្រើនឆ្នាំមកហើយ។ ទំនិញនាំចេញភាគច្រើនមានផលិតផលកសិកម្មដូចជាស្រូវ ដំឡូងមី ពោត និងកៅស៊ូខណៈការនាំចូលរួមមានអាហារ និងភេសជ្ជៈ ទំនិញប្រើប្រាស់ និងសម្ភារៈសំណង់។ លោកក៏បានបន្ថែមថាទោះបីជាកម្ពុជាអាចដំណើរការផលិតផលប្រើប្រាស់បានទូលំទូលាយក៏ដោយក៏សមត្ថភាពនៅតែមានកម្រិត។ ប្រទេសនេះនៅតែត្រូវការការនាំចូលបន្ថែមជាពិសេសពីប្រទេសជិតខាង ដូច្នេះការវិនិយោគអន្តរជាតិត្រូវបានលើកទឹកចិត្តដើម្បីធ្វើអោយឧស្សាហកម្មកែច្នៃ និងសមត្ថភាពផលិតក្នុងស្រុកប្រសើរឡើង។

### **២.២.១.២. ប្រទេសចិន**

ប្រទេសចិន គឺជាដៃគូពាណិជ្ជកម្មសំខាន់មួយរបស់ប្រទេសកម្ពុជាដែលមានទំហំពាណិជ្ជកម្ម ៨,១ ពាន់លានដុល្លារនៅឆ្នាំ ២០២០ (ទោះបីនេះគឺជាការធ្លាក់ចុះពី ៨,៥ ពាន់លានដុល្លារក្នុងឆ្នាំ២០១៩)។[៨] ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរមានសារៈសំខាន់ខ្លាំងណាស់ មិនត្រឹមតែនៅក្នុងបរិបទនៃជំងឺឆ្លងប៉ុណ្ណោះទេប៉ុន្តែថែមទាំងនៅក្នុងការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយតំបន់ ព្រមទាំងពិភពលោកផងដែរនេះបើយោងតាមរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម លោក សុខ សុភ័ក្រ្ត។

ការចរចាស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងចិន ត្រូវបានផ្តល់សច្ចាប័នហើយរំពឹងថានឹងចូលជាធរមាននៅឆ្នាំ ២០២២ និងជួយលើកកម្ពស់ទំហំពាណិជ្ជកម្ម និងពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនេះ ត្រូវបានរំពឹងថានឹងជំរុញពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរទៅដល់ ១០ ពាន់លានដុល្លារនៅឆ្នាំ ២០២៣ នេះបើតាមលោក សុខ សុភ័ក្រ្តមានប្រសាសន៍។ អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានចង្អុលបង្ហាញថានៅពេលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីត្រូវបានអនុវត្តហើយរាំងសាំងការពារជំងឺកូវីដ-១៩ បានកើតឡើងនៅជុំវិញពិភពលោកហើយកម្ពុជា និងចិន ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរត្រូវបានគេរំពឹងថានឹងកើនឡើង ជាពិសេសការទាក់ទាញវិនិយោគិនពីប្រទេសចិនមក

[៨] ក្រសួងពាណិជ្ជកម្ម, *"របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២០ និង ទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២១"*

ប្រទេសកម្ពុជាដើម្បីផលិត និងកែច្នៃផលិតផលដើម្បីនាំចេញត្រឡប់ទៅប្រទេសចិនវិញ។

**២.២.១.៣. សហរដ្ឋអាមេរិក**

ទោះបីជាវិបត្តិសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺឆ្លងបានធ្វើឱ្យពាណិជ្ជកម្មអន្តរជាតិធ្លាក់ចុះ ទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា និងអាមេរិកមានដំណើរការល្អ។ បើយោងតាមទិន្នន័យរបស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ ២០២១ តម្លៃសរុបនៃពាណិជ្ជកម្មកម្ពុជាជាមួយអាមេរិកបានកើនឡើងពី ៤,៧ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៩ ដល់ ៥,៥ ពាន់លានដុល្លារក្នុងឆ្នាំ ២០២០ ដែលជាការកើនឡើង ១៦,៨ ភាគរយ។ ទោះបីជាអាមេរិកមិនមែនជាប្រភពវិនិយោគដ៏សំខាន់របស់កម្ពុជាក៏ដោយ ក៏អាមេរិកជាទីផ្សារនាំចេញធំបំផុតរបស់កម្ពុជា ដោយភាគច្រើនជាសម្លៀកបំពាក់ និងស្បែកជើងដែលមានចំនួន ៥,២ ពាន់លានដុល្លារនៅឆ្នាំ ២០២០។

ដើម្បីលើកកម្ពស់ពាណិជ្ជកម្ម និងការវិនិយោគ ប្រទេសទាំងពីរបានជួបគ្នាជាញឹកក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគឆ្នាំ ២០០៦ ដែលជាកិច្ចព្រមព្រៀងមួយសម្រាប់ពួកគេដើម្បីដោះស្រាយបញ្ហាទ្វេភាគី តំបន់ និងពហុភាគី។ នៅថ្ងៃទី ០១ ខែមិថុនាឆ្នាំ ២០២១ អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក Wendy Sherman បានមកប្រទេសកម្ពុជាដើម្បីជួបជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន។ អនុប្រធានសភាពាណិជ្ជកម្មកម្ពុជាបានបញ្ជាក់ថាដំណើរទស្សនកិច្ចនេះឆ្លុះបញ្ចាំងពីទំនាក់ទំនងជិតស្និទ្ធ និងជំរុញពាណិជ្ជកម្មទ្វេភាគី និងកិច្ចសហប្រតិបត្តិការបន្ថែមទៀតរវាងប្រទេសទាំងពីរ។

**២.២.១.៤. សហភាពអឺរ៉ុប**

ប្រទេសកម្ពុជា និងសហភាពអឺរ៉ុបបានធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នានៅក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការសហភាពអឺរ៉ុប និងអាស៊ាន។ ទិន្នន័យពីក្រសួងពាណិជ្ជកម្មបង្ហាញថាពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងសហភាពអឺរ៉ុបមានចំនួន ៣,៨ ពាន់លានដុល្លារនៅឆ្នាំ ២០២០ ដែលជាការធ្លាក់ចុះ ១៥,៩ ភាគរយពី ៤,៥ ពាន់លានដុល្លារដែលបានបង្ហោះក្នុងឆ្នាំ២០១៩។ ការធ្លាក់ចុះគឺមកពីការដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់សហភាពអឺរ៉ុប (ប្រព័ន្ធអនុគ្រោះពន្ធគ្រប់យ៉ាងលើកលែងតែអាវុធ) និងជំងឺឆ្លងដែលបណ្តាលឱ្យមានការធ្លាក់ចុះនៃតម្រូវការ និងការនាំចេញទៅកាន់សហភាពអឺរ៉ុប និងការផ្អាកដំណើរការរោងចក្រមួយចំនួន។[៩]

កម្ពុជាទទួលបានអត្ថប្រយោជន៍ជាច្រើនពី ប្រព័ន្ធអនុគ្រោះទូទៅរបស់សហភាពអឺរ៉ុបដែលផ្តល់ឱ្យបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចនូវការរួចពន្ធ និងមិនគិតកូតាចូលចំពោះផលិតផលទាំងអស់លើកលែងតែអាវុធ និងគ្រាប់រំសេវ។ ការដក ២០ ភាគរយនៃប្រព័ន្ធអនុគ្រោះពន្ធគ្រប់យ៉ាងលើកលែងតែអាវុធជាមួយកម្ពុជានៅ

[៩] គណៈកម្មការអឺរ៉ុប, "*ប្រទេសកម្ពុជា*", ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០២១, ឯកសារជាភាសាអង់គ្លេស ពុំមានការបកប្រែជាភាសាខ្មែរ

ឆ្នាំ២០២០ ដែលសហភាពអឺរ៉ុបបានអះអាងថាមកពីការរំលោភសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅកម្ពុជា បានប៉ះពាល់ពាណិជ្ជកម្មទ្វេភាគីជាមួយសហភាពអឺរ៉ុបជាពិសេសសំលៀកបំពាក់សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្ករ។ ជាសំណាងល្អដែលកម្ពុជាមានសិទ្ធិទទួលបានការនាំចេញដោយរួចពន្ធក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់ចក្រភពអង់គ្លេស ដូច្នេះវាអនុញ្ញាតឱ្យកម្ពុជានាំចេញទំនិញ ២០ ភាគរយដែលបាត់បង់ពីសហភាពអឺរ៉ុបទៅចក្រភពអង់គ្លេសជំនួសវិញ។ ចក្រភពអង់គ្លេសមានការរៀបចំការធ្វើពាណិជ្ជកម្មមួយដែលរឹងមាំជាមួយប្រទេសកម្ពុជា និងមានសិទ្ធពាណិជ្ជកម្មលើការនាំចេញបើទោះបីជាចក្រភពអង់គ្លេសបានចាកចេញពីសហភាពអឺរ៉ុប។[១០]

ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងពាណិជ្ជកម្ម សហភាពអឺរ៉ុប និងកម្ពុជាបានជួបប្រជុំគ្នានៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០២១ ដើម្បីរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររួមរបស់អឺរ៉ុបស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់កម្ពុជាឆ្នាំ ២០២១-២០២៧។ នេះស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ លើវិស័យដូចជាការអភិវឌ្ឍធនធានមនុស្ស ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការលើកស្ទួយវិស័យឯកជន និងការងារ និងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។ កិច្ចប្រជុំនេះក៏បានពិភាក្សាអំពីសេចក្តីព្រាងច្បាប់ថ្មីនៃកម្មវិធីណែនាំពហុឆ្នាំរបស់សហភាពអឺរ៉ុបឆ្នាំ ២០២១-២០២៧ ដោយផ្តោតលើវិស័យអាទិភាពនៃវិស័យសេដ្ឋកិច្ច និងការងារ វិស័យអប់រំនិងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងវិស័យអភិបាលកិច្ច។

## ២.៣. កត្តាទាក់ទាញវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជា

ក្នុងចំនុចនេះ យើងនឹងសិក្សាអំពីកត្តាមួយចំនួន ដែលទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសមកធ្វើការវិនិយោគក្នុងប្រទេសកម្ពុជា។ មានកត្តាមួយចំនួនដូចខាងក្រោមៈ

### ២.៣.១. ស្ថេរភាពនយោបាយ

ស្ថេរភាពនៃនយោបាយនៅក្នុងប្រទេសមួយគឺជា កត្តាមួយដ៏សំខាន់ណាស់ក្នុងការទាក់ទាញអ្នកវិនិយោគពីបរទេស និងជាកត្តាមួយ ដែលវិនិយោគិនត្រូវពិចារណាថាតើប្រទេសនោះ មានសន្តិភាពនិងមានភាពរីកចម្រើនកម្រិតណា ហើយធ្វើការប្រមាណថាតើគេអាចវិនិយោគ ដើម្បីរកប្រាក់ចំណេញក្នុងកម្រិតហានិភ័យណា។

ជាក់ស្តែងប្រទេសកម្ពុជា ជាប្រទេសដែលប្រកាន់យករបបប្រជាធិបតេយ្យ និងសេដ្ឋកិច្ចទីផ្សារសេរីក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ នយោបាយកម្ពុជាមានស្ថេរភាព ទោះបីជាមានភាពចលាចលក្នុង

[១០] មជ្ឈមណ្ឌលធនធានធុរកិច្ច និងសិទ្ធិមនុស្ស, "*កម្ពុជាៈ ថ្វីត្បិតតែសហភាពអឺរ៉ុបសម្រេចចិត្តដកប្រព័ន្ធអនុគ្រោះពន្ធគ្រប់យ៉ាងលើកលែងតែអាវុធមួយផ្នែកដោយសារការរំលោភបំពានសិទ្ធិមនុស្សនិងសេរីភាពក៏ដោយ ចក្រភពអង់គ្លេសផ្តល់សិទ្ធិពាណិជ្ជកម្មដល់កម្ពុជាលើការនាំចេញ,*" ឯកសារជាភាសាអង់គ្លេស ពុំមានការបកប្រែជាភាសាខ្មែរ

ការបោះឆ្នោតនៅឆ្នាំ ២០១៣ ក៏ដោយប៉ុន្តែវាមិនបានប៉ះពាល់ទៅដល់ការធ្វើពាណិជ្ជកម្ម ជាពិសេសទៅដល់ការវិនិយោគឡើយ។ នេះបង្ហាញពីស្ថានភាពនយោបាយរបស់កម្ពុជាដែលផ្តល់ទំនុកចិត្តជូនទៅដល់អ្នកមានភាពនឹងនរប្រកបដោយសន្តិភាព សុវត្ថិភាព និងសន្តិសុខ វិនិយោគ និងបង្ហាញពី លក្ខណៈអំណោយផលដល់ការទាក់ទាញ FDI។

**២.៣.២. ធនធាន និងសក្តានុពលធម្មជាតិ**

ទឹកដីកម្ពុជាធ្លាប់ត្រូវបានគេហៅថាទឹកដីសុវណ្ណភូមិ ពីព្រោះមិនថានៅក្នុងទឹក លើដី គឺសម្បូរទៅដោយធនធានធម្មជាតិ ឬដែលមានអំណោយផលសម្រាប់ការធ្វើការវិនិយោគទៅលើគ្រប់វិស័យទាំងកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។

**តំបន់មាត់សមុទ្រ៖** តំបន់នេះបានផ្តល់ធនធានធម្មជាតិជាច្រើនសម្រាប់វិស័យ កសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។ តាមទំនាបឆ្នេរដែលស្ថិតនៅចន្លោះឆ្នេរសមុទ្រ និងជួរភ្នំក្រវ៉ាញច្រើន មានទម្រង់ជាដីខ្សាច់ និងមានជីជាតិបង្គួរសម្រាប់ដំណាំកសិកម្មដូចជា៖ ដូង ដូងប្រេង ធូរេន ម្រេចកៅស៊ូ និងស្រូវ។ ទំនាបឆ្នេរសមុទ្រកម្ពុជា ជាទំនាបឆ្នេរដ៏ល្អប្រសើរបំផុតសម្រាប់វិស័យកសិកម្ម ពិសេសដំនាំដូង ដែលតាមការស្រាវជ្រាវយើងមានដីប្រែពី ៤០,០០០ ទៅ ៥០,០០០ហត្ថ និងដំណាំចំការធំៗដូចជា ចំការម្រេច ចំការធូរ៉េន ដំណាំកៅស៊ូ និងដំណាំស្រូវ។ ជាពិសេសតំបន់ព្រៃកោងកាង ដែលអាចផ្តល់ជាអុស និងធ្យូង។ ផ្លូវទឹកដែលធ្លាក់ពីលើភ្នំក្រវាញ អាចផ្តល់លទ្ធភាពពេញបរិបូរណ៍ ក្នុងការទាញយកថាមពលអគ្គីសនី ដែលមានស្ទឹងកំចាយជាដើម។ រីឯឆ្នេរសមុទ្រវិញ គេប្រទះឃើញមានខ្សាច់សដ៏សន្ទឹកសន្ទាប់ ដែលជារូបធាតុដើមសម្រាប់ស្លធ្វើកែវ។ ឆ្នេរកែប គឺជាស្ថានីយងូតទឹក និងជាមជ្ឈមណ្ឌលទេចរណ៍មួយយ៉ាងមនោរម្យ។ ចំណែកឆ្នេរសមុទ្រខេត្តព្រះសីហនុវិញ រឹតតបានផ្តល់លក្ខណៈសម្បត្តិល្អប្រសើរសម្រាប់សំណង់បុរីសម្រាកកាយ។

លើសពីនេះទៅទៀត តំបន់មាត់សមុទ្រ តំបន់រមណីដ្ឋានទេសចរណ៍មួយដ៏សំខាន់សម្រាប់ប្រទេសផងដែរ។ ចំពោះឆកកំពង់សោម និងរាម គឺជាមូលដ្ឋានដ៏ប្រសើរសម្រាប់សំណង់កំពង់ផែ សមុទ្រអន្តរជាតិ ក្នុងសកម្មភាពលំនាំចេញ និងចូលនូវទំនិញនានា។ សព្វថ្ងៃនេះកំពង់ផែកំពង់សោមកំពុងមានសកម្មភាពខ្លាំងក្លាសម្រាប់ជាដង្ហើមសេដ្ឋកិច្ចប្រទេសកម្ពុជា។

**តំបន់ទំនាបកណ្តាល៖** តាមរយៈទីតាំងភូមិសាស្ត្រ តំបន់ទំនាបកណ្តាលត្រូវបានព័ទ្ធជុំវិញទៅដោយតំបន់ភ្នំ និងខ្ពង់រាបដែលធ្វើអោយប្រព័ន្ធផ្លូវទឹកជាច្រើនបានហូរភ្ជាប់គគ្នាក្នុងតំបន់នេះ ជាពិសេសទន្លេមេគង្គ។ គួបផ្សំជាមួយសណ្ឋានដីល្បាប់មានជីជាតិ បានធ្វើអោយតំបន់នេះមានលក្ខណៈល្អប្រសើរសម្រាប់ដំណាំកសិកម្ម និងដំណាំឧស្សាហកម្មទាំងឡាយព្រមទាំងជាទីជម្រកនៃមច្ឆាទឹកសាបផងដែរ។ ដំណាំជាទូទៅដែលគេសង្កេតឃើញក្នុងតំបន់នេះរួមមាន ពោត សណ្តែកលូ កប្បាស ក្រចៅ ថ្នាំជក់ និងកៅស៊ូ។ល។ ចំពោះ

ការនេសាទនៅក្នុងតំបន់នេះ មានសកម្មភាពមមាញឹកណាស់ដែរ។ ប្រជាពលរដ្ឋជាង ១.២លាននាក់ដែលរស់នៅជុំវិញតំបន់នេះបានពឹងផ្អែកទៅលើ ការនេសាទ ជាក់ស្តែងការនេសាទ ជាអនុវិស័យមួយក្នុងវិស័យកសិកម្ម ដែលមានទំហំប្រមាណជា ២២.២% (២០១៤) នៃវិស័យកសិកម្មទាំងមូល។

តារាងទី២៖ ផលនេសាទត្រីទឹកសាបពីឆ្នាំ ២០០៩-២០១៣ ច

| ឆ្នាំ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| ផលនេសាទទឹកសាប | ៣៩០.០០០ | ៤០៥.០០០ | ៤៤៥.០០០ | ៥០៩.០០០ | ៥៥០.០០០ |

ប្រភព៖ ទាញពីសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៤

តាមរយៈទិន្នន័យរបស់ក្រសួងកសិកម្ម យើងឃើញថាផលនេសាទ មានការកើនឡើងចាប់ពីឆ្នាំ ២០០៩ មាន ៣៩០.០០០តោន មកដល់ ៥៥០.០០០តោនក្នុងឆ្នាំ ២០១៣។

ក្រៅពីនេះតំបន់ទំនាបកណ្តាល នៅមានធនធានធម្មជាតិ និងធនធានវប្បធម៌ជាច្រើនទៀត ជាពិសេសគឺនៅតំបន់អង្គរខេត្តសៀមរាប ដែលបង្កលក្ខណៈងាយស្រួលដល់ការវិនិយោគផ្នែកទេសចរណ៍ដូចជាសណ្ឋាគារ មជ្ឈមណ្ឌលទេសចរណ៍ និងសេវាកម្មទេសចរណ៍ដទៃទៀត។

**តំបន់ប្រជុំភ្នំ និងខ្ពង់រាប៖** តំបន់នេះក៏ផ្តល់នូវធនធានធម្មជាតិយ៉ាងច្រើនផងដែរ ដែលអំណោយផលទៅលើការវិនិយោគក្នុងវិស័យទាំង៣។ ធនធានធម្មជាតិដែលត្រូវបានគេមើលឃើញថាមានដូចជា ឈើធំៗសម្រាប់សំណង់ ឧស្សាហកម្ម និងពាណិជ្ជកម្ម រ៉ែត្បូង ត្បូងថ្ម និងថ្មមានតម្លៃ ជាពិសេស នៅខេត្តពោធិសាត់ និងបាត់ដំបង ដែលអនុញ្ញាតិអោយធ្វើការវិនិយោគលើធនធានរ៉ែ ដូចជាការច្នៃគ្រឿងអលង្ការ និងជាវត្ថុធាតុដើមនៃឧស្សាហកម្មស៊ីម៉ង់ត៍ជាដើម។ ក្រៅពីនេះ នៅតាមតំបន់ខ្ពង់រាបប៉ែកខាងភូមិភាគឦសានមានដូចជាខេត្តក្រចេះ ស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី និងកំពង់ចាម សុទ្ធតែជាតំបន់ដីក្រហម ដែលមានលក្ខណៈអំណោយផលជាច្រើនសម្រាប់ការដាំដុះដំណាំកសិកម្ម និងឧស្សាហកម្មដូចជា កាហ្វេ តែ ចេក ម្នាស់ ក្រូច និងជាពិសេសដំណាំកៅស៊ូ។ លើសពីនេះទៅទៀត សម្រស់នៃធម្មជាតិព្រៃភ្នំបានផ្តល់អាទិភាពដល់ការវិនិយោគខាងវិស័យទេសចរណ៍ដ៏សំខាន់ផងដែរ។

ដូច្នេះ ជារួមយើងឃើញថា ប្រសិនបើមានការអភិរក្សយ៉ាងត្រឹមត្រូវចំពោះធនធានធម្មជាតិ និងធនធានវប្បធម៌ទាំងនេះ យើងជឿជាក់ថាប្រទេសកម្ពុជាអាចនឹងមានការអភិវឌ្ឍន៍ទៅមុខបានក្រោមគោលនយោបាយដ៏សមស្របមួយ តាមរយៈការធ្វើនូវឯកជនភាវូបនីយកម្មទៅលើធនធានទាំងឡាយណា ដែលយើងគិតថានឹងអាចផ្តល់ផលប្រយោជន៍ចំពោះសេដ្ឋកិច្ចជាតិ ពីព្រោះធនធានទាំងនោះមានសក្តានុពលយ៉ាងខ្លាំងក្លាក្នុងការទាក់ទាញ FDI។

### ២.៣.៣. តំបន់សេដ្ឋកិច្ចពិសេស

តំបន់សេដ្ឋកិច្ចពិសេស (SEZ) គឺជាតំបន់ភូមិសាស្ត្រនៅក្នុងទឹកដីកម្ពុជា ដែលត្រូវបានគេកំណត់ និងបែងចែកឡើងដោយរដ្ឋាភិបាល ដែលផ្តល់ជូនច្បាប់អាជីវកម្មខុសពីតំបន់ផ្សេងៗនៅក្នុងប្រទេស។ តំបន់សេដ្ឋកិច្ចពិសេសក៏មានហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗសម្រាប់អាជីវកម្ម ដែលស្វែងរក ភាពជោគជ័យដូចជាៈ ការបម្រុងទុកប្រភពថាមពល លូបង្ហូរទឹកនិងទឹកផ្លូវនិងអាកប្បកិរិយាគយពន្ធគរនិងអ្នកតំណាងរដ្ឋាភិបាលដទៃទៀត។ ជាទូទៅតំបន់សេដ្ឋកិច្ចពិសេសគឺសមស្របបំផុតចំពោះប្រតិបត្តិការផលិតកម្មទ្រង់ទ្រាយធំដូចជារោងចក្រសំលៀកបំពាក់ រោងចក្រស្បែកជើង រោងចក្រផលិតរថយន្ត តនិងរោងចក្រកែច្នៃម្ហូបអាហារជាដើម។

បណ្តាញសេដ្ឋកិច្ចពិសេសនៅទូទាំងប្រទេសកម្ពុជាបានលើកទឹកចិត្ត និងជម្រុញការវិនិយោគពីបរទេសនៅក្នុងវិស័យឧស្សាហកម្មអស់រយៈពេលជាច្រើនឆ្នាំ ហើយតំបន់ទាំងនេះផ្តល់សម្បទានពន្ធបន្ថែម ហេដ្ឋារចនាសម្ព័ន្ធ និងការគាំទ្រសេវារួមសម្រាប់វិនិយោគិនរោងចក្រ។

រដ្ឋាភិបាល បានទទួលស្គាល់ពីគុណសម្បត្តិហិរញ្ញវត្ថុនិងពេលវេលាដែលទទួលបានតាមរយៈការបញ្ជូនហេដ្ឋារចនាសម្ព័ន្ធនិងធនធានការងារតាមរយៈទីតាំងជាក់លាក់មួយ។ នេះជាមូលហេតុដែលតំបន់សេដ្ឋកិច្ចពិសេសចំនួន ៣៣ ត្រូវបានអនុម័តនៅទូទាំងប្រទេសដោយបំពេញបន្ថែមនូវបណ្តាញដ៏ធំមួយដែលកំពុងដំណើរការ។ ការដាក់ជាយុទ្ធសាស្ត្រនៃតំបន់ទាំងនេះអនុញ្ញាតឱ្យមានភាពងាយស្រួលសម្រាប់ព្រំដែនចាំបាច់និងមជ្ឈមណ្ឌលផលិតកម្ម។

រដ្ឋាភិបាលបានទទួលស្គាល់ពីអត្ថប្រយោជន៍ហិរញ្ញវត្ថុ និងពេលវេលា ដែលទទួលបានពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងធនធានពលកម្ម នៅលើទីតាំងជាក់លាក់មួយ ហើយនេះជាមូលហេតុ ដែលមានតំបន់សេដ្ឋកិច្ចពិសេសចំនួន ៣៣ កន្លែង(ឧបសម្ព័ន្ធទី១) បានអនុម័តនៅទូទាំងប្រទេស ដោយមានបណ្តាញដ៏ធំរួចស្រេចនៅក្នុងប្រតិបត្តិការ។ ការដាក់ជាយុទ្ធសាស្ត្រតំបន់ទាំងនេះផ្តល់ភាពងាយស្រួលក្នុង ការចូលទៅកាន់ ព្រំដែនសំខាន់ៗ និងមជ្ឈមណ្ឌលផលិតកម្ម។ តំបន់សេដ្ឋកិច្ចពិសេសដែលមានទីតាំងនៅលើបរិវេណនៃ ទីក្រុងភ្នំពេញគឺជាឧទាហរណ៍ដ៏សំខាន់មួយ សម្រាប់ការយល់ឃើញរបស់វិនិយោគិនបរទេស តំបន់សេដ្ឋកិច្ចពិសេសអាចសន្សំថវិកា ដែលនឹងត្រូវចំណាយលើការអភិវឌ្ឍដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខ និងការថែទាំ ជាប្រចាំ។ ការលើកលែងពន្ធទៅលើសម្ភារៈ និងបរិក្ខាផលិតកម្មអាចធ្វើទៅបាន នៅពេលអ្នកជួលតំបន់- សេដ្ឋកិច្ចពិសេស មានអាជ្ញាបណ្ណ QIP និងការលើកលែងពន្ធលើប្រាក់ចំណេញ នៅមានសុពលភាព។ សម្រាប់វិនិយោគិនបរទេស ដើម្បីទទួលបានកិច្ចសន្យាជួលឡើងវិញរហូតដល់ ៥០ ឆ្នាំ និងនៅគ្រប់កាលៈទេសៈអ្នកជួលមានលទ្ធភាពក្នុងការអភិវឌ្ឍ ការបែងចែក ឬការជួលបន្ត។

តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (SSEZ) នៅតែជាតំបន់ ដែលធំជាងគេនៅកម្ពុជា ដែលមានផ្ទៃដីជាង ១,០០០ ហិចតា ហើយការអភិវឌ្ឍតម្លៃ ៣២០ លានដុល្លារ នៅពេលសាងសង់រួចរាល់នឹងមានលទ្ធភាពផ្ទុករោងចក្របាន៣០០ កន្លែង ផ្ទុកកម្មករបានទី ៨០ ទៅ ១០០ ពាន់នាក់ និងមានផ្ទៃដី ១១ គីឡូម៉ែត្រការ៉េ។[១១]

ប្រហែលពាក់កណ្ដាលនៃទំហំនេះត្រូវបានគេកំណត់សម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតកម្មអេឡិចត្រូនិច ព្រមទាំងផលិតផលឧស្សាហកម្ម ធុនស្រាល។ ប្រទេសចិនបានសន្យាបន្តអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ហើយរហូតមកដល់ពេលនេះ វាបានទាក់ទាញក្រុមហ៊ុនជាង ១០០ មកពីប្រទេសចិន និងប្រទេសដទៃទៀត ដែលបានផ្ដល់ឱកាសការងារថ្មីចំនួនជិត ២០,០០០ កន្លែង។

ប្រហែលពាក់កណ្ដាលនៃទំហំនេះត្រូវបានកំណត់សម្រាប់វាយនភ័ណ្ឌ សម្លៀកបំពាក់និងផលិតកម្មអេឡិចត្រូនិចក៏ដូចជាផលិតផលឧស្សាហកម្មធុនស្រាល។ ប្រទេសចិនបានសន្យាថានឹងបន្តអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសអាស៊ានហើយរហូតមកដល់ពេលនេះខ្លួនបានទាក់ទាញក្រុមហ៊ុនជាង ១០០ មកពីព្រះរាជាណាចក្រចិន និងប្រទេសដទៃទៀត ហើយជាលទ្ធផលបានបង្កើតឱកាសការងារថ្មីជិត ២០.០០០។ ភាពជោគជ័យនៃតំបន់សេដ្ឋកិច្ចពិសេសនៅជុំវិញប្រទេសកម្ពុជា បានបណ្ដាលឱ្យមានឱកាសថ្មីសម្រាប់ប្រជាជនកម្ពុជានិងប្រទេសទាំងមូល។ ការងារជាង ៦៨.០០០ ត្រូវបានបង្កើតឡើងដោយសារការលើកទឹកចិត្តរបស់តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេស។ ជោគជ័យនេះភាគច្រើនដោយសារតែរដ្ឋាភិបាលបានទុកការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសឲ្យស្ថិតក្នុងកណ្ដាប់ដៃអ្នកអភិវឌ្ឍន៍វិស័យឯកជន ដែលបានធ្វើឱ្យវិស័យសាធារណៈរបស់ប្រទេសកម្ពុជាអាចចៀសផុតពីការចំណាយ និងនាំទៅរកការបង្កើតទីផ្សារប្រកបដោយចីរភាព។

### ២.៣.៤. គោលនយោបាយលើកទឹកចិត្ត

ដោយផ្អែកលើគោលការណ៍ច្បាប់នៃវិនិយោគនៅឆ្នាំ ១៩៩៤ និងច្បាប់វិនិយោគក្រោយការធ្វើវិសោធនកម្ម អនុក្រឹត្យ និងប្រកាសមួយចំនួន យើងឃើញថារដ្ឋាភិបាលបានផ្ដល់ការលើកទឹកចិត្តជាចម្បងចំពោះអ្នកវិនិយោគបរទេសតាមរយៈ គោលនយោបាយអនុគ្រោះពន្ធ។ បើគិតទៅលើការលើកទឹកចិត្តតាមរយៈពន្ធនេះ ប្រទេសកម្ពុជាគឺជាប្រទេសដែលផ្ដល់នូវអនុគ្រោះច្រើនជាងគេ ចំពោះអ្នកវិនិយោគបើធៀបទៅនឹងប្រទេសជិតខាងក្នុងតំបន់។

សកម្មភាពដែលត្រូវបានលើកកម្ពស់ និងជម្រុញ៖ រាជរដ្ឋាភិបាលកម្ពុជាមិនបានកំណត់តឹងរឹងចំពោះ

[១១]គេហទំព័រ អចលនទ្រព្យ , *"អំពីកម្ពុជា"*, www.realestate.com.kh

ការវិនិយោគផ្ទាល់ពីបរទេស ទៅលើវិស័យជាក់លាក់ណាមួយនោះទេ ប៉ុន្តែទោះជាយ៉ាងណាក្តីរដ្ឋាភិបាលកម្ពុជាបានកំណត់នូវសកម្មភាពជាចម្បងមួយចំនួន ដែលត្រូវបានផ្តល់អាទិភាពខ្ពស់ និងលើកទឹកចិត្តដូចជា:

- គម្រោងឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិទ្យាខ្ពស់ និងឈានមុខគេ
- មានលក្ខណៈបង្កើតការងារ
- គម្រោងឧស្សាហកម្មទេសចរណ៍
- មាននិន្នាការនាំចេញ
- គម្រោងកសិឧស្សាហកម្ម និងឧស្សាហកម្មកែច្នៃ
- គម្រោងសាងសង់រចនាសម្ព័ន្ធជារូបវន្ត និងប្រភពថាមពល
- ការអភិវឌ្ឍន៍តាមបណ្តាខេត្ត និងជនបទ

ប្រទេសកម្ពុជាបានបង្កើតបទបញ្ញត្តិផ្សេងៗ ដើម្បីសម្របសម្រួលសេដ្ឋកិច្ចអោយមានលក្ខណៈបើកចំហ និងមានការលើកទឹកចិត្តការវិនិយោគ ដូច្នេះហើយកម្ពុជា បានផ្តល់អោយអ្នកវិនិយោគនូវគោលការណ៍លើកទឹកចិត្ត ដែលមានលក្ខណៈល្អប្រសើរជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ការលើកទឹកចិត្តនោះរួមមាន៖

ក. ការលើកលែងពន្ធទៅលើប្រាក់ចំណេញសុទ្ធរហូតដល់ ៨ឆ្នាំ អាស្រ័យលើលក្ខណៈទម្រង់ដែលគាំទ្រដោយរដ្ឋ។

ខ. លើកលែងពន្ធ ១០០% ទៅលើការនាំចូលវត្ថុធាតុដើមចំពោះគម្រោង ដែលមានទិសដៅនាំចេញលើសពី៨០%នៃផលិតផលសរុប។

គ. លើកលែងពន្ធនាំចេញ ១០០% និងមានការអនុញ្ញាតអោយនាំមកជាមួយនូវក្រុមគ្រួសាររបស់អ្នកវិនិយោគបរទេស និងបុគ្គលិកបរទេសដែលមានលក្ខណៈជំនាញខ្ពស់ខាងការគ្រប់គ្រង និងខាងបច្ចេកទេស។

ឃ. រដ្ឋាភិបាលកម្ពុជាក៏បានអនុញ្ញាតិអោយមានការទិញទំនិញនូវរូបិយវត្ថុតាមរយៈប្រព័ន្ធធនាគារ ឬផ្ញើការផ្ញើរូបិយវត្ថុនោះដូចខាងក្រោម៖

- ការចំណាយសម្រាប់ការនាំចូល និងការទូទាត់ការប្រាក់នៃកម្ចីអន្តរជាតិ
- ការទូទាត់ថ្លៃឈ្នួលរបស់បុគ្គលិក និងអ្នកគ្រប់គ្រង
- ការផ្ទេរប្រាក់ចំណូល
- ការបង្វែរវិញនូវមូលធនដែលយកមកវិនិយោគ

### ២.៣.៥. ការធានា និងការការពារវិនិយោគ

ការផ្តល់ទំនុកចិត្ត និងជំនឿដល់អ្នកវិនិយោគបរទេស ច្បាប់វិនិយោគកម្ពុជា និងកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា និងកិច្ចព្រមព្រៀងអាស៊ានបានលើកឡើងចំណុចសំខាន់ៗមួយចំនួនដែលធានាដល់សន្តិសុខ និង

ទ្រព្យសម្បត្តិដល់វិនិយោគិនបរទេសដូចខាងក្រោម៖

ក. គ្មានការរើសអើងចំពោះរាល់អ្នកវិនិយោគទាំងអស់

ខ. គ្មានការអូសទាញធ្វើជាទ្រព្យសម្បត្តិរដ្ឋដែលប៉ះពាល់ទៅដល់សម្បត្តិឯកជន

គ. គ្មានការត្រួតពិនិត្យ និងគ្រប់គ្រងថ្លៃទំនិញ និងសេវារបស់អ្នកវិនិយោគដែលទទួលបានអាជ្ញាប័ណ្ណ។

ឃ. ផ្តល់សេរីភាពនៅក្នុងការទិញរូបិយប័ណ្ណបរទេស ឬការផ្ទេរប្រាក់ទៅបរទេសដែលទាក់ទងនឹងប្រតិបត្តិការវិនិយោគ។

ង. ផ្តល់ជូននូវសេរីភាពស្មើគ្នា ចំពោះវិនិយោគិនទាំងក្នុងស្រុក និងបរទេសដើម្បីធ្វើការប្រកួតប្រជែងគ្នាក្រោមលក្ខខ័ណ្ឌទីផ្សារសេរី។

ច. ផ្តល់ជូននូវការដោះស្រាយរាល់បញ្ហាដែលទាក់ទងនៅម៉ាក ប៉ាតង់ និងកម្មសិទ្ធិបញ្ញាផ្សេងៗទៀតទៅតាមច្បាប់នៃកម្មសិទ្ធិបញ្ញា។

ឆ. យោងទៅលើកិច្ចព្រមព្រៀងទ្វេភាគីរវាងកម្ពុជា និងបណ្តាប្រទេសក្នុងតំបន់អាស៊ានរាល់បណ្តាក្រុមហ៊ុនពហុជាតិ ឬក្រុមហ៊ុនផ្សេងៗទៀតមិនត្រូវបានដកហូតជាសម្បត្តិរបស់រដ្ឋឡើយ។ ការលើកលែងតែមួយ ប្រសិនបើមានការចាំបាច់ ដែលពាក់ព័ន្ធដល់ទ្រព្យសម្បត្តិសាធារណៈនោះក្រុមហ៊ុននោះ អាចនឹងត្រូវបានដកហូតធ្វើជាទ្រព្យសម្បត្តិរបស់រដ្ឋ តែក្រោមរូបភាពនៃការបង់សងផលប្រយោជន៍ត្រឡប់ទៅវិញ។

ជ. រាល់ជំលោះដែលទាក់ទងទៅនឹងការវិនិយោគ គួរតែត្រូវបានដោះស្រាយដំបូងបំផុតតាមរយៈនៃការចចារនៃភាគីជម្លោះ។ ករណីមិនទាន់មានភាពដាច់ស្រេទ្បះការដោះស្រាយអាចមានដល់កម្រិតខ្ពស់ជាងនេះ តាមរយៈការផ្សះផ្សារគ្នា ក្រោមរូបភាពការជួយជ្រោមជ្រែងពី CDC ឬបញ្ជូនសំណុំរឿងទៅតុលាការកម្ពុជា ឬទៅដល់មជ្ឈមណ្ឌលដោះស្រាយជម្លោះអន្តរជាតិ ដោយមានការព្រមព្រៀងពីភាគីទាំងសងខាង។

តាមរយៈនយោបាយ និងយុទ្ធសាស្ត្រដែលរដ្ឋាភិបាលបានប្រើប្រាស់ ដូចដែលបានលើកឡើងខាងលើយើងឃើញថា គេបានផ្តោតសំខាន់យ៉ាងសំខាន់ទៅលើ ការទាក់ទាញចំណាប់អារម្មណ៍របស់អ្នកវិនិយោគផ្ទាល់ពីបរទេស តាមរយៈការលើកទឹកចិត្តដោយពន្ធ (ពន្ធគយ និងពន្ធលើប្រាក់ចំនេញ)។

### ២.៣.៦. ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធ បរិយាយអំពីទ្រព្យបង្កើតឡើង ដែលអនុញ្ញាតឱ្យប្រទេសមួយ ដំណើរការ ដូចជាផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ព្រលានយន្តហោះ ប្រព័ន្ធគមនាគមន៍ អគ្គិសនី និងបណ្តាញចែកចាយទឹកស្អាត។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ របស់ក្រសួងផែនការ គូសបញ្ជាក់ពីទ្រព្យ និង

យុទ្ធសាស្ត្រហេដ្ឋារចនាសម្ព័ន្ធ របស់ប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន។[១២] (សេចក្តីព្រាងនៃផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣ ត្រូវបានចេញផ្សាយ ខណៈពេលដែលកំណែចុងក្រោយបង្អស់នៅខែមេសា

ឆ្នាំ២០១៩ នៅមិនទាន់បោះពុម្ពផ្សាយនៅឡើយ) ក្រសួងសាធារណការ និងដឹកជញ្ជូន មានភារកិច្ចអនុវត្តន៍គោលនយោបាយជាតិ ដែលគ្របដណ្តប់លើការសាងសង់ក្នុងការងារសាធារណការ ដូចជា ផ្លូវថ្នល់ ស្ពាន កំពង់ផែ ផ្លូវដែក និងផ្លូវទឹក។

ខណៈពេលដែលសង្គ្រាមរាប់សិបឆ្នាំ និងភាពវិកវរដែលកើតឡើងនៅចុងទសវត្សរ៍ឆ្នាំ ២០០០ បាននាំមកនូវការខូចខាតសន្ធឹកសន្ធាប់ដល់ហេដ្ឋារចនាសម្ព័ន្ធប្រទេស យ៉ាងណាមិញការស្តារឡើងវិញត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័សនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅក្នុងករណីខ្លះ ការមិនមានហេដ្ឋារចនាសម្ព័ន្ធពីមុននៅសេសសល់ក៏អាចជាគុណសម្បត្តិមួយដែរ ព្រោះថាប្រទេសកម្ពុជាអាចលោតផ្លោះពីបច្ចេកវិទ្យាចាស់ៗទាំងនោះ។ ដូចប្រសាសន៍របស់លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា ដែលបានថ្លែងថា "ខុសពីបណ្តាប្រទេសអភិវឌ្ឍន៍ជាភាគច្រើន កង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់បានធ្វើអោយប្រទេសកម្ពុជាកាន់តែងាយស្រួល ក្នុងការទទួលយកលទ្ធភាពបច្ចេកវិទ្យាថ្មីៗចុងក្រោយដោយគ្មានអ្វីជាឧបសគ្គនោះទេ។" [១៣]

- **ផ្លូវថ្នល់**

ប្រវែងផ្លូវសរុបនៅកម្ពុជា មាន ៤៧,២៦៣ គីឡូម៉ែត្រ ក្នុងនោះ ៧៤% ជាផ្លូវខេត្តនៅទីជនបទ។ គិតមកត្រឹម ឆ្នាំ២០១៣ ផ្លូវជាតិនិងផ្លូវខេត្ត ប្រវែង ១២,២៣៩ គីឡូម៉ែត្រ ត្រូវបានត្រួសត្រាយ។៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បង្ហាញពីផែនការរបស់រដ្ឋាភិបាល ក្នុងការកែលម្អ និងជួសជុលផ្លូវជនបទបន្ថែម ប្រមាណជា ៥,១៥០ គីឡូ ម៉ែត្រ នៅត្រឹមឆ្នាំ២០១៨។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមិនមានផ្លូវល្បឿនលឿនទេ។ យ៉ាងណាមិញ ផ្លូវល្បឿនលឿនមួយខ្សែដែលនឹងភ្ជាប់ពីភ្នំពេញទៅព្រះសីហនុត្រូវបានគ្រោងទុកអស់រយៈពេលជាច្រើនឆ្នាំមកហើយ ជាមួយគ្នានឹងគម្រោងមួយដែលមានការគាំទ្រពីប្រទេសកូរ៉េ ដែលបានប្រកាសកាលពីក្នុងឆ្នាំ២០១៥។[១៤] គម្រោងនេះមិនបានចេញជាលទ្ធផលអ្វីនោះទេ។ នៅក្នុងខែមិនា ឆ្នាំ២០១៩ គម្រោងមួយដែលគាំទ្រដោយប្រទេសចិនត្រូវ

[១២]ក្រសួងផែនការ, *" ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨"*, www.nis.gov.kh/index.php/km/

[១៣]ក្រសួងព័ត៌មាន, ថ្ងៃទី២២ ខែមិនា ឆ្នាំ២០១៩, *"ពិធីសម្ពោធការសាងសង់ផ្លូវល្បឿនលឿនដំបូងបង្អស់នៅកម្ពុជា"*

[១៤]រូប៊ីន ស្ពីស ២០១៧, *"ប្រទេសកម្ពុជាត្រូវប្រឈមនឹងបញ្ហាទ្វេដងស្តីពីផែនការស្ថាបនាផ្លូវថ្នល់"*, កាសែតភ្នំពេញប៉ុស្តិ៍, ចេញផ្សាយថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧, www.postkhmer.com/

បានប្រកាស ធ្វើឡើងក្រោមទម្រង់កិច្ចសន្យាសាងសង់-ប្រតិបត្តិការ-ផ្ទេរ ដែលម្ចាស់គម្រោងនឹងត្រូវតែប្រគល់ហេដ្ឋារចនាសម្ព័ន្ធនោះទៅកាន់ប្រទេសកម្ពុជាវិញទៅតាមលក្ខខណ្ឌ។ ផ្លូវល្បឿនលឿនដែលមានបួនទ្រូងផ្លូវត្រូវបានប៉ាន់ប្រមាណថានឹងត្រូវចំនាយថវិកាប្រមាណ ១,៩ ពាន់លានដុល្លារអាមេរិក។ ក្រុមហ៊ុន China Road and Bridge Corporation (CRBC) គឺជាក្រុមហ៊ុនដែលទទួលខុសត្រូវសាងសង់គម្រោងមួយនេះ។ ការទិញដីដែលត្រូវការសម្រាប់ស្ថាបនាផ្លូវមួយនេះកំពុងនៅបន្តធ្វើនៅឡើយនៅខែមិនា ឆ្នាំ២០១៩។

អ្នកនាំពាក្យនៅក្នុងសន្និសីទមួយកាលពីខែធ្នូ ឆ្នាំ២០១៧ ដែលស្ដីពីហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់បានរៀបរាប់ពីឧបសគ្គនានាទាក់ទងនឹងគុណភាពនៃការអភិវឌ្ឍផ្លូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ករណីភាគច្រើន គឺក្រុមអ្នកសាងសង់មិនមានបច្ចេកវិទ្យាទំនើប ហើយផ្លូវថ្នល់ជាញឹកញាប់ត្រូវបានសាងសង់ដោយក្រុមកម្មករមិនមានវិជ្ជាជីវៈ និងខ្វះការត្រួតពិនិត្យណែនាំ។ ″ នៅក្នុងសន្និសីទនោះត្រូវបានគេរាយការណ៍ថា ផ្លូវថ្នល់កម្ពុជា ៧០% ត្រូវបានផ្ដល់មូលនិធិដោយប្រទេសចិន ហើយជាញឹកញាប់គេប្រើប្រាស់វិធីសាស្ត្រសាងសង់ដែលមានតម្លៃទាប ដោយគ្រាន់តែក្រាលកំទេសថ្មស្តើងៗជាមួយនឹងកៅស៊ូនៅផ្នែកខាងលើ។

- **ផ្លូវដែក**

ប្រទេសកម្ពុជា មានបណ្ដាញផ្លូវដែកសំខាន់ៗ ២ ខ្សែ ដែលបណ្ដាញផ្លូវនៅភាគខាងជើងប្រវែង ៣៨៦ គីឡូម៉ែត្រ ភ្ជាប់រាជធានីភ្នំពេញ ជាមួយនឹងទីក្រុងប៉ោយប៉ែតដែលជាប់ព្រំប្រទល់នឹងប្រទេសថៃ តាមរយៈខេត្តពោធិសាត់ និងខេត្តបាត់ដំបង និងបណ្ដាញផ្លូវនៅភាគខាងត្បូងប្រវែង ២៦៦ គីឡូម៉ែត្រ តភ្ជាប់រាជធានីភ្នំពេញ ទៅខេត្តព្រះសីហនុ។ ការប្រើប្រាស់ប្រព័ន្ធផ្លូវដែក បានកើនឡើងខ្ពស់ នៅឆ្នាំ១៩៧០[១៥] ប៉ុន្តែ សង្គ្រាមស៊ីវិលដែលចេះតែបន្ត និងការមិនយកចិត្តទុកដាក់រាប់ទសវត្សរ៍ បានធ្វើឱ្យផ្លូវដែកស្ថិតក្នុងស្ថានភាពទ្រុឌទ្រោម។ សេវាផ្លូវដែក បានចាប់ផ្ដើមសារជាថ្មីឡើងវិញ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ប៉ុន្តែសេវាសម្រាប់អ្នកធ្វើដំណើរបានបញ្ចប់ នៅត្រឹមឆ្នាំ២០០៨។

នៅឆ្នាំ២០០៦ គម្រោងស្ដារផ្លូវដែកតម្លៃ ១៤៣លាន ដុល្លារអាមេរិក ត្រូវបានដាក់សម្ពោធដោយរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងការគាំទ្រពីម្ចាស់ជំនួយក្រៅប្រទេសជាច្រើន។ គម្រោងខ្សែផ្លូវដែកភាគខាងត្បូងត្រូវបានបញ្ចប់រួចរាល់ និងបើកបម្រើសម្រាប់ប្រតិបត្តិការដឹកជញ្ជូន នៅខែសីហា ឆ្នាំ២០១៣។[១៦] កាលពីដើមឆ្នាំ ២០១៦នេះ ខ្សែផ្លូវដែកភាគខាងត្បូងបានដាក់ឱ្យប្រើប្រាស់សម្រាប់ការដឹកជញ្ជូនប្រេងឥន្ធនៈ ផ្សូងថ្ម

[១៥] ចាប ម៉ូលី, "*ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក នៅកម្ពុជា: យុទ្ធសាស្ត្ររយៈពេលវែង*", ឯកសារពិភាក្សារបស់វិទ្យាស្ថានអភិវឌ្ឍសេដ្ឋកិច្ច លេខ ១៥០, វិទ្យាស្ថានអភិវឌ្ឍសេដ្ឋកិច្ច ឆ្នាំ២០០៨, www.efi.mef.gov.kh/៦១១៧/

[១៦] ហ៊ា គីមសាយ, "*ផ្លូវដែកសម្រាប់ការនាំអង្ករចេញរួចរាល់*", កាសែត ភ្នំពេញប៉ុស្តិ៍, ចុះផ្សាយ ៩ សីហា ២០១៥

ស៊ីម៉ង់ត៍ និងកុងតឺន័រសម្រាប់ដឹកជញ្ជូនតាមកាប៉ាល់ ដោយខ្សែរសេវាសម្រាប់អ្នកដំណើរ ត្រូវបានប្រកាសឱ្យដំណើរការនៅក្នុងឆ្នាំតែមួយ។

យ៉ាងនេះក្តី បញ្ហាតាំងទីលំនៅ ការប្រឈមនឹងការចំណាយលើស ទឹកជំនន់ និងបញ្ហាគុណភាពសំណង់ បានបណ្តាលឱ្យគម្រោងផ្លូវដែកភាគខាងជើងត្រូវពន្យារ។ នៅក្នុងខែកក្កដា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានសម្រេចផ្តល់ទឹកប្រាក់បន្ថែមចំនួន ៣៣ លាន ដុល្លារអាមេរិក ដើម្បីឱ្យការជួសជុលខ្សែផ្លូវ-ដែកភាគខាងជើងអាចបញ្ចប់នៅត្រឹមឆ្នាំ២០១៧ បន្ទាប់ពីធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារជំនួយអភិវឌ្ឍន៍អូស្រ្តាលី ដែលជាដៃគូគម្រោង បានច្រានចោលសំណើសុំផ្តល់មូលនិធិបន្ថែម។

នៅក្នុងខែមេសា ឆ្នាំ២០១៩ ប្រព័ន្ធផ្លូវដែកប្រទេសកម្ពុជា និងប្រទេសថៃ ត្រូវបានតភ្ជាប់គ្នាឡើងវិញនៅក្បែរក្រុងប៉ោយប៉ែត បន្ទាប់ពីពីបានកាត់ផ្តាច់គ្នាកាលពីក្នុងឆ្នាំ ១៩៧៤។ នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានមានវត្តមាននៅក្នុងពិធីសម្ពោធ និងបានធ្វើដំណើរឆ្លងកាត់ព្រំប្រទល់តាមរយៈរថភ្លើងនោះជាមួយគ្នាផងដែរ។

ក្រុមហ៊ុន Royal Railway ទទួលបានសម្បទានផ្តាច់មុខលើប្រតិបត្តិការផ្លូវដែកនៅកម្ពុជារយៈពេល ៣0ឆ្នាំ ប៉ុន្តែនៅខែមិនា ឆ្នាំ២០១៩ រដ្ឋាភិបាលបានដកហូតសម្បទាននោះមកវិញ។ សេវានេះត្រូវបានដាក់ដំណើរការបណ្តោះអាសន្នដោយក្រសួងសាធារណការ និងដឹកជញ្ជូន។ រដ្ឋាភិបាលជឿថា ក្រុមហ៊ុនមិនបានវិនិយោគលើផ្លូវរថ និងឧបករណ៍ដទៃទៀតឱ្យឆ្លើយតបទៅនឹងតម្រូវការដែលកំពុងកើនឡើងនៅក្នុងប្រទេស។

រដ្ឋាភិបាលនៃប្រទេសកម្ពុជា បានបង្ហាញចេតនាកសាងបណ្តាញផ្លូវដែកបន្ថែមទៀត ហើយប្រទេសថៃ ប្រទេសជប៉ុន និង ប្រទេសចិន បានបង្ហាញពីចំណាប់អារម្មណ៍ ក្នុងការធ្វើកិច្ចការលើគម្រោងទាំងនេះសំដៅពង្រីកសេវាផ្លូវដែកឆ្លងកាត់តាមប្រទេសកម្ពុជា។[១៧]

- **ផ្លូវទឹក និងកំពង់ផែ**

ប្រវែងផ្លូវទឹកនៃប្រទេសកម្ពុជា មានប្រមាណជា ១,៧៥0 គីឡូម៉ែត្រ ក្នុងនោះ ៨៥0 គីឡូម៉ែត្រ អាចធ្វើចរាចរបាន នៅក្នុងរដូវប្រាំង។

កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាផែអន្តរជាតិសមុទ្រទឹកជ្រៅ និងជាកំពង់ផែពាណិជ្ជកម្មតែមួយគត់របស់ប្រទេសកម្ពុជា។ កំពង់ផែនេះគ្របដណ្តប់នៅលើផ្ទៃដី ១២៥ ហិកតា។ អស់រយៈពេលប្រាំឆ្នាំ ពី ២០១៤-២០១៨ ចំនួនកុងតឺន័រដែលផ្ទុកនៅកំពង់ផែនេះបានកើនឡើងជាមធ្យម ១១ % ក្នុងមួយឆ្នាំៗ។ [១៨]

[១៧] ក្រសួងសាធារណការ និងដឹកជញ្ជូន, *"ទិដ្ឋភាពទូទៅនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន នៅព្រះរាជាណាចក្រកម្ពុជា"* បោះពុម្ពលើកទី៤, របាយការណ៍ប្រចាំឆ្នាំ, រាជធានីភ្នំពេញ: ក្រសួងសាធារណការ និងដឹកជញ្ជូន ឆ្នាំ២០១៣

[១៨] សមាគមអ្នកសាងសង់កម្ពុជា ថ្ងៃទី៧ ខែមិនា ឆ្នាំ២០១៩, *"ប្រទេសជប៉ុននឹងផ្តល់កម្ចី ២០៩លានដុល្លារដើម្បីពង្រីកផែសមុទ្រទឹកជ្រៅក្រុងព្រះសីហនុ"*

នៅដើមឆ្នាំ ២០១៩នេះ កំពង់ផែមានជម្រៅ ១១ ម៉ែត្រ ហើយអាចផ្ទុកបាន ៤,៥៦០ កុងតឺន័រ យ៉ាងណាមិញកំពង់ផែននេះក៏មានផែនការដើម្បីបង្កើនចំនួនផ្ទុកកុងទីន័ររបស់ខ្លួនបន្ថែមទៀតផងដែរ។ ការពង្រីកនេះនឹងផ្តល់នៅចំណតថ្មីមួយទៀត ដែលមានជម្រៅរហូតដល់ ១៤,៥ ម៉ែត្រជាមួយនឹងទំហំ៣៥០ ម៉ែត្រ ដែលអាចទទួលផ្ទុកកាប៉ាល់បានជាង ៩០%នៃកាប៉ាល់ទាំងឡាយនៅក្នុងតំបន់។ គម្រោងនេះនឹងបញ្ចប់នៅក្នុងឆ្នាំ ២០២៣។ គម្រោងនេះនឹងធ្វើអោយកំពង់ផែព្រះសីហនុ ក្លាយជាកំពង់ផែស្តង់ដារមធ្យមជាមួយនឹងសមត្ថភាពផ្ទុកច្រើនជាង ១,២៩ លាន TEUs ក្នុងមួយឆ្នាំ[១៩] (នៅចុងឆ្នាំ ២០១៨ សមត្ថភាពផ្ទុកមានទំហំ ៥៣៧,១០៧ TEUs។

នៅក្នុងឆ្នាំ ២០១៨ ទំហំផ្ទុកសរុបនៃកំពង់ផែព្រះសីហុបានកើនឡើង រហូតដល់ ៥,១ លានតោន ស្មើនឹងកំណើន ១៨ % ដែលក្នុងនោះ ៣,៨ លានតោនជាទំហំទំនិញនាំចេញ ហើយ ១,៣ លានតោនជាទំហំទំនិញនាំចូល។

មានការលើកឡើងថា កំពង់ផែសមុទ្រនៃប្រទេសកម្ពុជា គឺជាកំពង់ផែមានតម្លៃសេវាថ្លៃបំផុតនៅអាស៊ី។ នៅក្នុងឆ្នាំ ២០១៩ រដ្ឋាភិបាលកម្ពុជាបាននិយាយថា ខ្លួននឹងធ្វើការកាត់បន្ថយតម្លៃសេវាដើម្បីឱ្យកំពង់ផែព្រះសីហនុអាចប្រកួតប្រជែងនៅក្នុងទីផ្សារ។

កំពង់ផែស្វយ័តភ្នំពេញរបស់រដ្ឋ នៅស្រុកកៀនស្វាយនៃទឹកដីខេត្តកណ្តាល ដែលមានចម្ងាយ ៣០ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ គឺជាកំពង់ផែធំបង្អស់ទី២ របស់កម្ពុជា។ នៅខែមករា ឆ្នាំ២០១៣ កំពង់ផែ បានបើកឱ្យដំណើរការ ស្ថានីយកុងតឺន័រ តម្លៃ២៨លាន ដុល្លារអាមេរិក ក្រោមជំនួយថវិកាពីរដ្ឋាភិបាលនៃប្រទេសចិន។ ផលិតផលសម្លៀកបំពាក់ និងកសិកម្ម (ជាពិសេសស្រូវអង្ករ) គឺជាទំនិញនាំចេញឆ្លងកាត់កំពង់ផែនេះ ខណៈដែលសម្ភារៈសំណង់ គ្រឿងម៉ាស៊ីនប្រើក្នុងវិស័យកសិកម្ម វត្ថុធាតុដើមសម្រាប់ឧស្សាហកម្មវាយនភ័ណ្ឌ និងសម្លៀកបំពាក់ និងទំនិញប្រើប្រាស់ គឺជាផលិតផលនាំចូលសំខាន់ៗ។

ក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ ២០១៣មក ចរាចរណ៍កុងតឺន័រឆ្លងកាត់កំពង់ផែភ្នំពេញបានកើនឡើងជាមធ្យម ១៤,៤ %ក្នុងមួយឆ្នាំ។[២០]

នៅក្នុងដំណាក់កាលទី១ និងទី២ នៃការអភិវឌ្ឍ កំពង់ផែនេះបានបង្កើនសមត្ថភាពផ្ទុករបស់ខ្លួនបានរហូតដល់ ៣០០,០០០ TEUs ក្នុងរយៈពេលមួយឆ្នាំ។ នៅដំណាក់កាលទី៣នៃការពង្រីកបន្ថែមនេះ មានគោលបំណងបង្កើនសមត្ថភាពផ្ទុកកុងតឺន័រឱ្យបានរហូតដល់ ៥០០,០០០ TEUs ក្នុងមួយឆ្នាំ។

---

[១៩] ជា វណ្ណៈ ២០១៩, *"ចរាចរណ៍កុងតឺន័រតាមផ្លូវសមុទ្រមានការកើនឡើងខ្លាំង"*, កាសែតខ្មែរថាមស៍ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៩

[២០] ហ៊ិន ពិសី ២០១៨, *"ការពង្រីកកំពង់ផែភ្នំពេញដើម្បីជម្រុញការដឹកជញ្ជូនតាមផ្លូវទឹកនៅក្នុងប្រទេសកម្ពុជា"* កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨

កំពង់ផែស្វួតភ្នំពេញ គឺជាកំពង់ផែទឹកទន្លេ ដែលមានចម្ងាយ ៣៣០គីឡូម៉ែត្រ ពីសមុទ្រ។ កប៉ាល់ផ្ទុកទំនិញនៅទីនេះ អាចបម្រើដល់គោលដៅអន្តរជាតិជាច្រើន ដូចជា ប្រទេសសិង្ហបុរី ជាដើម។ ផែសមុទ្រតូចៗដទៃទៀត នៅខេត្តកោះកុង និងខេត្តកំពត ត្រូវបានប្រើសម្រាប់កាប៉ាល់តូចៗ។ កំពង់ផែទន្លេ ដូចជានៅខេត្តកំពង់ចាម បម្រើឱ្យកាប៉ាល់ក្នុងស្រុកប៉ុណ្ណោះ។

- **ការដឹកជញ្ជូនតាមផ្លូវអាកាស**

ប្រទេសកម្ពុជាបច្ចុប្បន្ននេះ មានអាកាសយានដ្ឋានអន្តរជាតិ ៣កន្លែង នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ បើទោះបីជាអាកាសយានដ្ឋាននៅខេត្តព្រះសីហនុ ទទួលបានជើងហោះហើរអន្តរជាតិតិចតួច។ អាកាសយានដ្ឋានទាំងនេះ ត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា ដែលមានភាគហ៊ុន ៧០% កាន់កាប់ដោយក្រុមហ៊ុនបារាំង Vinci និងភាគហ៊ុន ៣០% ជារបស់ក្រុមហ៊ុនវិនិយោគរួមគ្នាម៉ាឡេស៊ី-កម្ពុជា Muhibbah Masteron Cambodia។

នៅខែតុលា ឆ្នាំ២០១៧ មានសេចក្តីរាយការណ៍មួយបានឱ្យដឹងថា ក្រុមហ៊ុនចិន Yunnan Investment Holding Ltd នឹងធ្វើការស្ថាបនាអាកាសយានដ្ឋានអន្តរជាតិថ្មីមួយនៅលើផ្ទៃដីទំហំ ៧០០ ហិកតាស្ថិតនៅក្នុងស្រុកសូត្រនិគម ចំហាយប្រមាណ ៥០គីឡូម៉ែត្រពីក្រុងសៀមរាប។ កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងក្នុងទម្រង់សម្បទាន សាងសង់-ប្រតិបត្តិការ-ផ្ទេរ (BOT) រយៈពេល ៥៥ ឆ្នាំ។[២១]

នៅខែកុម្ភៈ ឆ្នាំ២០១៩ គណៈកម្មាធិការរដ្ឋាភិបាលត្រូវបានបង្កើតដើម្បីកំណត់ទីតាំងដើម្បីសាងសង់អាកាសយានដ្ឋានទីពីរនៅរាជធានីភ្នំពេញ។ គណៈកម្មាធិការនេះមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាប្រធាន និងមានសមាជិកចំនួន ២៣ រូបទៀតដែលមកពីក្រសួង និងស្ថាប័នរដ្ឋាភិបាលនានា។ ក្រសួងព័ត៌មានបានធ្វើការប៉ាន់ប្រមាណថា អាកាសយានដ្ឋានថ្មីនេះនឹងត្រូវចំនាយថវិកាប្រហែល ១,៥ ពាន់លានដុល្លារអាមេរិក ហើយការសាងសង់នឹងចំនាយដោយក្រុមហ៊ុន Cambodia Airport Investment Co., Ltd. ដោយមានការសហការរួមគ្នាជាមួយនឹងក្រុមហ៊ុន Overseas Cambodian Investment Corporation (OCIC) និងរដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិលដែលជាស្ថាប័នរដ្ឋាភិបាល។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ការងារកែលម្អសំខាន់ៗជាច្រើនត្រូវបានធ្វើឡើងនៅគ្រប់អាកាសយានដ្ឋានទាំងអស់។ ស្ថានីយអ្នកដំណើរនៅឯអាកាសយានដ្ឋានព្រះសីហនុត្រូវបានពង្រីករហូត ៨០% (សព្វថ្ងៃនេះវាមានទំហំ ៤,៨០០ ម៉ែត្រក្រឡា) និងត្រូវបានជួសជុលទាំងស្រុង។ ការងារបន្ទាប់នឹងរួមបញ្ចូលការពង្រីកផ្លូវរត់រហូតដល់ ៨០០ ម៉ែត្រ ដើម្បីអោយផ្លូវរត់នេះមានប្រវែងពេញលេញ ៣,៣ គីឡូម៉ែត្រ។ ការងារនេះនឹង

[២១] ជា វណ្ណៈ, *"លោកនាយករដ្ឋមន្ត្រីប្រកាសពីការសាងសង់អាកាសយានដ្ឋានថ្មីនៅខេត្តសៀមរាប"*, កាសែតខ្មែរថាមស៍ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧, www.khmertimeskh.com/

អនុញ្ញាតឱ្យអាកាសយានដ្ឋានអាចនឹងទទួលបានជើងយន្តហោះពីខាងក្រៅ និងនៅតំបន់អាស៊ានបានកាន់តែច្រើនជាងមុន។

ឆ្នាំ២០១៧ ជាឆ្នាំដែលត្រូវបានជាប់កំណត់ត្រាថាជាឆ្នាំដែលមានកំណើនអាកាសចរណ៍ប្រចាំឆ្នាំកើនខ្លាំងបំផុត ដែលចំនួនអ្នកធ្វើដំណើរបានឈានរហូតដល់ ៨,៧៨៦,៨០០នាក់ ដែលស្មើនឹងកំណើន ២៥ % បើធៀបទៅនឹងឆ្នាំ ២០១៦ ដែលមានចំនួនអ្នកធ្វើដំណើរ ៧,០២៣,៧៨០នាក់។

គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ អ្នកធ្វើដំណើរមកដល់អាកាសយានដ្ឋានទាំងបីក្នុងរយៈពេលមួយឆ្នាំនេះមានចំនួនរហូតដល់ ១០ លាននាក់។

ការដឹកជញ្ជូនទំនិញតាមអាកាស មានកំណើន ៣៥ % ដែលកើនបាន ៦៥,០០០ តោននៅឆ្នាំ ២០១៧ ហើយចរាចរណ៍ជើងហោះហើរវិញ មានកំណើន ២២% កើនបាន ៩០,២០០ជើង។ កំណើននៃចំនួនអ្នកធ្វើដំណើរនៅឯអាកាសយានដ្ឋានព្រះសីហនុបានកើនឡើងគួរឱ្យភ្ញាក់ផ្អើល។ ការមកដល់នៃភ្ញៀវទេសចរណ៍បរទេសនៅក្នុងខែមិថុនា ឆ្នាំ២០១៦ មាន ៤៦១នាក់ សម្រាប់ឆ្នាំ ២០១៧ ខែដដែល មានចំនួន ៤,១៤១ នាក់ ហើយនីឆ្នាំ ២០១៨ មានចំនួន ១៤,១៣០ នាក់។៣៥មានការប្រកួតប្រជែងខ្លាំងរវាងក្រុមហ៊ុនអាកាសចរណ៍ ក្នុងនោះមានក្រុមហ៊ុនចំនួន ៦ ដែលកំពុងបម្រើសេវាហោះហើរផ្លូវពីភ្នំពេញទៅកាន់ខេត្តសៀមរាប ក្រុមហ៊ុន ៥ សម្រាប់ការហោះហើរពីសៀមរាបទៅកាន់ខេត្តព្រះសីហនុ និង ក្រុមហ៊ុន ៦ ទៀតបម្រើសេវាហោះហើរពីភ្នំពេញទៅកាន់ខេត្តហ្គ័ងចូវ ប្រទេសចិន។

ប្រទេសកម្ពុជាមានក្រុមហ៊ុនអន្តរជាតិដែលផ្តល់សេវាហោះហើរចំនួន ៣០ ហើយក្នុងចំនោមក្រុមហ៊ុនទាំងនោះ មានក្រុមហ៊ុនចំនួន ១០ ដែលជាក្រុមហ៊ុនមកពីប្រទេសចិន។[២២]

### ២.៣.៧. សម្បូរភាពពលកម្ម និងកម្រិតប្រាក់ឈ្នួលទាប

កម្លាំងពលកម្ម ជាធាតុចូល (Input) មួយក្នុងការផលិតទំនិញ និងសេវាកម្ម។ ពលកម្មជាសក្តានុពលមួយដែលអ្នកវិនិយោគសំឡឹងមើល ដើម្បីធ្វើការវិនិយោគ។ ជាក់ស្តែងភាពសម្បូរនៃពលកម្មនៅកម្ពុជា រួមទាំងកម្រិតនៃប្រាក់ឈ្នួលទាប ធ្វើអោយកម្ពុជាអាចទាក់ទាញអ្នកវិនិយោគបរទេសមកធ្វើការវិនិយោគនៅក្នុងស្រុក។

[២២] មជ្ឈមណ្ឌលអាកាសចរណ៍ CAPA, *"ព្រលានយន្តហោះភ្នំពេញ ជាអាកាសយានដ្ឋានល្អបំផុតទាក់ទងនឹងកំណើន"*, កាសែតភ្នំពេញប៉ុស្តិ៍, ចុះផ្សាយថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៩, www.postkhmer.com/

តារាងទី៣៖ ចំនួនពលកម្មនៅកម្ពុជាក្នុងចន្លោះឆ្នាំ ២០០៩-២០១៤

| **វិស័យ** | **២០០៩** | **២០១៤** | **ប្រែប្រួល** |
|---|---|---|---|
| ពលកម្មសរុប(គិតជាពាន់នាក់) | ៧.៤៦៩ | ៨.២៣៥ | ៧៦៦ |
| កសិកម្ម | ៤.៣០២ | ៣.៧៣០ | -៥៧២ |
| ឧស្សាហកម្ម | ១.១៨៨ | ២.០០១ | ៨១៤ |
| សេវាកម្ម | ១.៩៧៩ | ២.៥០៣ | ៥២៤ |
| ភាគទានកម្លាំងពលកម្មតាមវិស័យនីមួយៗ(%) | | | |
| **វិស័យ** | **២០០៩** | **២០១៤** | **ប្រែប្រួល** |
| កសិកម្ម | ៥៧,៦ | ៤៥,៣ | -១២,៣ |
| ឧស្សាហកម្ម | ១៥,៩ | ២៤,៣ | ៨,៤ |
| សេវាកម្ម | ២៦,៥ | ៣០,៤ | ៣,៩ |
| សរុប | ១០០,០ | ១០០,០ | |

ប្រភព៖ Cambodia Social Economic Survey Oct ២០១៥

ក្នុងកំឡុងរយៈពេល ៥ឆ្នាំ ពោលគឺ ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៤ កម្លាំងពលកម្មនៅកម្ពុជាបានកើនឡើង ៧៦៦ពាន់នាក់ ដោយកើនពី ៧.៤៦៩ពាន់នាក់ (២០០៩) ទៅដល់ ៨.២៣៥ពាន់នាក់(២០១៤) ដោយការកើននេះមានល្បឿនលឿនជាងកំណើនប្រជាជន[២៣]។ ប៉ុន្តែកម្លាំងពលកម្មក្នុងវិស័យកសិកម្មបានធ្លាក់ចុះពី ៥៧,៦% នៅត្រឹម ៤៥,៣% ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៤។ ចំណែកឯវិស័យឧស្សាហកម្ម និងសេវាកម្មបានកើនឡើង។ ក្នុងនោះ កម្លាំងពលកម្មវិស័យឧស្សាហកម្មបានកើនឡើងពី ១៥,៩% ទៅដល់ ២៤,៣% ដែលក្នុងកំឡុងនោះ វិស័យឧស្សាហកម្មបានបង្កើតការងារចំនួន ០,៥លានការងារ។ រីឯ វិស័យសេវាកម្មបានកើនឡើងពី ២៦,៥% ដល់ ៣០,៥% ដែលបានបង្កើតការងារក្នុងកំឡុង៥ឆ្នាំនោះបាន ០,៨ លានការងារ។ បើក្រឡេកទៅមើលប្រាក់ឈ្នួលរបស់ពលកម្មកម្ពុជាមានកម្រិតទាបជាងប្រទេសមួយចំនួន ជាពិសេសបណ្តាប្រទេសក្នុងតំបន់អាស៊ីដូចជា ប្រទេសថៃ ចិន និងវៀតណាមជាដើម។

តារាងទី៤៖ ការប្រើធៀបថ្លៃ FDI លើប្រាក់ឈ្នួលក្នុងប្រទេសកម្ពុជា ថៃ និងម៉ាឡេស៊ី ២០២២

| ប្រាក់បៀវត្សប្រចាំខែ ($/ខែ) | **ប្រទេស** | **កម្ពុជា** | **ថៃ** | **ម៉ាឡេស៊ី** |
|---|---|---|---|---|
| | ប្រាក់ឈ្នួលអប្បបរមាតាមច្បាប់ | ១៩៤ | ២៦៩ | ២៩៦ |

ប្រភព៖ កែសម្រួលពី អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា *“សេចក្តីសង្ខេបយន្តការកំណត់ប្រាក់ឈ្នួលផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងសមិទ្ធិផលសម្រេចបាន”*, ឆ្នាំ២០២២

តាមទិន្នន័យខាងលើយើងឃើញថា ប្រាក់ឈ្នួលពលកម្មនៅកម្ពុជាមានកម្រិតទាបជាងប្រទេសថៃ និងម៉ាឡេស៊ី។ បើតាមការស្ទាបស្ទង់មតិនៃការសិក្សាទៅលើរោងចក្ររបស់ក្រុមសិក្សាទិន្នន័យរបស់កម្ពុជាបានអោយដឹងថា ប្រាក់ឈ្នួលពលកម្មរបស់កម្ពុជា ត្រឹមតែ ១៩៤ ដុល្លារអាមេរិកក្នុងមួយខែដែលទាបជាងប្រទេសថៃគឺ ២៦៩ ដុល្លារអាមេរិក និងម៉ាឡេស៊ីចំនួន ២៩៦ ដុល្លារអាមេរិក នាឆ្នាំ២០២២នេះ។ អាស្រ័យលើប្រាក់ឈ្នួលកម្រិតទាបនេះហើយ ដែលអនុញ្ញាត្តិអោយកម្ពុជាមានភាពទាក់ទាញ FDI និងជាទីកន្លែងវិនិយោគដ៏ប្រសើរដែលវិនិយោគិនបរទេស ធ្វើការពិចារណា និងធ្វើការវិនិយោគ។

កត្តាទាំងអស់នេះហើយ ដែលមានឥទ្ធិពលទៅលើការទាក់ទាញ FDI មកធ្វើការវិនិយោគនៅកម្ពុជា។ បើតាមលោក អាឡាសាន សូ ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំកម្ពុជា បានមានប្រសាសន៍ថាកម្ពុជាមានការរីកចម្រើនក្នុងការជម្រុញធ្វើអោយបរិយាកាសផ្នែកធុរកិច្ច មានលក្ខណៈកាន់តែប្រសើរជាងមុនតាមរយៈការជម្រុញកត្តាដែលបានរៀបរាប់ខាងលើ។

[២៣] ធនាគារពិភពលោក, World Bank, *“Cambodia Economic Update”*, ២០១៦, www.worlbank.com

# ជំពូកទី ៣
# ស្ថានភាពទូទៅនៃ
# វិស័យវាយនភ័ណ្ឌ
# នៅប្រទេសកម្ពុជា

# ជំពូកទី ៣

# ស្ថានភាពទូទៅនៃវិស័យវាយនភ័ណ្ឌនៅប្រទេសកម្ពុជា

## ៣.១. ទិដ្ឋភាពទូទៅនៃវិស័យកាត់ដេរនៅប្រទេសកម្ពុជា

វិស័យកាត់ដេរសម្លៀកបំពាក់នៅកម្ពុជា ជាវិស័យសំខាន់មួយដែលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈការនាំចេញនិងផ្តល់ការងារធ្វើដល់មនុស្សរាប់សែននាក់។ ឧស្សាហកម្មកាត់ដេរបានចាប់ផ្តើមដំណើរការ ខ្លាំងនៅកម្ពុជាតាំងតែពីចុងទស្សវត្ស៩០ហើយ តាំងពីពេលនោះមកវាបាន និងកំពុងដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចកម្ពុជាទាំងមូល។

វិស័យឧស្សាហកម្មកាត់ដេរមិនគ្រាន់តែចូលរួមបង្កើនកំណើនសេដ្ឋកិច្ចជាតិ និងបង្កើតការងារសម្រាប់ប្រជាជនកម្ពុជា ចូលរួមមបង្កើតការងារពាក់ព័ន្ធ និងការងារបំពេញ អោយគ្នាប៉ុណ្ណោះទេ តែវាក៏ជាវិស័យមួយយ៉ាងសំខាន់បំផុតក្នុងការប្រមូល យកនូវរូបិយវត្ថុអន្តរជាតិសម្រាប់បម្រើដល់ការនាំចូលសម្ភារៈបរិក្ខានានា ដែលមានប្រយោជន៍ សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិតាមរយៈការនាំចេញរបស់ខ្លួន។

វិស័យផលិតកម្មនៅកម្ពុជាត្រូវបានត្រួតត្រាដោយការផលិតសម្លៀកបំពាក់ និងស្បែកជើងដែលមានចំនួន ៧៤% នៃការនាំចេញទំនិញប្រចាំឆ្នាំ។ យោងតាមអគ្គនាយកដ្ឋានគយ និងរដ្ឋាករក្រោមក្រសួង- សេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាន ឲ្យដឹង ថាព្រះរាជាណាចក្រកម្ពុជាបាននាំចេញ នូវផលិតផលសម្លៀកបំពាក់ និងស្បែកជើងដែលមានតម្លៃជិត ៨ ពាន់លានដុល្លារក្នុងរយៈពេល ៩ ខែដំបូងនៃឆ្នាំ ២០១៩ ពោលគឺកើនឡើង ១៣ % បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៨ ។ ភាគច្រើននៃការនាំចេញ ទាំងនេះត្រូវបានដឹកនាំនៅ ផ្សារអឺរ៉ុបតែមួយសហរដ្ឋអាមេរិក និងជប៉ុន។ វិស័យកាត់ដេរ នៅតែជាក្បាលម៉ាស៊ីនដ៏សំខាន់ ចំពោះកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដែលផ្តល់ការងារដល់មនុស្សចំនួន ៦០៥,១២៩ នាក់ នៅក្នុងរោងចក្រកាត់ដេរ និងស្បែកជើងចំនួន ៦២៦ នៅចុងឆ្នាំ ២០១៦ ។[២៤] ការនាំចេញសរុបមានចំនួន ៧,៣ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៦ ដែលមានចំនួន ៧៨% នៃការនាំចេញទំនិញរបស់កម្ពុជា។ប្រហែល ៦៥% នៃសម្លៀកបំពាក់ និងស្បែកជើងបាននាំចេញទៅកាន់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិច ប៉ុន្តែការនាំចេញទៅកាន់ទីផ្សារដទៃទៀតក៏បានកើនឡើងយ៉ាងខ្លាំងដែរ។ ការនាំចេញទៅប្រទេសកាណាដាមានត្រឹមតែ ០,៥ ភាគរយនៃការនាំចេញសរុបនៅក្នុងឆ្នាំ ២០១០ ប៉ុន្តែបានកើនឡើងដល់ ៨ ភាគរយនៅឆ្នាំ ២០១៦ ។ ការនាំចេញទៅប្រទេសជប៉ុនមានត្រឹមតែ ២,៧ ភាគរយនៅក្នុងឆ្នាំ ២០១០ ប៉ុន្តែបានកើនឡើងដល់ ៩ ភាគរយនៅឆ្នាំ ២០១៦ ប្រទេសចិនគឺជាវិនិយោគបរទេសដ៏សំខាន់នៅក្នុងរោងចក្រសំលៀកបំពាក់និងស្បែកជើងនៅកម្ពុជា។

[២៤] អង្គការពលកម្មអន្តរជាតិ, *"ព្រឹត្តិបត្រព័ត៌មានវិស័យកាត់ដេរនិងស្បែកជើងនៅកម្ពុជា"* លេខ ៦ ។ បោះពុម្ពខែ ឧសភា ឆ្នាំ២០១៧

រូបភាពទី៣៖ ការនាំចេញសំលៀកបំពាក់និង ស្បែកជើងនៅកម្ពុជាពីឆ្នាំ២០០០-២០១៨ (គិតជាលានដុល្លា)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១៩

វិស័យកាត់ដេរបានក្លាយជាសសរស្តម្ភមួយនៃសេដ្ឋកិច្ចកម្ពុជា ទោះបីជាវិស័យនេះបានរងផលប៉ះ-ពាល់ដោយសារជំងឺរាតត្បាតក៏ដោយ។ របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជានៅឆ្នាំ ២០១៩ និយាយថាការនាំចេញសម្លៀកបំពាក់បានកើនឡើង ១១ ភាគរយក្នុងឆ្នាំ ២០១៨ បើប្រៀបធៀបទៅនឹងឆ្នាំកន្លងទៅ ខណៈរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្មបានចង្អុលបង្ហាញពីការថយចុះ ១០,២ ភាគរយពី ៨ ២៦៦,៣៥ លានដុល្លារក្នុងឆ្នាំ ២០១៩ មក ៧ ៤២០,២៨ លានដុល្លារនៅឆ្នាំ ២០២០។[២៥] ជំងឺរាតត្បាតបានបណ្តាលឱ្យរោងចក្រមួយចំនួនបិទដែលជះឥទ្ធិពលអវិជ្ជមានទាំងការនាំចេញ និងការងារ ទោះបីជាកម្មករកាត់ដេរនៅតែទទួលបាន ៧០ ដុល្លារក្នុងមួយខែក៏ដោយ។ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) បានប្រកាសនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២១ ថាប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់សហរដ្ឋ-អាមេរិក (GSP) ដែលអនុញ្ញាតឱ្យកម្ពុជាទទួលបានអត្ថប្រយោជន៍ពីអត្រាពន្ធទាបបានផុតកំណត់នៅថ្ងៃទី

[២៥] ធនាគារជាតិនៃកម្ពុជា, "*របាយការណ៍ប្រចាំឆ្នាំ២០១៩*", www.nbc.org.kh/english/

៣១ ខែធ្នូ ឆ្នាំ២០២០។ ប្រទេសចំនួន ១១៩ នឹងត្រូវបង់ពន្ធនាំចូលផ្អែកលើ Most Favored Nation (MFN) ដែលជាប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្មមួយដែលផ្តល់លទ្ធភាពអោយបង់ពន្ធក្នុងកម្រិតទាប។ ប្រធានសហ-ភាពការងារកម្ពុជា (CLC) លោក អាត់ ធន់ មានប្រសាសន៍ថា "សម្រាប់ប្រទេសកម្ពុជា ផលិតផលកាត់ដេរដែលស្ថិតក្រោម MFN ត្រូវបានបង់ពន្ធពី ១២ ទៅ ៣៣ ភាគរយ" ។

វិស័យវាយនភ័ណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប មានរោងចក្រ សហគ្រាស និងកម្មករនិយោជិតតិចតួច នៅពេលកម្ពុជាបានចាប់ផ្តើមបើកសេដ្ឋកិច្ចរបស់ខ្លួន និងទទួលវិនិយោគចាប់ពីឆ្នាំ១៩៩៣ និងបានបន្តកើនឡើងជាបន្តបន្ទាប់រហូតមក ជាពិសេសចាប់ពីឆ្នាំដែលកម្ពុជាទទួលបានសន្តិភាពពេញលេញដោយសារនយោបាយ ឈ្នះ-ឈ្នះ របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ហើយបន្ទាប់មកគឺនៅក្រោយឆ្នាំ១៩៩៩ ពេលដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក ដោយផ្សាភ្ជាប់ពាណិជ្ជកម្មជាមួយបទដ្ឋានការងារអន្តរជាតិ។ គិតត្រឹមចុងឆ្នាំ២០២១ នេះ រោងចក្រ សហគ្រាសដែលបានចុះបញ្ជីផ្លូវការក្នុងវិស័យនេះបានកើនដល់ប្រមាណជាង ១២០០ រោងចក្រដែលផ្តល់ការងារក្នុងប្រព័ន្ធ ដល់កម្មករនិយោជិតប្រមាណជិត ១ លាននាក់។[២៦]

ជាក់ស្តែងនៅក្នុងឆ្នាំ ២០២១ ទឹកប្រាក់នាំចេញសរុបនៃវិស័យនេះមានប្រមាណជិត ១០ ពាន់លាន-ដុល្លារអាម៉េរិក ឬប្រមាណ ៦៣ ភាគរយ នៃទឹកប្រាក់នាំចេញសរុបរបស់កម្ពុជា។ ដោយឡែកជីវភាពកម្មករនិយោជិត ក៏បានប្រសើរឡើងជាលំដាប់ដោយការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល តាមរយៈការតម្លើងប្រាក់ឈ្នួលអប្បបរមាជាបន្តបន្ទាប់។ បើគិតចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានដំឡើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតបានចំនួន ១៨លើក ដោយកើនពី ៤០ដុល្លារអាម៉េរិកសម្រាប់ឆ្នាំ ១៩៩៧ ដល់ ១៩៤ដុល្លារអាម៉េរិកសម្រាប់ឆ្នាំ២០២២។ សម្រាប់ឆ្នាំ២០២២នេះ ដោយបូករួមទាំងប្រាក់រង្វាន់អតីតភាពការងារ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗ អាចទទួលបានប្រាក់ឈ្នួលចាប់ពី ២១១ដុល្លារអាម៉េរិក ទៅ ២២២ដុល្លារអាម៉េរិក ក្នុងមួយខែ។ ក្រៅពីកម្មករនិយោជិតប្រមាណជិត ១លាននាក់ ដែលទទួលផលផ្ទាល់ មានប្រជាពលរដ្ឋប្រមាណជាង ២លាននាក់ដែលទទួលផលដោយប្រយោលពីវិស័យនេះ។

[២៦] ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា, "*វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ជាវិស័យទ្រទ្រង់សេដ្ឋកិច្ច និងនាំចេញសំខាន់ជាងគេរបស់កម្ពុជា*", ចេញផ្សាយថ្ងៃទី ១៧ មករា ២០២២

### ៣.១.១. ការវិវត្តនៃទំនាក់ទំនងទីផ្សារនាំចេញសម្លៀកបំពាក់របស់កម្ពុជា

ផលិតផលឧស្សាហកម្មកាត់ដេរកម្ពុជា បានទទួលការអនុគ្រោះជាច្រើនពីទីផ្សារប្រទេសអភិវឌ្ឍន៍នានាដូចជា សហរដ្ឋអាមេរិក ប្រទេសកាណាដា និងសហភាពអឺរ៉ុបជាដើម។ តាមឯកសាររបស់លោក Yoko Asuyama និងSeiha Neou តាំងពីឆ្នាំ១៩៩៦ ដែលកម្ពុជាបានទទួល Status ជា Most Favored Nation (MFN) ពីសហរដ្ឋអាមេរិក ហើយក្រោយមកទទួលបានពីសហភាពអឺរ៉ុបតាមរយៈប្រព័ន្ធអនុគ្រោះទូទៅ (Generalized System of Preferences:GSP)។[២៧] ក្រោយមកនៅឆ្នាំ១៩៩៩ កម្ពុជាទទួលបាននូវការអនុគ្រោះជា MFN/GSP ពីបណ្តាប្រទេសចំនួន២៨ផ្សេងទៀត។ ក្រោយៗមកក៏មានការផ្តល់កូតានាំចូលសម្លៀកបំពាក់ពីសហរដ្ឋអាមេរិកតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្ម វាយនភ័ណ្ឌ និងសម្លៀកបំពាក់ដល់ប្រទេសកម្ពុជាហើយ សហភាពអឺរ៉ុបបានលើកលែងពន្ធ និងកូតាសម្រាប់ពីសមាជិកទាំងឡាយរបស់អង្គការពាណិជ្ជកម្មពិភពលោក បន្ទាប់ពីកម្ពុជាបានចូលជាសមាជិកអង្គការនេះនៅឆ្នាំ ២០០៤ ដែលខណៈ ពេលផងដែរនោះ កូតាដែលសហរដ្ឋអាមេរិកបានផ្តល់អោយកម្ពុជាត្រូវបាន ដកចេញ។

កិច្ចព្រមព្រៀង ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន (AJCEP) ត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ២០០០។ ប្រទេសជប៉ុនបានលុបចោល ៩២% នៃអត្រាពន្ធលើសម្លៀកបំពាក់ និងវាយនភ័ណ្ឌពីបណ្តាប្រទេសអាស៊ាន។

តាមរយៈបទបង្ហាញរបស់លោក Ken Loo[២៨] ដែលជាអគ្គលេខាធិកានៃសមាគមរោងចក្រកាត់ដេរកម្ពុជា កាលពីខែតុលា ឆ្នាំ២០១២ បានបង្ហាញថាប្រទេសកាណាដាតាំងតែពីឆ្នាំ២០០២ បានលុបបំបាត់របាំងពន្ធគយ និងកូតាដល់ទៅ៩៩% សម្រាប់ការនាំចូលផលិតផលនានា ក្នុងនោះរួមមានផលិតផលវាយនភ័ណ្ឌ និងសម្លៀកបំពាក់ពីប្រទេសកំពុងអភិវឌ្ឍន៍នានា តាមរយៈកម្មវិធីពន្ធគយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍របស់ខ្លួន។ បន្ទាប់មកនៅក្នុងឆ្នាំ ២០១៥-២០១៧ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) អនុញ្ញាតឱ្យកម្ពុជានាំចេញទំនិញ ទៅកាន់ប្រទេសចិនក្នុងអត្រាទាបបំផុត (ស្ទើរតែសូន្យភាគរយនៃពន្ធនាំចូល) ។

ជាក់ស្តែងនៅថ្ងៃទី១២ សីហា ២០២០ កម្ពុជាត្រូវបានដកផ្នែកខ្លះនៃ EBA(២០%) ពីសហភាពអឺរ៉ុប។ ហើយនូវដើមឆ្នាំ ២០២១ កម្ពុជាបានទទួលប្រព័ន្ធអនុគ្រោះពន្ធហៅកាត់ថា GSP

[២៧] Yoko Asuyama និងSeiha Neou ,"*Firm dynamics in the Cambodian garment industry*", ឆ្នាំ ២០១២, ទំព័រទី០៤
[២៨] Ken Loo, "*Cambodia's garment industry*", តុលា ២០១២

ពីចក្រភពអង់គ្លេសសម្រាប់នាំ ទំនេញគ្រប់ប្រភេទ លើកលែងតែអាវុធ និងគ្រឿងផ្ទុះ ដោយមិនជាប់ពន្ធ និងមិនជាប់ការកំរិតកូតាក្រោយពីការអនុគ្រោះនេះ។ មន្ត្រីរដ្ឋាភិបាល អ្នកក្នុងវិស័យកាត់ដេរ និងវិស័យវិនិយោគ រំពឹងថា ប្រព័ន្ធអនុគ្រោះពន្ធ GSP នេះ នឹងមិនត្រឹមតែជួយជំរុញទំនិញកាន់តែច្រើននាំចេញពីកម្ពុជាប៉ុណ្ណោះទេ តែថែមទាំងជួយបំពេញបន្ថែម នូវការបាត់បង់ផ្នែកខ្លះ នៃ EBA នៅទីផ្សារអឺរ៉ុប ជាពិសេសជួយទាក់ទាញវិនិយោគបន្ថែមចូលមកកម្ពុជា ដើម្បី ផលិត កែច្នៃ និងវេចខ្ចប់ នាំចេញទៅទីផ្សារចក្រភពអង់គ្លេស។ លោកឧកញ៉ា លឹម ហេង អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានបញ្ជាក់ថា ប្រព័ន្ធអនុគ្រោះទូទៅ ជាការជម្រុញលើកទឹកចិត្តដល់អ្នកវិនិយោគ និងជាការទាក់ទាញអ្នកវិនិយោគថ្មីៗបន្ថែម ឲ្យមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា តាមរយៈការផ្តល់នូវលក្ខណៈពិសេស។ លោកឧកញ៉ា បន្តថា GSP នឹងជំនួសការបាត់បង់ ក្នុងប្រព័ន្ធអនុគ្រោះពន្ធ EBA ដែលសហភាពអឺរ៉ុប សម្រេចដកចេញពីកម្ពុជា។[២៩]

កម្ពុជានាំចេញផលិតផលទៅចក្រភពអង់គ្លេស មានដូចជា ផលិតផលសំលៀកបំពាក់ ស្បែកជើង អង្ករ និងកង់ ខណៈនាំចូលមកវិញ មានដូចជា រថយន្ត និងគ្រឿងចក្រជាដើម។

ក្នុងឆ្នាំ២០១៩ ការដោះដូរពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងអង់គ្លេស មានទឹកប្រាក់សរុបជាង ១ ពាន់លានដុល្លារអាមេរិក។ ចំណែកនៅក្នុងរយៈពេល ៣ខែ ឆ្នាំ ២០២០ កម្ពុជាបាននាំចេញ សរុបជាង ២០០ លានដុល្លារ ក្នុងនោះការនាំចេញវិស័យកាត់ដេរជាង ១៩០ លានដុល្លារ និងទំនិញផ្សេងៗ ១៥ លានដុល្លារអាមេរិក។

### ៣.១.២. ចំណែកទីផ្សារ និងទំហំនាំចេញផលិតផលសម្លៀកបំពាក់របស់ ប្រទេសកម្ពុជា

ស្ថានភាពនៃការនាំចេញវិស័យកាត់ដេរ រួមជាមួយផលិតផលឧស្សាហកម្មផ្សេងៗទៀត បានហក់ឡើងខ្ពស់ខណៈដែលការនាំចូលវិស័យវាយនភណ្ឌបានធ្លាក់ចុះ។

អគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញឲ្យដឹងថា នៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ នេះ ស្ថានភាពមុខទំនិញ នៃការនាំចេញពីកម្ពុជា ក្នុងនោះ វិស័យកាត់ដេរ បានហក់ឡើងខ្ពស់ដល់ប្រមាណជិត ១៣ ម៉ឺនបីលានរៀល ខណៈឆ្នាំ២០១៨ មានត្រឹមជាង ១១ ម៉ឺនលានរៀល។

វិស័យកាត់ដេរនៅកម្ពុជាបានបង្ហាញពីដំណើរការល្អទាំងផ្នែកផលិតកម្ម ការនាំចេញ និងកំណើននៃការបញ្ជាទិញ ខណៈដែលការនាំចូលក្រណាត់សម្រាប់ផលិតសម្លៀកបំពាក់កើនឡើងជាង ២៥%។ យោងតាមបច្ចុប្បន្នភាពសេដ្ឋកិច្ចចុងក្រោយរបស់ធនាគារពិភពលោកសម្រាប់កម្ពុជា ក្នុងរយៈពេលប្រាំបួនខែដំបូងនៃឆ្នាំនេះ កម្ពុជាបាននាំចូលសម្លៀកបំពាក់ប្រមាណ ៣.៥ ពាន់លានដុល្លារអាមេរិក កើនឡើងជាង ២៥% ។

[២៩] ក្រសួងព័ត៌មាន ,“ *បទយកការណ៍៖ ក្រោមប្រព័ន្ធអនុគ្រោះពន្ធ GSP របស់អង់គ្លេស កម្ពុជានឹងទទួលបានប្រយោជន៍ច្រើនក្នុងការនាំចេញ*”, ចេញផ្សាយ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២០

លោក កាំង ម៉ូនីកា អគ្គលេខាធិការរងសមាគមរោងចក្រកាត់ដេរកម្ពុជា ត្រូវបានសារព័ត៌មានក្នុងស្រុកដកស្រង់សម្តីដោយបញ្ជាក់ថា ការកើនឡើងនៃការនាំចូលវត្ថុធាតុដើមសម្រាប់ផលិតសម្លៀកបំពាក់នៅឆ្នាំនេះ គឺស្របទៅនឹងកំណើននៃការនាំចេញសម្លៀកបំពាក់ និងផលិតផលធ្វើដំណើរ។

លោកបាននិយាយទៀតថា កំណើនក្នុងវិស័យនីមួយៗមានភាពខុសគ្នាបន្តិចបន្តួចដោយវិស័យសម្លៀកបំពាក់ត្រូវបានមើលឃើញថាមានកំណើនទាបបំផុតប្រហែល ៥% ក្នុងរយៈពេល ៩ ខែដំបូងនៃឆ្នាំនេះ ប៉ុន្តែវិស័យស្បែក ជើងកើនឡើងប្រហែល ១៥% ហើយសម្រាប់ផលិតផលធ្វើដំណើរក៏មានកំណើនខ្លាំងបន្ថែមទៀតជាង ៣០០% បើធៀបនឹងឆ្នាំមុន។ ជាទូទៅ សម្លៀកបំពាក់គឺជាផលិតផលដែលមានកំណើនទាប ហើយយើងត្រូវមានការប្រកួតប្រជែងខ្លាំងជាមួយប្រទេសផ្សេងទៀត ជាពិសេសបង់ក្លាដែស និងវៀតណាម។

លោកបានបន្ថែមថា បើប្រៀបធៀបទៅនឹងឆ្នាំមុនក្នុងឆ្នាំ ២០២១ ស្ថានភាពនៃវិស័យកាត់ដេរនៅកម្ពុជាមានភាពប្រសើរឡើង ដោយសារផលិតកម្មមានស្ថិរភាព ដែលនាំឱ្យមានការនាំចេញកើនឡើង ខណៈដែលការបញ្ជាទិញសម្រាប់ឆ្នាំនេះកើនឡើងច្រើនជាងឆ្នាំមុន។

ការនាំចូលទៅសហរដ្ឋអាមេរិកបានបន្តកើនឡើង បើទោះបីជា GSP មិនទាន់មានសុពលភាពក៏ដោយ។ ទន្ទឹមនឹងនេះ រោងចក្រដែលបានផ្អាកការផលិតកាលពីដើមឆ្នាំបានដំណើរការផលិតឡើងវិញជាធម្មតា។

យោងតាមរបាយការណ៍ចុងក្រោយរបស់ធនាគារពិភពលោក ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិកបានកើនឡើង ៣១.៩% ដល់ ៣.៤ ពាន់លានដុល្លារក្នុងខែកញ្ញា ឆ្នាំ ២០២១ ទោះបីជា GSP មិនទាន់ត្រូវបានពិនិត្យសុពលភាពឡើងវិញក៏ដោយ។

យោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងរយៈពេល៩ខែដំបូងនៃឆ្នាំ ២០២១ ការនាំចេញសម្លៀកបំពាក់មានចំនួន ៨.២៤ ពាន់លានដុល្លារ កើនឡើងប្រហែល ៨៤៣.៤ លានដុល្លារ ឬស្មើ ១១.៤% បើធៀបនឹងរយៈពេល ៩ខែក្នុងឆ្នាំ២០២០។

រូបភាពទី៤៖ សកម្មភាពនៅរោងចក្ររបស់កម្មករ



ប្រភព៖ ទាញពី GMAC កម្ពុជា

រូបភាពទី៥៖ ចំណែកទីផ្សារនាំចេញផលិតផលសម្លៀកបំពាក់របស់កម្ពុជា ឆ្នាំ២០១២ (គិតជាភាគរយ)




ប្រភព៖ កែសម្រួលពី GMAC (២០១៣) "*consolidated Data for Garment and Textile Export*", www.gmac-cambodia.org/imp-exp/garment.php

តាមរយៈទិន្នន័យបានពីសមាគមរោងចក្រកាត់ដេកម្ពុជា យើងឃើញថា ចំណែកទីផ្សារសហរដ្ឋ-អាមេរិកមានចំណែកច្រើនជាងគេនៅឆ្នាំ២០១២(ដូចមានបង្ហាញក្នុងរូបទី៣.២) គ្រាន់តែនៅឆ្នាំ២០១២ ទំហំ-ទីផ្សារមាន៤៥% ដែលមានទំហំនាំចេញដល់ទៅ ១៩៩៩.០៣ លានដុល្លាអាមេរិក និងតាមពីក្រោយដោយសហភាពអឺរ៉ុប (៣៣% ស្មើនិង ១៤៥៤.០២លានដុល្លាអាមេរិក) ប្រទេសកាណាដា (៩% ស្មើនិង ៤០៧.៧០លានដុល្លាអាមេរិក) ប្រទេសជប៉ុន (៣% ស្មើនិង ១៤០.៧០លានដុល្លាអាមេរិក) និងទីផ្សារដទៃទៀត (១០% ស្មើនិង៤៤៧.២០លានដុល្លាអាមេរិក)។

រូបភាពទី៦៖ ការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើងឆ្នាំ២០០០-២០១៦ (លានដល្លារ)




ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឆ្នាំ២០១៧

### ៣.១.៣. វិនិយោគទុនក្នុងវិស័យឧស្សាហកម្មកាត់ដេរ

តាមរយៈការបើកចំហរទីផ្សារពាណិជ្ជកម្ម និងវិនិយោគបរទេស និងតាមរយៈការដែលសហរដ្ឋអា-មេរិកបាន ផ្តល់កូតានាំចូលផលិតផលសម្លៀកបំពាក់ទៅក្នុងទីផ្សារសហរដ្ឋអាមេរិកដល់កម្ពុជាមូលធនពីបរទេសបានហូរចូលមកទីផ្សារកម្ពុជាជាបន្តបន្ទាប់ ជាពិសេសទាក់ទងទៅនឹងវិស័យឧស្សាហកម្មកាត់ដេរក្នុងគោលដៅផលិតផលិតផលសម្លៀកបំពាក់សម្រាប់បំរើការនាំចេញទៅទីផ្សារបរទេស (Amakawa, ២០១០ ,p.០៩)។ ប្រទេសកម្ពុជា ជាប្រទេសដែលមានរបបវិនិយោគបរទេសសេរី និងបើកចំហ ដោយមាន

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយគាំទ្រវិនិយោគិន។ ការលើកទឹកចិត្តវិនិយោគត្រូវបានផ្តល់ដល់វិនិយោគិនបរទេស រួមមាន ៖ សិទ្ធិកាន់កាប់ក្រុមហ៊ុន ១០០ ភាគរយ ការលើកលែងពន្ធសាជីវកម្មរហូតដល់ ៨ ឆ្នាំ អត្រាពន្ធសាជីវកម្ម ២០ ភាគរយ (បន្ទាប់ពីរយៈពេលលើកទឹកចិត្តត្រូវបានបញ្ចប់) ការលើកលែងពន្ធនាំចូលលើទំនិញជាមូលធន (capital goods) និងពុំមានការហាមឃាត់លើការដកដើមទុនវិនិយោគត្រឡប់ទៅវិញ។ ដូចនេះ វិស័យកាត់ដេរនៅ កម្ពុជាបានពឹងពាក់ស្ទើរតែទាំងស្រុងលើវិនិយោគ ផ្ទាល់ពីបរទេស។ នៅឆ្នាំ១៩៩៤ ក្រុមហ៊ុនទីមួយដែលវិនិយោគនៅកម្ពុជាក្នុងវិស័យកាត់ដេរ សម្រាប់បំរើការនាំចេញ គឺក្រុមហ៊ុនមកពីហុងកុង ម៉ាឡេស៊ី សិង្ហបុរី និងតៃវ៉ាន់ (Dasgupta, Poutianen, &Williams,២០១១,p.០២) ក្រោយមកក៏មាន វិនិយោគពីប្រទេសម៉ាឡេស៊ីនិង តៃវ៉ាន់បានកើនឡើងបន្ថែមពីឆ្នាំ១៩៩៦ នៅពេលទំនាក់ទំនង ពាណិជ្ជកម្មសហរដ្ឋអាមេរិក និងកម្ពុជាមានភាពល្អប្រសើរ ពេលដែលក្រុមហ៊ុនរបស់កូរ៉េខាងត្បូង បានចាប់ផ្តើមនៅឆ្នាំ១៩៩៧ និងក្រុមហ៊ុនចិនបានធ្វើប្រតិបត្តិការនៅចុងទសវត្សន៍១៩៩០ និងដើមឆ្នាំ២០០០(Amakawa,២០១០,p.៤១)។

ក្នុងឆ្នាំ២០០៤ នៅក្នុងចំណោមក្រុមហ៊ុនវិនិយោគក្នុងវិស័យកាត់ដេរដែលជារបស់បរទេស មាន៨០% គឺជារបស់ចិន ហុងកុង និងតៃវ៉ាន់ (Amakawa,២០១០,p.៤២)។

រូបភាពទី៧៖ ភាគរយនៃម្ចាស់រោងចក្រឧស្សាហកម្មកាត់ដេរនៅកម្ពុជា(២០១០)




ប្រភព៖ កែសម្រួលពី GMAC (២០១៣) consolidated Data for Garment and Textile Export, www.gmac-cambodia.org

យោងតាមលទ្ធផលអង្កេតនៃសហគ្រាសកាត់ដេរសម្លៀកបំពាក់ចំនួន ៥០ វិនិយោគផ្ទាល់បរទេសមានចំនួន ៤៥៤ លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ។ សហគ្រាសទាំងនេះបានផ្តល់ការងារ

ចំនួនប្រមាណ ៨០.០០០ នាក់ ឬស្មើនឹង ១៤ ភាគរយ នៃចំនួននិយោជិតសរុបនៅក្នុងវិស័យនេះ។ ការវិនិយោគរបស់ប្រទេសចិនមានទំហំដល់ទៅ ៣៨៣ លានដុល្លារអាមេរិក បន្ទាប់មកប្រទេសកូរ៉េខាងត្បូង ( ៣៣ លានដុល្លារអា-មេរិក) ប្រទេសសិង្ហបុរី (១០ លានដុល្លារអាមេរិក) ប្រទេសម៉ាឡេស៊ី (១០ លានដុល្លារ-អាមេរិក) ប្រទេសថៃ (៨ លានដុល្លារអាមេរិក) ចក្រភពអង់គ្លេស (៨ លានដុល្លារអាមេរិក) និងសហរដ្ឋ-អាមេរិក (២ លានដុល្លារអាមេរិក) ដែលមានបង្ហាញនៅក្នុងរូបភាពទី១៨ ខាងក្រោម។

រូបភាពទី៨៖ FDI លើវិស័យកាត់ដេរសំលៀកបំពាក់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

(គិតជាលានដុល្លាអាមេរិក)




ប្រភព៖ កែសម្រួលពី ធនាគារជាតិកម្ពុជា, www.nbc.org.kh

### ៣.១.៤. អំពីរោងចក្រកាត់ដេរ

ចំនួនរោងចក្រកាត់ដេរតាំងតែពីពេលដែលឧស្សាហកម្មកាត់ដេរមានដំណើរការ នៅកម្ពុជាមានកំណើនជាលំដាប់ពី ២០ រោងចក្រនៅឆ្នាំ១៩៩៥ ទៅច្រើនជាង ២០០ រោងចក្រនៅឆ្នាំ២០០៤(គណៈកម្មាធិការសហប្រតិបត្តិដើម្បីកម្ពុជា, តុលា ២០០៥, p. ០៨) និង ទៅដល់ ៣០៩ រោងចក្រនៅឆ្នាំ២០១១ (Asuyama & Neou, ២០១២, p. ២៦) ដូចមានបង្ហាញក្នុងរូបបន្ថែមក្នុងឧបសម្ព័ន្ធទី៦។ តាមឯកសាររបស់ប៉ះពាល់សហប្រតិបត្តិការដើម្បីកម្ពុជា (តុលា ២០០៥, p. ០៨) បានឲ្យដឹងថា ជាទូទៅរោងចក្រកាត់ដេរនៅកម្ពុជាពន្យារពេលប្រតិបត្តិការ ឬក៏បិទរោងចក្រតែម្តង ទើបគេពិបាកនឹងរាប់ឲ្យបានចំនួនពិតប្រាកដនៃរោងចក្រ ដែលធ្វើប្រតិបត្តិការតាមពេលវេលានីមួយៗ។ របាយការណ៍ខាងលើបានបន្ថែមថា ដោយគ្រាន់តែពីពាក់កណ្តាលទសវត្សរ៍១៩៩០ មកដល់ឆ្នាំ ២០០៤ មានរោងចក្រ៥៦បានបិទទ្វារ។ នេះអាចបញ្ជាក់ថា ចំនួនរោងចក្រសរុបដែលត្រូវបានបង្កើតឡើងអាចមានដល់ទៅជាង២៥០នៅឆ្នាំ២០០៤។ ម្យ៉ាងទៀត ទោះជាមានចំនួន

រោងចក្រផ្លូវការ និងដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ជាច្រើន តែវានៅតែមានរោងចក្រសាខាជាច្រើនដែលបានផ្តល់នូវសមត្ថភាពកាត់ដេរបន្ថែម និងជួយផ្គត់ផ្គង់ដល់រោងចក្រផ្លូវការនានានៅខណៈណាដែលមានតម្រូវការកើនឡើងជាបន្ទាន់ (NEAK, S. & YEM, S., ០៧ កក្កដា ២០០៦, p. ០៤;គណៈកម្មាធិការសហប្រតិបត្តិដើម្បីកម្ពុជា, តុលា ២០០៥, p. ០៩)។ តាមរបាយការណ៍ទាំងពីរដដែលក៏បានបង្ហាញថា ភាគច្រើនគឺមានទីតាំងនៅទីក្រុងភ្នំពេញ និងតំបន់នៅជុំវិញ។ ក្រៅពីនេះ មានរោងចក្រក្រៅផ្លូវការមួយចំនួនទៀតដែលធ្វើប្រតិបត្តិការនៅតាមបណ្តាខេត្តភាគពាយ័ព្យ និងដែលបាននឹងកំពុងតែធ្វើប្រតិបត្តិការផលិតសម្រាប់នាំចេញទៅទីផ្សារប្រទេសថៃ។ ដូចដែលបានរៀបរាប់ពីខាងលើរួចមកហើយថា ភាគច្រើននៃម្ចាស់រោងចក្រកាត់ដេរនៅកម្ពុជា គឺមកពី ប្រទេសចិន ហុងកុង តៃវ៉ាន់ និងកូរ៉េ ហើយដែលផលិតកម្មទាំងអស់ គឺក្នុងគោលដៅបំរើដល់ការនាំចេញ នេះមានន័យថាការដែលជនបរទេសកាន់កាប់រោងចក្រ ១០០% នោះរាល់ការសម្រេចចិត្តជាយុទ្ធសាស្ត្រទាំងអស់ គឺត្រូវបានធ្វើឡើងនៅការិយាល័យកណ្តាលនៅប្រទេសកម្ពុជា ដែលជាការបង្ហាញថាកាលណាកម្ពុជាមានលក្ខខណ្ឌមិនអំណោយផល ឬមានការកើនឡើងកម្រិតប្រកួតប្រជែង និងចំណាយនានា នោះវិនិយោគិននឹងពុំសូវមានគ្រឿងលើកទឹកចិត្តក្នុងការរក្សារោងចក្រនៅកម្ពុជានោះទេ។ រោងចក្រកាត់ដេរនៅកម្ពុជាភាគច្រើន ស្ទើរតែទាំងអស់ជារោងចក្រដែលធ្វើប្រតិបត្តិការក្នុងកម្រិតតម្លៃបន្ថែមទាប ត្រឹមថ្នាក់មូលដ្ឋាន ដែលអនុវត្តតាមគំរូ CMT (Cut-Make-Trim) គឺមានន័យថា រោងចក្រភាគ-ច្រើនធ្វើប្រតិបត្តិការដោយគ្រាន់តែ កាត់ ដេរ និងតែងលម្អសម្លៀកបំពាក់តាមការតម្រូវរបស់អ្នកទិញប៉ុណ្ណោះ (Natsuda, Goto និង Thoburn, ២០០៩, p. ១៥; Asuyama, Y. &Neou, S., ២០១២, p.០២; Zakir Hossain, ២០១០, p. ១១) មានន័យថា គឺអ្នកទិញជាអ្នកសម្រេចចិត្តទាំងម៉ូតដែលត្រូវរចនា ទាំងបរិមាណស-ម្លៀកបំពាក់ដែលត្រូវដេរ ហើយរោងចក្រមានតួនាទីត្រឹមតែដេរឲ្យបានតាមការតម្រូវនោះប៉ុណ្ណោះ។ ប្រតិបត្តិការបែបនេះវាទាមទារនូវកម្រិតហិរញ្ញវត្ថុ និងបច្ចេកវិទ្យាតិចតួច ហើយជាទូទៅ វាមិនអាចរកបានប្រាក់ចំណេញខ្ពស់ដូចដំណាក់កាលដទៃទៀតនៃផលិតកម្មទេ (Dasgupta, Poutianen, & Williams, ២០១១, p. ២៤)។ ការងារក្រោយពីកាត់ដេរ និងវេចខ្ចប់ គឺគ្រាន់តែបញ្ជូនទំនិញទៅឲ្យអ្នកទិញបន្ទាប់ដែលភាគច្រើននៅអាស៊ីខាងកើត ហើយដែលពួកនេះទាក់ទងចរចា និងដឹកជញ្ជូន ចែកចាយផ្ទាល់ទៅឲ្យអ្នកទិញនៅអាមេរិក និងអឺរ៉ុបជាដើម។ តែក៏មានប្រហែលជា១ភាគ៤ក្នុងចំណោមរោងចក្រទាំងអស់ ដែលធ្វើប្រតិបត្តិការពេញលេញ ដែលរួមមាននូវប្រតិបត្តិការរាប់តាំងពី ទិញក្រណាត់ ដេ និងវេចខ្ចប់ហើយដឹកជញ្ជូនដល់អ្នកលក់ដុំ លក់រាយផ្ទាល់ ក្រៅពីនោះ ១៥% ជារោងចក្រមៅការបន្ត ហើយក្នុងចំណោមរោងចក្រទាំងអស់ដែលមានប្រតិបត្តិការផ្សេងៗគ្នានោះ មានរោងចក្រជាង៨០%ដែលធ្វើប្រតិបត្តិការតិចជាង១០ឆ្នាំនៅកម្ពុជា (Dasgupta, Poutianen, & Williams, ២០១១, p.២២,៤៤)។ រោងចក្រដែលមានប្រតិបត្តិការនៅកម្ពុជា គឺមានលក្ខណៈខុសគ្នាពីរោងចក្រនៅ

វៀតណាម និងបង់ក្លាដេស ពីព្រោះ រោងចក្រនៅកម្ពុជាធ្វើការនាំចូលក្រណាត់ និងបរិក្ខារផងទៀត ដូចជាអំបោះជាដើម ពីបរទេសសម្រាប់ផលិតកម្មរបស់ខ្លួន ដូចជាមកពីប្រទេសចិន តៃវ៉ាន់ ហុងកុង កូរ៉េខាងត្បូង និងប្រទេសអាស៊ាន (Asuyama, Y. & Neou, S., ២០១២, p. ០២; Zakir Hossain,២០១០, p. ១១; Neak, S. & Yem, S., ២០០៦, p.០៣; Dasgupta, S., Poutiainen, T. &Williams, D., ២០១១, p. ២៤) ហើយដោយគ្រាន់តែក្នុងឆ្នាំ២០១០-២០១១ ក្រណាត់នាំចូលមានដល់ទៅជាង ២.២៥៣ពាន់លានម៉ែត្រ (Zakir Hossain, ២០១០, p. ១១)។ គិតតាមទំហំរោងចក្រ ជាទូទៅរោងចក្រមានបីប្រភេទខុសគ្នា ដែលក្នុងនោះរោងចក្រដែលមានទំហំតូចមានកម្មករត្រឹម ២០០នាក់ រោងចក្រមានទំហំមធ្យមមានកម្មករជាមធ្យមចំនួន ១០០០នាក់ ហើយរោងចក្រដែលមានទំហំធំមានកម្មករអាចដល់ទៅ ៥០០០នាក់ (Asuyama, Y &Neou, S., ០៩, p. ០; Omar Bargawi, ០០, p. ០៥; Dasgupta, S., Poutiainen, T. &Williams, D., ២០១១, p. ៤៣, គណៈកម្មាធិការសហប្រតិបត្តិដើម្បីកម្ពុជា, តុលា ២០០៥, p. ០៩)។

### ៣.១.៥. ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភ័ណ្ឌ

ប្រាក់ឈ្នួលអប្បបរមា ត្រូវបានឲ្យនិយមន័យថា ជាប្រាក់ឈ្នួលមួយដែលនិយោជកមិនអាចបន្ទាបកម្រិត វាបាន ហើយកម្រិតរបស់វាត្រូវបានកំណត់ និងធានាដោយច្បាប់ (បណ្ឌិត កងច័ន្ទតារារ័ត្ន និង លីវ ដាណែត, ៣០ កញ្ញា ២០០៩, p, ១៧)។ ប្រាក់ឈ្នួលអប្បបរមាជាឧបករណ៍គោលនយោបាយទូទៅមួយដ៏សំខាន់ ដែលត្រូវបានប្រើប្រាស់ស្ទើរតែក្នុងបណ្តាប្រទេសទាំងអស់នៅលើពិភពលោក។ បើតាមការសិក្សាស្រាវជ្រាវរបស់បណ្ឌិត កង ច័ន្ទតារារ័ត្ន និង លីវ ដាណែត អំពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ឧស្សាហកម្មកាត់ដេរកម្ពុជា (កញ្ញា ២០០៩, p. ១៧) បានឲ្យដឹងថា ក្នុងកំឡុងពេលពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៧ ប្រាក់ឈ្នួលអប្បបរមានៅក្នុងពិភពលោកបានកើនឡើងជាមធ្យម ៥.៧% ក្នុងមួយឆ្នាំ ដែលក្នុងនោះ នៅក្នុងប្រទេសជឿនលឿន កម្រិតប្រាក់ឈ្នួល អប្បបរមាមានកំណើនជាង ៣.៨% ក្នុងមួយឆ្នាំ និង៦.៥% ក្នុងមួយឆ្នាំ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ ប្រាក់ឈ្នួលអប្បបរមាពិតជាមានភាពចាំបាច់សម្រាប់វិស័យសេដ្ឋកិច្ច ជាពិសេសវិស័យកាត់ដេរ ដោយសារតែក្នុងវិស័យនេះ គឺវាមានភាពងាយរងគ្រោះជាងគេ ពីព្រោះតែវាជាវិស័យដែលទាមទារប្រើប្រាស់កម្លាំងពលកម្មច្រើន ដូចនេះ ការធានានូវនិរន្តរភាព និងការសម្រេចបាននូវការបំពេញតម្រូវការចាំបាច់នានាដូចជា ម្ហូបអាហារ ការស្នាក់នៅ និងសម្លៀកបំពាក់ គឺមានភាពចាំបាច់ដែលអ្នកអនុវត្តនយោបាយសេដ្ឋកិច្ច និងសង្គមត្រូវតែមានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់។ ទៀតសោត ចំពោះឧស្សាហកម្មកាត់ដេរ ដូចនៅកម្ពុជា ដែលជាវិស័យឧស្សាហកម្មមួយនាំមុខ និងដែលភាគច្រើនធ្វើប្រតិបត្តិការសម្រាប់បម្រើការនាំចេញ ប្រាក់ឈ្នួល អប្បបរមាកាន់តែមានភាពចាំបាច់ទៅទៀតដើម្បីធានានូវសុខុមាលភាពសង្គមក្នុងកម្រិតមួយ នៅពេលពិភពលោកមានវិបត្តិ ជាពិសេសដូចកាលពីវិបត្តិហិរញ្ញវត្ថុ

ពិភពលោកក្នុងឆ្នាំ២០០៨ និង ២០០៩នោះ។ ម្យ៉ាងទៀត ដែលសំខាន់ទៅទៀតនោះ គឺប្រាក់ឈ្នួលអប្បបរមាក៏ជាឧបករណ៍មួយសម្រាប់ជួយកាត់បន្ថយនូវគម្លាតនៃការបែងចែកផលកំណើនសេដ្ឋកិច្ចរបស់ជាតិផងដែរ។ បើតាមរបាយការណ៍របស់ NEAK Samsen និង YEM Sokha (កក្កដា ២០០៦, p. ១០) ការសិក្សាស្រាវជ្រាវរបស់បណ្ឌិត កង ច័ន្ទតារារ័ត្ន និង លី ដាណែត អំពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ឧស្សាហកម្មកាត់ដេរកម្ពុជា កញ្ញា ២០០៩, ០៧) និងតាមរយៈសៀវភៅរបស់Dasgupta, Poutiainen និង Williams (២០១១, p.០៣) បានបង្ហាញថា តាំងតែពីឆ្នាំ១៩៩៧ មកដែលច្បាប់ការងាររបស់កម្ពុជាបានអនុម័ត និងបានផ្តល់សិទ្ធិដល់ក្រសួងការងារក្នុងការកំណត់កម្រិតប្រាក់ឈ្នួលអប្បបរមាសម្រាប់ការងារគ្រប់វិស័យទាំងអស់ ប៉ុន្តែតាំងតែពីពេលនោះមក គេឃើញមានតែឧស្សាហកម្មវាយនភ័ណ្ឌសម្លៀកបំពាក់ និងស្បែកជើងប៉ុណ្ណោះដែលមានការកំណត់ប្រាក់ឈ្នួលអប្បបរមា។ ជាលទ្ធផល ប្រាក់ឈ្នួលអប្បបរមាសម្រាប់ផ្នែកនេះត្រូវបានបន្តកើនឡើងជាបន្តបន្ទាប់ពី ៤០ដុល្លារអាម៉េរិក ក្នុងមួយខែ នៅឆ្នាំ១៩៩៧ (មុនយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា) ទៅដល់ ១៤៥ដុល្លារអាម៉េរិក ក្នុងមួយខែ នៅឆ្នាំ២០១៥ (ពេលចាប់ផ្តើមយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា) និងត្រូវបានដំឡើងដល់ ១៩៤ដុល្លារអាម៉េរិក ក្នុងមួយខែ សម្រាប់ឆ្នាំ២០២២ និងបន្តរក្សាអត្ថប្រយោជន៍ផ្សេងៗ របស់កម្មករនិយោជិតនៅដដែល រួមមាន៖ ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ៧ដុល្លារអាម៉េរិកក្នុងមួយខែ, ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ដុល្លារអាម៉េរិកក្នុងមួយខែ, ប្រាក់ថ្លៃបាយសម្រាប់ការធ្វើការងារបន្ថែមម៉ោងដោយស្ម័គ្រចិត្តចំនួន ២ ០០០រៀល ក្នុងមួយថ្ងៃ ឬការទទួលបានបាយមួយពេលដោយឥតគិតថ្លៃ, និងប្រាក់រង្វាន់អតីតភាពការងារចំនួនពី ២ដុល្លារអាម៉េរិកដល់ ១១ដុល្លារអាម៉េរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតដែលបានធ្វើការចាប់ពីឆ្នាំទី២ ដល់ឆ្នាំទី១១។ ដូចនេះនៅក្នុងឆ្នាំ២០២២ ដោយបូករួមទាំងប្រាក់រង្វាន់អតីតភាពការងារ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗទទួលបានប្រាក់ឈ្នួលជាមធ្យមចាប់ពី ២១១ដុល្លារអាម៉េរិក ទៅ ២២២ដុល្លារអាម៉េរិកក្នុងមួយខែ។

តារាងទី៥៖ ការវិវត្តនៃប្រាក់ឈ្នួលអប្បបរមា និងប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅកម្ពុជាឆ្នាំ២០២២ (គិតជាដុល្លារអាម៉េរិក/ខែ)

| កាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្ត | ប្រាក់ឈ្នួលអប្បបរមា | ប្រាក់រង្វាន់ធ្វើការទៀងទាត់ | ប្រាក់សោហ៊ុយ ធ្វើដំណើរ និងស្នាក់នៅ | ប្រាក់ថៃទាំសុខភាព | ប្រាក់ឧបត្ថម្ភជីវភាព | ប្រាក់រង្វាន់អតីតភាពការងារ | ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | តិចបំផុត | ច្រើនបំផុត |
| ១ មករា ២០២២ | ១៩៤ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ២១១ | ២២២ |
| ១ មករា ២០២១ | ១៩២ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ២០៩ | ២២០ |
| ១ មករា ២០២០ | ១៩០ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ២០៧ | ២១៨ |
| ១ មករា ២០១៩ | ១៨២ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ១៩៩ | ២១០ |
| ១ មករា ២០១៨ | ១៧០ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ១៨៧ | ១៩៨ |
| ១ មករា ២០១៧ | ១៥៣ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ១៧០ | ១៨១ |
| ១ មករា ២០១៦ | ១៤០ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ១៥៧ | ១៦៨ |
| ១ មករា ២០១៥ | ១២៨ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ១៤៥ | ១៥៦ |
| ១ កុម្ភៈ ២០១៤ | ១០០ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ១១៧ | ១២៨ |
| ១ ឧសភា ២០១៣ | ៨០ | ១០ | ៧ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ៩៧ | ១០៨ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១ កញ្ញា ២០១២ | ៦១ | ១០ | ៧ | ៥ | ម.អ | (ពី 0 ទៅ ១១) | ៨៣ | ៩៤ |
| ១ មករា ២០១២ | ៦១ | ៧ | ម.អ | ៥ | ម.អ | (ពី 0 ទៅ ១១) | ៧៣ | ៨៤ |
| ១ មីនា ២០១១ | ៦១ | ៧ | ម.អ | ម.អ | ម.អ | (ពី 0 ទៅ ១១) | ៦៨ | ៧៩ |
| ១ តុលា ២០១០ | ៦១ | ៥ | ម.អ | ម.អ | ម.អ | (ពី 0 ទៅ ៥) | ៦៦ | ៧១ |
| ១ មេសា ២០០៨ | ៥០ | ៥ | ម.អ | ម.អ | ៦ | (ពី 0 ទៅ ៥) | ៦១ | ៦៦ |
| ១ មករា ២០០៧ | ៥០ | ៥ | ម.អ | ម.អ | ម.អ | (ពី 0 ទៅ ៥) | ៥៥ | ៦០ |
| ១ សីហា ២០០០ | ៤៥ | ៥ | ម.អ | ម.អ | ម.អ | (ពី 0 ទៅ ៥) | ៥០ | ៥៥ |
| ១៩៩៧ | ៤០ | ម.អ | ម.អ | ម.អ | ម.អ | (ពី 0 ទៅ ៥) | ៤០ | ៤០ |

*ប្រភព៖ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា(សម្គាល់៖ ម.អ ៖ មិនអនុវត្ត)*

ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ កម្ពុជាគឺជាប្រទេសតែមួយគត់ ដែលមានកំណើនប្រាក់ឈ្នួលអប្បបរិមាសម្រាប់ឆ្នាំ២០២២ ខណៈពេលដែលប្រទេសជិតខាង និងប្រទេសជាដៃគូរប្រកួត-ប្រជែងកម្ពុជា បានផ្អាកការដំឡើងប្រាក់ឈ្នួលអបប្បរមាយ៉ាងតិចចំនួន ២ឆ្នាំជាប់គ្នាដូចបានបង្ហាញក្នុងរូបខាងក្រោម៖

រូបភាពទី៩៖  ប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជា និងប្រទេសផ្សេងៗសម្រាប់ឆ្នាំ២០២២




ប្រភព៖ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា*"សេចក្តីសង្ខេបយន្តការកំណត់ប្រាក់ឈ្នួលផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងសមិទ្ធិផលសម្រេចបាន"*, ឆ្នាំ ២០២២

# ជំពូកទី ៤
# ផលចំណេញពី
# ការវិនិយោគផ្ទាល់ពីបរទេស
# លើវិស័យវាយនភ័ណ្ឌ
# នៅប្រទេសកម្ពុជា

# ជំពូកទី ៤

# ផលចំណេញពីការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌនៅប្រទេស

## ៤.១. ឱកាសការងារ និងប្រាក់បៀវត្សន៍

FDI បានបណ្តាក់ទុនលើគ្រប់វិស័យចម្បងៗ នៅក្នុងប្រទេសកម្ពុជាដែលក្នុងនោះរួមមានវិស័យកសិកម្ម មានកសិកម្មកែច្នៃ និងកសិកម្មលើការចិញ្ចឹមសត្វជាដើម។ ចំណែកវិស័យឧស្សាហកម្មវិញ ដែលផ្តោតចម្បងលើ វិស័យកាត់ដេរ រោងចក្រថាមពលអគ្គីសនី និងរ៉ែ និងប្លាស្ទិចជាដើម។ ខណៈពេលដែលការបណ្តាក់ទុនលើវិស័យសេវាកម្មមាន ពាណិជ្ជកម្ម ដឹកជញ្ជូន ហិរញ្ញវត្ថុ អចលនទ្រព្យសណ្ឋាគារ និងភោជនីយដ្ឋាន និងគមនាគមន៍ជាដើម។ ផលវិជ្ជមានដំបូងគេរបស់ FDIគឺបង្កើតការងារដល់ប្រជាជនក្នុងប្រទេស។ ជាការពិតណាស់នៅពេលដែលក្រុមហ៊ុនបរទេសមកធ្វើការវិនិយោគនៅប្រទេសកម្ពុជា នោះវានឹងបង្កើតឱកាសការងារដល់ប្រជាជនកម្ពុជាដោយការជ្រើសរើសបុគ្គលិកជំនាញ និងធនធានមនុស្សនៅក្នុងស្រុក។ ជាក់ស្តែង យោងទៅតាមគម្រោងដែលបានអនុម័តនៅក្នុងឆ្នាំ ២០១៥ យើងឃើញថា ក្នុងនោះវិនិយោគក្នុងវិស័យកសិកម្មត្រូវបានអនុម័តចំនួន ១៤គម្រោងដែលបានបង្កើតការងារចំនួន ១៣.៩៥៨នាក់ រួមមាន អ្នកមានជំនាញចំនួន ៨.២៤០នាក់ អ្នកគ្មានជំនាញចំនួន ៥.២៨២នាក់ អ្នកគ្រប់គ្រងចំនួន ២៦នាក់ និងវិស្វករចំនួន ៣៧នាក់ ព្រមទាំងបុគ្គលិកដទៃទៀត។ ចំណែកវិស័យឧស្សាហកម្មវិញ ត្រូវបានអនុម័តចំនួន ៩៧គម្រោង ដែលបានផ្តល់ការងារចំនួន ១១៩.៦១៥នាក់ ដែលក្នុងនោះរួមមាន បុគ្គលិកជំនាញចំនួន ១០១.២៧៩នាក់ អ្នកគ្មានជំនាញចំនួន ១៤.៥២៥នាក់ អ្នកគ្រប់គ្រងចំនួន ១៣៥នាក់ និងវិស្វករចំនួន ២៤២ នាក់ ព្រមទាំងបុគ្គលិកដទៃទៀត។ ចំណែកឯវិនិយោគក្នុងវិស័យសេវាកម្ម និងទេសចរណ៍វិញ ត្រូវបានអនុម័តចំនួន ១៣គម្រោង ដែលបានបង្កើតការងារចំនួន ៩.៩៩៨នាក់ ដែលក្នុងនោះមានបុគ្គលិកជំនាញចំនួន ៦.១៦៦នាក់ អ្នកគ្មានជំនាញចំនួន ២.៨០៦នាក់ អ្នកគ្រប់គ្រងចំនួន ៦១នាក់ និងវិស្វករចំនួន ១៦២ អ្នក ព្រមទាំងបុគ្គលិកដទៃទៀត។ សរុបមកគម្រោងវិនិយោគដែលត្រូវបានអនុម័-តក្នុងឆ្នាំ ២០១៥ មានចំនួន ១២៤គម្រោង ហើយបានបង្កើតការងារចំនួន ១៤៣.៥៧១នាក់។ FDI បានផ្តល់ការងារជាច្រើនសម្រាប់ប្រជាជនកម្ពុជា ដូចជា ការងារកាត់ដេរ និងសំណង់ បុគ្គលិកបម្រើតាមសណ្ឋាគារ និងភោជនីយដ្ឋាននានា អ្នកបកប្រែ និងដឹកអ្នកដំណើរជាដើម។ ក្នុងនោះ វិស័យកាត់ដេរត្រូវបានផ្តល់ការងារច្រើនជាងគេតាមការអនុម័តវិនិយោគ។ វិស័យកាត់ដេរនេះតំណាង ប្រហែលជា ៩០% នៃការនាំចេញនៃផលិតផលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ហើយបង្កើតការងារជាច្រើនដល់ប្រជាជនកម្ពុជា ជាពិសេសដល់ស្ត្រី។

## ៤.២ ការកាត់បន្ថយភាពក្រីក្រ

FDI មិនត្រឹមតែបានផ្តល់ការងារសម្រាប់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាផងដែរ។ ជាពិសេស វិស័យកាត់ដេរមានឥទ្ធិពលយ៉ាងខ្លាំងក្លា ក្នុងការកាត់បន្ថយភាពក្រីក្រ។ ភាគច្រើនប្រជាជននៅតាមជនបទ ជាពិសេសស្ត្រីបានបម្រើនៅក្នុងវិស័យកាត់ដេរនេះ ដោយទទួលបានប្រាក់ឈ្នួលក្នុងការផ្គត់ផ្គង់គ្រួសារ។ ជាក់ស្តែង ពលករក្នុងវិស័យកាត់ដេរទទួលបានប្រាក់បៀវត្សអប្បរមាស្មើនឹង ១៩៤ដុល្លាក្នុងមួយខែនៅក្នុងឆ្នាំ២០២២នេះ ហើយពួកគេអាចទទួលបានប្រាក់ឈ្នួលអប្បរមា និងអត្ថប្រយោជន៍ផ្សេងៗទៀតចំនួន ២១១ដុល្លាអាមេរិកក្នុងមួយខែនេះបើយោងទៅតាមតារាងទី១៥។ ប្រាក់ឈ្នួលក្នុងមួយថ្ងៃអាចបាន ២៨០០០រៀលក្នុងមួយថ្ងៃ តាមទិន្នន័យបង្ហាញនៅតារាងទី១៥។ ដូច្នេះប្រាក់ឈ្នួលទាំងនេះ ពលករទាំងអស់អាចប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃព្រមទាំងយកទៅផ្គត់ផ្គង់គ្រួសារនៅឯជនបទផងដែរ។

## ៤.៣ ការពង្រឹងធនធានមនុស្ស និងការអភិវឌ្ឍន៍ជំនាញ

ការវិនិយោគផ្ទាល់ពីបរទេស បានផ្ទេរគុណប្រយោជន៍ដល់ប្រទេសកម្ពុជា តាមរយៈការបំពាក់បំប៉នជំនាញ និងប្រសិទ្ធិភាពកម្លាំងពលកម្ម។ តាមរយៈការវិនិយោគទៅលើវិស័យចម្បងៗធំៗដូចជាវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម អាចបណ្តុះបណ្តាលជំនាញដល់ពលកម្មរបស់កម្ពុជារយៈការផ្លាស់ប្តូរបទពិសោធន៍ និងការបើកទូលាយនូវការផ្លាស់ប្តូរក្នុងស្រុក និងបរទេស។ ដូច្នេះហើយ FDI នាំមកនូវចំណេះដឹង និងចំណេះធ្វើ ដែលជាកត្តាជម្រុញឲ្យពលកម្មរបស់កម្ពុជាអនុវត្ត និងការផ្លាស់ប្តូរទៅរកការងារប្រើប្រាស់ជំនាញ និងបែបស្តង់ដារ។ លើសពីនេះទៅទៀត ការលើកទឹកចិត្តដោយការផ្លាស់ប្តូរពលកម្មទៅសិក្សានៅក្រុមហ៊ុនបរទេសរឹតតែអាចធ្វើឲ្យបុគ្គលិកទទួលបាននូវចំណេះដឹងថ្មីៗ ព្រមទាំងការអនុវត្តន៍នៅក្នុងការងារជាក់ស្តែងផងដែរ។

## ៤.៤ ការបង្កើននូវបច្ចេកវិទ្យា

ការចូលរួមដ៏មានសារៈសំខាន់មួយទៀតរបស់ FDI ចំពោះកម្ពុជានោះគឺការផ្ទេរនូវបច្ចេកវិទ្យា និងបង្កើនផលិតភាពផលិតកម្ម។ វាជាការពិតណាស់ ចំពោះបណ្តាប្រទេសអភិវឌ្ឍន៍ ដែលចូលមកធ្វើការវិនិយោគនៅកម្ពុជាតែងតែមានបច្ចេកវិទ្យាខ្លាំងជាងកម្ពុជា ដែលវាជាប្រភពមួយដ៏សំខាន់ ដើម្បីឈានទៅរកទំនើបនីយកម្ម (Modernization)។ ក្រុមហ៊ុនពហុជាតិអាចជួយក្នុងការពន្លឿនដំណើរការផលិតតាមរយៈការផ្ទេរបច្ចេកវិទ្យា និងធ្វើឲ្យការផលិតមានតម្លៃទាបតាមការបង្រៀនឲ្យចេះប្រើប្រាស់គ្រឿងអេឡិចត្រូនិច និងឧបករណ៍ម៉ាស៊ីនទំនើបៗ។ ជាទូទៅ FDI អាចចូលរួមក្នុងសេដ្ឋកិច្ចជាតិមួយតាមរយៈលក្ខណៈបីផ្សេងគ្នា៖

- វាអាចណែនាំបច្ចេកវិទ្យាថ្មី ដែលមិនធ្លាប់មានក្នុងស្រុកពីមុនមក។ ដូច្នេះវានឹងនាំប្រទេសនោះ ពោលគឺកម្ពុជាអាចឈានទៅរកការផលិត និងប្រើប្រាស់ផលិតផលថ្មីដែរ។
- ការវិនិយោគបរទេសដែលប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប ជាទូទៅវាទាមទារនូវកម្លាំងពលកម្ម ជំនាញខ្ពស់ដែរ។ ដូចនេះ វានឹងនាំទៅរកការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍នូវជំនាញដល់ពលកម្មនៅក្នុងស្រុក។
- គំនិតបង្កើតថ្មីក្នុងស្រុក (Domestic Innovation) គឺវាអាស្រ័យទៅលើបរិមាណ ឬចំនួននៃគំនិតថ្មីនោះ ដែលអាចមាននៅក្នុងសេដ្ឋកិច្ច។ ដូចនេះប្រសិនបើមានវត្តមានFDI នោះគំនិតថ្មីនោះនឹងអាចកើនឡើងលើសពីអ្វីដែលមានស្រាប់ ហើយវាអាចនឹងជម្រុញឲ្យបន្ថែមនូវគំនិតក្នុងស្រុកនោះទៀតផង។

## ៤.៥ លទ្ធផលនៃការស្រាវជ្រាវ

បន្ទាប់ពីបានធ្វើការស្រាវជ្រាវ និងសិក្សាពីឥទ្ធិពលក្នុងការវិនិយោគផ្ទាល់ពីបរទេស ក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរក្នុងប្រទេសកម្ពុជា។ យើងបានស្វែងយល់អំពីចំណុចសំខាន់នៃការវិនិយោគផ្ទាល់ពីបរទេសក្នុងប្រទេសកម្ពុជា យើងអាចមើលឃើញថាវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌពិតជាផ្តល់ផលចំណេញលើប្រាក់ ចំណូលរបស់ប្រជាជនកម្ពុជាគួរអោយកត់សម្គាល់។ ការវិនិយោគផ្ទាល់ពីបរទេសមកកាន់កម្ពុជា ជាពិសេសលើវិស័យវាយនភ័ណ្ឌ បានជំរុញអោយសេដ្ឋកិច្ចកម្ពុជា មានភាពរីកចំរើនស្របតាមគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ របស់កម្ពុជា។ ការនាំចេញជា ចំណែកធំមួយនៃប្រាក់ចំណូលជាតិ ហើយទីផ្សារធំជាងគេក្នុងការនាំចេញផលិតផលវាយនភ័ណ្ឌគឺ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។ ដោយសារកម្ពុជាមានសក្តានុពលមួយចំនួនដូចជា ទីតាំងភូមិសាស្ត្រល្អ ស្ថេរភាព-នយោបាយ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ថ្លៃដើមពកម្មទាប គោលនយោបាយលើកទឹកចិត្តអ្នកវិនិយោគពាណិជ្ជកម្ម និងទំនាក់ទំនងបរទេស តំបន់សេដ្ឋកិច្ចពិសេស និងមានច្បាប់ការពា អ្នកវិនិយោគទាំងនេះហើយដែលជាកត្តាក្នុងការទាក់ទាញអ្នកវិនិយោគ ពិសេសអ្នកវិនិយោគផ្ទាល់ពីបរទេស។

ជាក់ស្តែងតាមរយៈកំណើននៃការវិនិយោគផ្ទាល់ពីបរទេស បានជំរុញអោយវិស័យវាយនភ័ណ្ឌនៅកម្ពុជាមានការវិវត្តន៍គួរអោយកត់សម្គាល់ រហូតក្លាយជាវិស័យមួយដ៏សំខាន់ដែលបានរួមចំណែកយ៉ាងធំប្រហែលជា ៩០% នៃការនាំចេញនៃផលិតផលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។ ទន្ទឹមនិងនោះ វាបានផ្តល់ផលចំណេញជាច្រើនដល់សេដ្ឋកិច្ចកម្ពុជា តាមរយៈការផ្តល់ការងារដល់ប្រជាជនកម្ពុជារាប់លានអ្នក ការកាត់បន្ថយភាពក្រីក្រ ការផ្ទេរបច្ចេកទេស ការពង្រឹងជំនាញដល់កម្លាំងពលកម្ម ដែលទាំងនេះជាចំណុច

វិជ្ជមានដែលកម្ពុជាទទួលបាន។ កម្ពុជាក៏ទទួលបាន ឱកាសជាច្រើន ក្នុងការទាក់ទាញអ្នកវិនិយោគ ដូចជាការចូលជាសមាជិកសមាគមន៍សេដ្ឋកិច្ច ASEAN និង AFTA។

យោងតាមលទ្ធផលនៃការស្រាវជ្រាវនេះ កម្ពុជាពិតជាត្រូវការអ្នកវិនិយោគផ្ទាល់ពីបរទេសជាពិសេសការវិនិយោគលើវិស័យវាយនភ័ណ្ឌកាត់ដេរ ដែលជាវិស័យអាទិភាព ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិក៏ដូចជាជួយជ្រោមជ្រែងដល់ចំណូលប្រជាជនកម្ពុជា ។

# សេចក្តីសន្និដ្ឋាន

# និង

# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

នៅក្នុងការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ ផ្តោតសំខាន់លើការវិនិយោគទុនបរទេសនៅក្នុងវិស័យកាត់ដេរ និងវាយនភ័ណ្ឌនៅក្នុងប្រទេសកម្ពុជា ដែលជាការទាក់ទាញយ៉ាងខ្លាំង ពីសំណាក់វិនិយោគិនអន្តរជាតិដែលកំពុងស្វែងរកទីតាំងល្អបំផុតសម្រាប់ឧស្សាហកម្ម។ បន្ទាប់ពីប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាមស៊ីវិលក្នុងឆ្នាំ ១៩៩៣មក បានផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនចេញពីសេដ្ឋកិច្ចសង្គមនិយមទៅជាសេដ្ឋកិច្ចទីផ្សារសេរី និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយសហគមន៍អន្តរជាតិទាក់ទងនឹងវិបត្តិសេដ្ឋកិច្ចរួមមានសហភាពអឺរ៉ុប សហរដ្ឋអាមេរិក និងចិនដែលបានផ្តល់ឱកាសជាច្រើនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រព័ន្ធនយោបាយនិងហេដ្ឋារចនាសម្ព័ន្ធសង្គមទូទាំងប្រទេស។ ដូច្នេះប្រទេសកម្ពុជាបានសាងសង់ឧស្សាហកម្មផលិតកម្មជាច្រើនដើម្បីបំពេញនូវតម្រូវការទីផ្សារពិភពលោក ដែលតម្រូវឱ្យមានបរិមាណផលិតផលច្នៃប្រឌិតធំៗដើម្បីផ្គត់ផ្គង់ហើយអ្នកជំនួញបរទេសជាច្រើន បានជំនួសឧស្សាហកម្មផលិតកម្ម ទៅប្រទេសដែលផ្តល់ជូនអត្ថប្រយោជន៍ប្រកួតប្រជែងផ្នែកអាជីវកម្មនិងនិរន្តរភាពនៃផលិតភាព ជាមួយផលិតផលជាន់ទាបនិងចំណាយលើកម្លាំងពលកម្ម។

លទ្ធផលនៃការវិនិយោគបរទេសនៅកម្ពុជាត្រូវបានទាក់ទាញ និងទទួលបានរោងចក្រជាច្រើនដែលបានប្រតិបត្តិការនៅក្នុងវិស័យកាត់ដេរមានចំនួន ៨០០រោងចក្របានចុះបញ្ជីនៅឆ្នាំ២០១៦។ ផ្ទុយទៅវិញក្រសួងពាណិជ្ជកម្ម សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាបានកត់ត្រាថា មានរោងចក្រចំនួនតិចជាង ៦០០ បានចុះបញ្ជី។ ភាពខុសគ្នានេះទំនងជាកើតឡើងដោយសារតែក្រុមហ៊ុនមិននាំចេញ និងក្រុមហ៊ុនម៉ៅការបន្ត ដែលបានបង្កើតទស្សនៈទានការងាររាប់ពាន់សម្រាប់ប្រជាជនកម្ពុជាដែលអាចបំពេញការងារផលិតកម្ម ដំណើរការនៅក្នុងរោងចក្រកាត់ដេរ។ ផ្នែកវាយនភ័ណ្ឌនិងកាត់ដេរគឺជាសសរស្តម្ភដ៏សំខាន់ទីពីរក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅក្នុងសហគមន៍របស់ពួកគេដូចជាហេដ្ឋារចនាសម្ព័ន្ធសង្គមរួមមានការកសាងផ្លូវហាយវេ និងផ្លូវក្រោមដីដើម្បីភ្ជាប់ដំណើរការដឹកជញ្ជូននិងជំរុញការអភិវឌ្ឍសហគមន៍។ ការវិនិយោគទាំងនោះបានធ្វើអោយកំរិត GDP របស់ប្រទេសកម្ពុជាមានការកើនឡើងគួអោយកត់សម្គាល់ដោយកើនពី ២២.១៨ ប៊ីលានដុល្លាក្នុងឆ្នាំ ២០១៧ ដល់ ២៦.៩៦ ប៊ីលានដុល្លាក្នុងឆ្នាំ ២០២១ ។ ដើម្បីសម្រេច និងលើកទឹកចិត្តដល់វិនិយោគិនបរទេសកម្ពុជាបានបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅ ទីក្រុងភ្នំពេញ និងខេត្តសំខាន់ៗនានាដើម្បីឆ្លើយតបទៅនឹងការកើនឡើងនឧស្សាហកម្មកាត់ដេរនៅទូទាំងប្រទេស ដែលផ្តល់នូវគោលនយោបាយលើកទឹកចិត្តពិសេសក្នុងអំឡុងប្រតិបត្តិការអាជីវកម្ម។ ហេតុផលនេះវិនិយោគិន នឹងមិនមើលរំលងទីតាំងអាជីវកម្មរបស់

ប្រទេសកម្ពុជាក្នុងចំណោមបណ្ដាប្រទេសអាស៊ាន និងផ្ដល់ធនធានយ៉ាងពេញលេញដើម្បីជួយសម្រួលដល់តម្រូវការផលិតកម្មនិងវឌ្ឍនភាព។ លើសពីនេះសហគមន៍អន្តរជាតិបានផ្ដល់កូតាលើផលិតផល នាំចេញទៅកាន់ទីផ្សារសកលលោក ដោយមានកាតព្វកិច្ចតិចជាងមុន ដើម្បីកែលម្អជំហររបស់កម្ពុជានៅក្នុងបរិបទពិភពលោក។ កត្តានេះបានជំរុញឱ្យឧស្សាហកម្មកម្ពុជាបង្កើនទំហំផលិតកម្មនិងទិន្នផលចូលទៅក្នុងទីផ្សារក្រៅប្រទេស។ ដូចដែលយើងបានឃើញ ការប្រមូលផ្ដុំ វិនិយោគទុនបរទេសកាន់តែច្រើននៅក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរបានជំរុញអោយមានទ្រព្យសម្បត្តិ និងការអភិវឌ្ឍន៍ប្រទេសកម្ពុជាក្លាយជាប្រទេសឈានមុខគេនៅក្នុងតំបន់ និងស្តារឡើងវិញនូវកំណើនសេដ្ឋកិច្ចអភិវឌ្ឍន៍ប្រព័ន្ធអប់រំ ចំណូលប្រជាជន និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាពីមួយទៅមួយ។ ពេលវេលាដែលអាចធ្វើឱ្យប្រសើរឡើងនូវបដិវត្តន៍សេដ្ឋកិច្ច និងភាពក្រីក្រទាំងអស់ឱ្យសមស្រប ជាមួយបណ្ដាប្រទេស អាស៊ានដែលអាចប្រកួតប្រជែង រួមទាំងទុនរបស់អ្នក-ជំនាញដែលហូរចូលអាស៊ាននៅពេលដែល សហគមន៍អាស៊ានត្រូវបានបញ្ចូលគ្នាយ៉ាងពេញលេញហើយកម្ពុជា គឺជាទីតាំងល្អបំផុតសម្រាប់ការវិនិយោគអន្តរជាតិដែលទទួលបានប្រាក់ចំណេញខ្ពស់ និងមានប្រសិទ្ធភាពក្នុងផលិតកម្មនាំចេញទៅទីផ្សារពិភពលោក។

## ២. ការផ្ដល់អនុសាសន៍

ឆ្លងតាមការស្រាវជ្រាវខាងលើយើងឃើញថា សេដ្ឋកិច្ចប្រទេសកម្ពុជាមានការរីកចម្រើនខ្លាំងគួរអោយកត់សម្គាល់តាមរយៈ ការវិនិយោគផ្ទាល់ពីបរទេសលើវិស័យវាយនភ័ណ្ឌ។ ដូច្នេះរដ្ឋាភិបាលកម្ពុជាគួរតែយកចិត្តទុកដាក់លើការជំរុញអោយមានការវិនិយោគផ្ទាល់ពីបរទេស អោយកាន់តែច្រើនដោយពិនិត្យមើលលើចំនុចមួយចំនួនដូចខាងក្រោម៖

- ⇒ រដ្ឋាភិបាលកម្ពុជាគួរតែយកចិត្តទុកដាក់ទៅលើការរក្សា ស្ថេរភាពនយោបាយ និងសេដ្ឋកិច្ចដើម្បីជាកត្តាជំរុញអោយមានការទាក់ទាញវិនិយោគក្រៅប្រទេសអោយកាន់តែច្រើនជាងនេះ។
- ⇒ ការវិនិយោគគួរតែមានការថ្លឹងថ្លែង អោយបានត្រឹមត្រូវរវាងផលប៉ះពាល់ទៅលើធនធានធម្មជាតិ និងធនធានវប្បធម៌ដដែលបានរៀបរាប់នៅជំពូក២ខាងលើ និងផលចំណេញដែលតាមមកពីព្រោះធនធានទាំងនេះមានសក្ដានុពលយ៉ាងខ្លាំងក្លាក្នុងការទាក់ទាញ FDI។
- ⇒ កម្ពុជាគួរតែពង្រីកបន្ថែមនូវតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសដើម្បីទាក់ទាញបានវិនិយោគិនអោយកាន់តែច្រើន។
- ⇒ កម្ពុជាគួរតែពង្រឹងនូវគោលនយោបាយលើកទឹកចិត្តដល់វិនិយោគិនអោយកាន់តែមានប្រសិទ្ធភាពជាងមុន។

# ឯកសារយោង

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ


១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការវិនិយោគកម្ពុជា, *"ក្រមុងច្បាប់ និងបទបញ្ញត្តិ ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា"* ,ឆ្នាំ ២០១០។

២. បណ្ឌិត ហង់ ជួន ណារ៉ុន, ២០១៥, *"សេដ្ឋកិច្ចកម្ពុជា មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត"*, ភ្នំពេញ។

៣. សាស្ត្រាចារ្យ ម៉ម ចរិយារ៉ុធ, ២០១៣, *"ម៉ាក្រូសេដ្ឋកិច្ច"*,មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

៤. សាស្ត្រាចារ្យ ងួន ហេង, ២០១៤, *"រូបិយវត្ថុ និងធនាគា"* , មេរៀនសម្រាប់ថ្នាកបរិញ្ញាបត្រសេដ្ឋកិច្ចឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។


## ឯកសារជាភាសាបរទេស


៥. Samuelson និង Nordhaus, *"Fundamental of Investment [មូលដ្ឋានគ្រឹះនៃការវិនិយោគ] "*, (២០០១), ៧១។

៦. Charles W. L. Hill, "International business Competing in the Global Marketplace", Fifth Edition, (២០០៥), ២២១។

៧. John Dunning និង Rajneesh Narula, "Foreign Direct Investment and Governments" , ១៩៩៦។

៨. Yoko Asuyama និងSeiha Neou *," Firm dynamics in the Cambodian garment industry"*, ឆ្នាំ ២០១២, ទំព័រទី០៤

៩. Ken Loo, *"Cambodia's garment industry",* តុលា ២០១២


## គេហទំព័រ


១០. គេហទំព័រ អចលនទ្រព្យ , *"អំពីកម្ពុជា"*, www.realestate.com.kh ។

១១. អង្គការទិន្នន័យអំពីការអភិវឌ្ឍ, "ចំណូលជាតិសរុប (GNI)", www. opendevelopmentcambodia.com ។

១២. ក្រសួងពាណិជ្ជកម្ម, *"របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២០ និង ទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២១*, www.moc.gov.kh/ ។

១៣. គណៈកម្មការអឺរ៉ុប, *"ប្រទេសកម្ពុជា"*, ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០២១, ឯកសារជាភាសាអង់គ្លេស ពុំមានការបកប្រែជាភាសាខ្មែរ, www.business-humanrights.org/ ។

១៤. មជ្ឈមណ្ឌលធនធានធុរកិច្ច និងសិទ្ធិមនុស្ស, *"កម្ពុជា៖ ថ្វីត្បិតតែសហភាពអឺរ៉ុបសម្រេចចិត្តដកប្រព័ន្ធអនុគ្រោះពន្ធគ្រប់យ៉ាងលើកលែងតែអាវុធមួយផ្នែកដោយសារការរំលោភបំពានសិទ្ធិមនុស្សនិងសេរីភាពក៏ដោយ ចក្រភពអង់គ្លេសផ្តល់សិទ្ធិពាណិជ្ជកម្មដល់កម្ពុជាលើការនាំចេញ,"* ឯកសារជាភាសាអង់គ្លេស ពុំមានការបកប្រែជាភាសាខ្មែរ, www.cambodia.ohchr.org/kh/ ។

១៥. ក្រសួងផែនការ, ” *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨* ”, www.nis.gov.kh/index.php/km/ ។

១៦. ក្រសួងព័ត៌មាន, ថ្ងៃទី២២ ខែមិនា ឆ្នាំ២០១៩, "ពិធីសម្ពោធការសាងសង់ផ្លូវល្បឿនលឿនដំបូងបង្អស់នៅកម្ពុជា”, www.information.gov.kh/ ។

១៧. រូប៊ីន ស្ពីស ២០១៧, "*ប្រទេសកម្ពុជាត្រូវប្រឈមនឹងបញ្ហាទ្វេដងស្តីពីផែនការស្ពានផ្លូវថ្នល់*”, កាសែតភ្នំពេញប៉ុស្តិ៍, ចេញផ្សាយថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧, www.postkhmer.com/ ។

១៨. ចាប ម៉ូលី, "*ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក នៅកម្ពុជា: យុទ្ធសាស្ត្ររយៈពេលវែង*”, ឯកសារពិភាក្សារបស់វិទ្យាស្ថានអភិវឌ្ឍសេដ្ឋកិច្ច លេខ ១៥០, វិទ្យាស្ថានអភិវឌ្ឍសេដ្ឋកិច្ច ឆ្នាំ២០០៨, www.efi.mef.gov.kh/ ។

១៩. ហ៊ា គីមសាយ, "*ផ្លូវដែកសម្រាប់ការនាំអង្ករចេញរួចរាល់*”, កាសែត ភ្នំពេញប៉ុស្តិ៍, ចុះផ្សាយ ៩ សីហា ២០១៥, www.postkhmer.com/ ។

២០. ក្រសួងសាធារណការ និងដឹកជញ្ជូន, "*ទិដ្ឋភាពទូទៅនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន នៅព្រះរាជាណាចក្រកម្ពុជា*”បោះពុម្ពលើកទី៤, របាយការណ៍ប្រចាំឆ្នាំ, រាជធានីភ្នំពេញ: ក្រសួងសាធារណការ និងដឹកជញ្ជូន ឆ្នាំ២០១៣, www.mpwt.gov.kh/kh/ ។

២១. សមាគមអ្នកសាងសង់កម្ពុជា ថ្ងៃទី៧ ខែមិនា ឆ្នាំ២០១៩, "*ប្រទេសជប៉ុននឹងផ្តល់កម្ចី ២០៩លានដុល្លារដើម្បីពង្រីកផែសមុទ្រទឹកជ្រៅក្រុងព្រះសីហនុ*”, www.construction-property.com/km ។

២២. សមាគមអ្នកសាងសង់កម្ពុជា ថ្ងៃទី៧ ខែមិនា ឆ្នាំ២០១៩, "*ប្រទេសជប៉ុននឹងផ្តល់កម្ចី ២០៩លានដុល្លារដើម្បីពង្រីកផែសមុទ្រទឹកជ្រៅក្រុងព្រះសីហនុ*”, www.construction-property.com/km ។

២៣. ហ៊ិន ពិសី ២០១៨, "*ការពង្រីកកំពង់ផែភ្នំពេញដើម្បីជម្រុញការដឹកជញ្ជូនតាមផ្លូវទឹកនៅក្នុងប្រទេសកម្ពុជា*” កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨, www.khmertimeskh.com/ ។

២៤. ជា វណ្ណៈ, "*លោកនាយករដ្ឋមន្ត្រីប្រកាសពីការសាងសង់អាកាសយានដ្ឋានថ្មីនៅខេត្តសៀមរាប*”, កាសែតខ្មែរថាមស៍ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧, www.khmertimeskh.com/ ។

២៥. មជ្ឈមណ្ឌលអាកាសចរណ៍ CAPA, "*ព្រលានយន្តហោះភ្នំពេញ ជាអាកាសយានដ្ឋានល្អបំផុតទាក់ទងនឹងកំណើន*” , ២០១៧, កាសែត ភ្នំពេញប៉ុស្តិ៍, ចុះផ្សាយថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៩, www.postkhmer.com/ ។

២៦. ធនាគារពិភពលោក, World Bank, "Cambodia Economic Update", ២០១៦, www.worldbank.com ។

២៧. អង្គការពលកម្មអន្តរជាតិ, "*ព្រឹត្តិបត្រព័ត៌មានវិស័យកាត់ដេរនិងស្បែកជើងនៅកម្ពុជា*” លេខ ៦ ។ បោះពុម្ពខែ ឧសភា ឆ្នាំ២០១៧។

២៨. ធនាគារជាតិនៃកម្ពុជា, "*របាយការណ៍ប្រចាំឆ្នាំ២០១៩*”, www.nbc.org.kh/english/ ។

២៩. ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា, *"វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ជាវិស័យទ្រទ្រង់សេដ្ឋកិច្ច និងនាំចេញសំខាន់ជាងគេរបស់កម្ពុជា"*, ចេញផ្សាយថ្ងៃទី ១៧ មករា ២០២២, www.minimumwage.gov.kh/ ។

៣០. ក្រសួងព័ត៌មាន ,*"បទយកការណ៍៖ ក្រោមប្រព័ន្ធអនុគ្រោះពន្ធ GSP របស់អង់គ្លេស កម្ពុជានឹងទទួលបានប្រយោជន៍ច្រើនក្នុងការនាំចេញ"*, ចេញផ្សាយ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២០, www.information.gov.kh/ ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១ ៖ តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជានៅឆ្នាំ ២០២០




ប្រភព៖ គេហទំព័រ អចលនទ្រព្យ , www.realestate.com.kh , អំពីកម្ពុជា

## ឧបសម្ព័ន្ធទី២៖ ស្ថិតិនាំចេញមុខទំនេញសំខាន់ៗ(ឯកតា លានដុល្លារអាមេរិក)

| ល.រ | មុខទំនិញផ្សេងទៀត | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | បម្រែបម្រួល (%) |
|---|---|---|---|---|
| 1 | សម្លៀកបំពាក់ | ៨ ២៦៦,៣៥ | ៧ ៤២០,២៨ | (១០,២៤%) |
| 2 | ស្បែកជើង | ១ ២៦៤,៦២ | ១ ១១៦,៧៣ | (១១,៦៩%) |
| 3 | សម្ភារៈធ្វើដំណើរ | ១ ០៧៨,៨៩ | ៩៦៤,៧ | (១០,៥៨%) |
| 4 | ម៉ាស៊ីនបរិធាន និងសម្ភារៈអគ្គិសនី | ៥៧៤,៤៤ | ៧៥៥,៣៤ | ៣១,៤៩% |
| 5 | កង់ | ៤១២,៤៩ | ៥២៧,០៨ | ២៧,៧៨% |
| 6 | អង្ករ | ៤២០,១៣ | ៤៦៨,៥៨ | ១១,៥៣% |
| 7 | គ្រឿងសង្ហារឹម និងបរិធានបំភ្លឺ | ៤១៩,៤៨ | ៦៣១,៨៨ | ៥០,៦៣% |
| 8 | កៅស៊ូក្រែប | ២២៣,៩ | ២៨០,៣៤ | ២៥,២១% |
| 9 | ស្ករអំពៅ | ៥៤,៤ | ៤៦,០៤ | (១៥,៣៦%) |
| 10 | បន្លែ និងផ្លែឈើ | ៦៦,២៣ | ១៣៤,៦៣ | ១០៣,២៧% |
| 11 | មុខទំនិញផ្សេងទៀត | ១ ៩៦៧,៨ | ៤ ៨៦៩,៧៦ | ១៤៧,៤៧% |
| **សរុប៖** | | ១៤ ៧៤៨,៧៤ | ១៧ ២១៥,៣៧ | ១៦,៧២% |

## ឧបសម្ព័ន្ធទី៣៖ អត្រាកំណើនផលិតផលក្នុងស្រុកសរុប ( GDP) ២០១៩-២០២២




ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី, www.data.adb.org/dataset/gdp-growth-asia-and-pacific-asian-development

## ឧបសម្ព័ន្ធទី៤៖ ស្ថិតិនាំចេញរបស់កម្ពុជាក្នុងឆ្នាំ ២០២០ (គិតជាលានដុល្លារអាមេរិក)




ប្រភព៖ ក្រសួងពាណិជ្ជកម្ម, *របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២០ និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២១*, www.moc.gov.kh/

**ឧបសម្ព័ន្ធទី៥៖ ការងារ និងប្រាក់ឈ្នួលប្រចាំខែជាមធ្យមទូទៅ និងជាក់ស្តែង (វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង)**




ប្រភព៖ ក្រសួងពាណិជ្ជកម្ម វិទ្យាស្ថានជាតិស្ថិតិ (NIS) ឆ្នាំ ២០១៧

**ឧបសម្ព័ន្ធទី៦៖ កំណើននៃវិស័យកាត់ដេរសម្លៀកបំពាក់ វាយនភ័ណ្ឌ និងស្បែកជើង**




ប្រភព៖ មូលដ្ឋានទិន្នន័យរបស់ ទស្សវិស័យអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០២២

**ឧបសម្ព័ន្ធទី៧៖ ប្រទេសទទួលផលពី EBA នៅក្នុងតបន់អាស៊ី និងប្រទេសមិនទទួលផលពី EBA មួយចំនួននៅក្នុងតំបន់អាស៊ី**

| **ប្រទេសទទួលផលពី EBA ក្នុងតំបន់អាស៊ី** | **ប្រទេសមិនបានទទួលផល EBA ក្នុងតំបន់អាស៊ី** |
|---|---|
| អាហ្វហ្គានីស្ថាន | ចិន |
| បង់ក្លាដែស | ឥណ្ឌូនេស៊ី* |
| ប៊ុយតាន | ថៃ |
| កម្ពុជា | វៀតណាម* |
| ឡាវ | |
| មីយ៉ាន់ម៉ា[10] | |
| នេប៉ាល់ | |
| ទីម័រ | |

ប្រភព៖ គណកម្មការអឺរ៉ុប ឆ្នាំ២០១៧